**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អំណាចរបស់ព្រះរាជអាជ្ញាដឹកនាំនីតិវិធីនគរបាលយុត្តិធម៌

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ហួន លីហួរ**

ណែនាំដោយ

លោក **ទ្រី សុភារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហួន លីហួរ** ជានិស្សិតបរិញ្ញាបត្រនីតិសាស្រ្តជំនាន់ទី ២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**សូមថ្លែងអំណរអរគុណដ៏ជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក សឿន សាម៉ុន** និង **អ្នកម្តាយ ហ៊ុង គីមហ៊ី** ជាគុណដ៏អនេកប្បការដែលលោកទាំងពីរដែលបានផ្តល់កំណើតដល់កូន ព្រមទាំងខិតខំពុះពារនូវគ្រប់ឧបសគ្គ លះបង់នូវកម្លាំងកាយចិត្ត ញើសឈាម ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន និងព្រមទាំងជួយទំនុកបម្រុងទាំងផ្នែកបញ្ញាស្មារតី និងផ្នែកសម្ភារៈគ្រប់បែបយ៉ាងតាំងពីថ្នាក់បឋមសិក្សារហូតដល់ឧត្តមសិក្សា។

លើសពីនេះលោកទាំងពីរ បានផ្តល់ដំបូន្មាន អប់រំ ប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ដ៏ល្អប្រពៃដែលពុំអាចកាត់ថ្លៃបាន។ លោកទាំងពីរបានខិតខំលះបង់ទ្រព្យធន ទាំងឡាយ និងបានជ្រោមជ្រែងកូន ឱ្យកូនបានខ្ពង់ខ្ពស់ត្រចះត្រចង់ និងដើម្បីឱ្យខ្ញុំបាទក្លាយជាបញ្ញវ័ន្តមួយរូបដែលមានវិជ្ជាជីវៈ ព្រមទាំងមានចំណេះជំនាញមួយច្បាស់លាស់ប្រកបដោយគុណធម៌ សីលធម៌ និងសច្ចធម៌សម្រាប់សង្គមជាតិ។ ស្របពេលជាមួយគ្នានេះដែរ ខ្ញុំបាទដែលជាកូនសូមធ្វើការក្រាបលំឱនកាយគោរពនូវមហាករុណាទិគុណដ៏មហិមាទាំងអស់នេះដែលធ្វើឱ្យកូនចងចាំជានិច្ចចំពោះការលះបង់ដ៏ធំធេង និងគ្មានទីបញ្ចប់ ដើម្បីជួយជ្រោមជ្រែងជីវិតទទួលបាននូវផ្លែផ្កាដែលជាលទ្ធផលវិសេសវិសាលសម្រាប់ជាទុនប្រកបរបរចិញ្ចឹមជីវិត និងជួយអភិវឌ្ឍប្រទេសជាតិឱ្យស្របទៅតាមកាលានុវត្តភាពនៃទិដ្ឋភាពសង្គម។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យគ្រប់លំដាប់ថ្នាក់ លោក លោកស្រី មន្ត្រីរាជការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ទាំងអស់** ដែលបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីបណ្តុះបណ្តាល ចែករំលែកចំណេះដឹងដែលលោកមាន ព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនក្នុងសង្គម មកបង្ហាត់បង្រៀនខ្ញុំបាទ រួមទាំងសិស្សនិស្សិតទាំងអស់គ្នា គ្រប់មុខវិជ្ជាតាំងពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរហូតដល់បានបញ្ចប់ការសិក្សា និងក្លាយជាបុគ្គលដែលមានសមត្ថភាពក្នុងសង្គម។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកគ្រូ ជ្រ សុភារ៉ា** ដែលបានខិតខំដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយកម្លាំងចិត្ត គំនិតប្រាជ្ញាស្មារតី ដើម្បីបណ្តុះបណ្តាល និងពន្យល់ណែនាំដើម្បីឱ្យការចងក្រងសារណាមួយនេះទទួលបានជោគជ័យ។

# អារម្ភកថា

ព្រះរាជអាជ្ញាជាតួអង្គប្រតិបត្ត នៃស្ថាប័នអយ្យការដែលជាអ្នកធានាដល់ការអនុវត្តនូវបណ្តឹងអាជ្ញាដើម្បីស្វែងរកនូវការពិត ផ្តល់យុត្តិធម៌ដល់គ្រប់ជន គ្រប់បុគ្គលដែលជាគូភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះរាជអាជ្ញាគឺជាអ្នកដែលស្វែងរកយុត្តិធម៌នេះតាមរយៈបណ្តឹងអាជ្ញា ក្នុងគោលបំណងការពារផលប្រយោជន៍សាធារណៈ។ ទោះជាយ៉ាងណាក្តី ព្រះរាជអាជ្ញាអាចបំពេញនូវមុខងាររបស់ខ្លួនបានក៏ត្រូវការការចូលរួមពីសំណាក់ភាគីអាជ្ញាធរពាក់ព័ន្ធ ពិសេសផ្នែកខាងកងកម្លាំងសាធារណៈដែលមាននគរបាលយុត្តិធម៌។ នគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងការបំពេញតួនាទីជាជំនួយដល់អំណាចតុលាការ ព្រមទាំងប្រតិបត្តិការនីតិវិធីនានាដូចដែលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់ឱ្យ។ នគរបាលយុត្តិធម៌ជាផ្នែកមួយដែលមិនអាចខ្វះបានក្នុងការចូលរួមចំណែកដ៏សកម្មក្នុងបេសកកម្មការងារដល់សុខសុវត្ថិភាពជាតិ។

ក្នុងការជ្រើសរើសប្រធានបទ អំណាចព្រះរាជអាជ្ញាដឹកនាំនីតិវិធីរបស់នគរបាលយុត្តិធម៌ ដើម្បីធ្វើជាសារណាបញ្ចប់ឆ្នាំសិក្សានេះដោយសារតែខ្ញុំបាទចង់ស្វែងយល់បន្ថែមទៀតពីបទដ្ឋានគតិយុត្តសំខាន់ៗ ព្រមទាំងការអនុវត្តនូវសិទ្ធិអំណាចទាំងឡាយដែលអង្គអយ្យការមានប្រើប្រាស់ក្នុងការអាចដឹកនាំលើនគរបាលយុត្តិធម៌។ ខ្ញុំបាទសង្ឃឹមថាសារណានេះអាចជួយផ្តល់ជាពុទ្ធិ និងអាចជាមូលដ្ឋានក្នុងការស្រាវជ្រាវសម្រាប់អ្នកជំនាន់ក្រោយអ្នកសិក្សា និងអ្នកដែលចង់យល់ដឹងអំពីច្បាប់ផ្នែកនេះផងដែរ។

ទន្ទឹមគ្នានេះដែរ ចំពោះការតាក់តែងចងក្រងនូវសារណាមួយនេះ គឺជៀសមិនផុតពីភាពខ្វះខាត ខ្វះចន្លោះ អត្ថន័យ ឃ្លាប្រយោគ និងអក្ខរាវិរុទ្ធមួយចំនួនផងដែរ ខ្ញុំបាទសូមអភ័យទោសទុកជាមុននូវកំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនាក្នុងសារណាមួយនេះ និងសូមទទួលយកនូវពាក្យរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ លោក លោកស្រី ដែលជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ សិស្សច្បង មិត្តភក្តិ និងសិស្សប្អូនដែលជាអ្នកសិក្សាច្បាប់ជំនាន់ក្រោយផងដែរ។

# **មាតិកា**

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**អំពីអង្គការអយ្យការ និងអង្គភាពនគរបាលយុត្តិធម៌**

**១.១.ស្ថាប័នអយ្យការ** ........................................ ៤

១.១.១.តួនាទីរបស់អយ្យការ ........................................ ៤

១.១.២.លក្ខន្តិកៈរបស់អយ្យការ ........................................ ៦

១.១.៣.សមត្ថកិច្ចរបស់អយ្យការ ........................................ ៧

**១.២.អង្គភាពនគរបាលយុត្តិធម៌** ........................................ ៧

១.២.១.សមាសភាពនគរបាលយុត្តិធម៌ និងការទទួលបាននូវនីតិសម្បទាជានគរបាលយុត្តិធម៌ ........................................ ៨

១.២.១.១.មន្ត្រីនគរបាលយុត្តិធម៌ ........................................ ៨

១.២.១.២.ភ្នាក់ងារនគរបាលយុត្តិធម៌ ........................................ ១៣

១.២.១.៣.មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ........................................ ១៣

១.២.២.បេសកកម្មនគរបាលយុត្តិធម៌ ........................................ ១៥

១.២.៣.បញ្ជីនៃបណ្តឹង ........................................ ១៧

**ជំពូកទី២**

**អំណាចរបស់ព្រះរាជអាជ្ញាដឹកនាំនីតិវិធីស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌**

**២.១.ការស៊ើបអង្កេតជាក់ស្តែង** ........................................ ១៨

២.១.១.លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ........................................ ១៨

២.១.២.ដំណើរការនៃការស៊ើបអង្កេតជាក់ស្តែង ........................................ ១៩

២.១.៣.ការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ ........................................ ២០

២.១.៤.ការឃាត់ខ្លួន ........................................ ២៣

២.១.៥.ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន....................................................................២៥
២.១.៦.វិធានពិសេសនៃការស៊ើបអង្កេតករណីជាក់ស្តែង ..........................................................២៥
២.១.៧.មោឃភាពនៃនីតិវិធីស៊ើបអង្កេតជាក់ស្តែង.................................................................... ២៦
**២.២.ការស៊ើបអង្កេតបឋម** ......................................................................................... ២៧
២.២.១.ការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ករណីបទល្មើសមិនជាក់ស្តែង ........................... ២៧
២.២.២.ការឃាត់ខ្លួន និងនីតិវិធីនៃការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន .............................. ២៨
២.២.៣.វិធានពិសេសនៃការស៊ើបអង្កេតករណីមិនជាក់ស្តែង...................................................... ២៨
២.២.៤.មោឃភាពនៃនីតិវិធីស៊ើបអង្កេតមិនជាក់ស្តែង ...........................................................២៩
**២.៣.ភាពខុសគ្នារវាងការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម**..................២៩
**២.៤.ការមានចំណាត់ការលើបណ្តឹងអាជ្ញាដោយស្ថាប័នអយ្យការ**................................... ៣០
២.៤.១.ការតម្កល់រឿងទុកឥតចាត់ការ............................................................................... ៣០
២.៤.២.គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់.......................................................... ៣១
២.៤.២.១.ការបើកការស៊ើបសួរ..........................................................................................៣១
២.៤.២.២.ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ...............................................................................៣៣
២.៤.២.៣.នីតិវិធីបង្ហាញខ្លួនភ្លាម ........................................................................................ ៣៤

## **ជំពូកទី៣**

## **អំពីអំណាចព្រះរាជអាជ្ញាចំពោះនគរបាលយុត្តិធម៌**

**៣.១.ការធ្វើអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌ និងការដាក់វិន័យ**..................... ៣៦
៣.១.១.ការធ្វើអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌........................................................... ៣៦
៣.១.១.១.ការធ្វើអធិការកិច្ចពិនិត្យបញ្ជីបណ្តឹងព្រហ្មទណ្ឌ ........................................................ ៣៧
៣.១.១.២.ការធ្វើអធិការកិច្ចពិនិត្យបញ្ជីនៃការឃាត់ខ្លួន.......................................................... ៣៨
៣.១.១.៣.ការធ្វើអធិការកិច្ចពិនិត្យទីកន្លែងឃាត់ខ្លួន ............................................................. ៣៨
៣.១.១.៤.ការធ្វើអធិការកិច្ចចុះអង្កេតពន្ធនាគារ .................................................................... ៣៩

៣.១.២.កំហុសរបស់នគរបាលយុត្តិធម៌ និងការទទួលរងវិន័យ ........ ៣៩

**៣.២.ការអនុវត្តទោសរបស់តុលាការ** ........ ៤១

៣.២.១.ការជូនដំណឹងអំពីសាលក្រម ........ ៤១

៣.២.២.កាអនុវត្តសាលក្រម ........ ៤៣

៣.២.២.១.ការអនុវត្តមូលទោស ........ ៤៤

៣.២.២.២.ការអនុវត្តទោសបន្ថែម ........ ៤៦

៣.២.២.៣.ការអនុវត្តទោសជំនួស ........ ៤៨

**សេចក្ដីសន្និដ្ឋាន** ........ ៥០

**អនុសាសន៍** ........ ៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសមួយដែលមានការអភិវឌ្ឍជឿនលឿនលុះត្រាតែប្រទេសនោះមានការយកចិត្តទុកដាក់ទៅលើប្រជាពលរដ្ឋដោយផ្តល់ឱ្យនូវសន្តិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងសង្គម។ ទោះបីជាមានការខិតខំព្យាយាមរក្សាសណ្តាប់ធ្នាប់យ៉ាងណាក៏ដោយតែងជៀសមិនផុតពី ការកើតឡើងនូវបទល្មើសផ្សេងៗឡើយ។ នៅពេលដែលមានបទល្មើសកើតឡើង នគរបាលយុត្តិធម៌ដែលជាជំនួយនៃអំណាចតុលាការត្រូវធ្វើការអន្តរាគមន៍ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋទាំងអស់។ លើសពីនេះ នគរបាលយុត្តិធម៌ដើរតួនាទីដើម្បីធានាដល់ការប្រមូលនូវភស្តុតាង និងកំណត់អត្តសញ្ញាណភាគីនៃបទល្មើស ជូនដល់ព្រះរាជអាជ្ញាដើម្បីអាចមានលទ្ធភាពក្នុងការអនុវត្តតួនាទីរបស់ខ្លួន ពិសេសគឺគោលការណ៍កាលានុវត្តន៍ភាពនៃការចោទប្រកាន់ធានាក្នុងការទទួលបានសុក្រឹតភាព តម្លាភាព និងយុត្តិធម៌។

ជាក់ស្តែងនគរបាលយុត្តិធម៌មានសមាសភាពដូចជា មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ព្រមទាំងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។ យ៉ាងណាមិញ សមាសភាពទាំង ៣ នៃនគរបាលយុត្តិធម៌គឺក្រមនីតិវិធីព្រហ្មទណ្ឌបានដាក់ឱ្យស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងការអនុវត្តតួនាទីនេះ។ យើងបានដឹងហើយថានគរបាលយុត្តិធម៌ពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងបរិបទរស់នៅប្រចាំថ្ងៃរបស់យើងទាំងអស់គ្នាដែលពួកគាត់ត្រូវតែមានវត្តមានជានិច្ចដោយពុំអាចខានបានទេ។ នគរបាលយុត្តិធម៌ គឺនៅតែបន្តទប់ស្កាត់បទល្មើស បង្ក្រាបបទល្មើស បង្ការបទល្មើស ក៏ដូចជាបន្តធ្វើជាជំនួយដល់អំណាចតុលាការក្នុងការស្វែងរកយុត្តិធម៌តាមរយៈការស៊ើបអង្កេតរបស់ពួកគាត់។ ដូច្នេះយើងអាចនិយាយបានថាចំពោះ តួនាទីភារកិច្ចរបស់នគរបាលយុត្តិធម៌គឺតែងតែផ្តល់ផលប្រយោជន៍ជូនប្រជាពលរដ្ឋ ព្រមទាំងសង្គមជាតិទាំងមូលផងដែរ និងកាន់តែមានភាពស្របច្បាប់ក្នុងការដែលមានការដឹកនាំនីតិវិធីដោយព្រះរាជអាជ្ញា។

ដូច្នេះដើម្បីយល់ដឹងបន្ថែមអំពីអំណាចព្រះរាជអាជ្ញាដឹកនាំនីតិវិធីរបស់នគរបាលយុត្តិធម៌ សារណានេះនឹងបកស្រាយតាមកម្រិតថ្នាក់បរិញ្ញាបត្រ ដើម្បីជាការចែករំលែកចំណេះដឹងជូនដល់មិត្តអ្នកអានទាំងឡាយជាពិសេសសម្រាប់មិត្តអ្នកអានណាដែលចង់ក្លាយខ្លួនជា តំណាងអយ្យការ ឬនគរបាលយុត្តិធម៌ នាថ្ងៃអនាគត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយហេតុថាព្រះរាជអាជ្ញាទទួលបានសិទ្ធិអំណាចយ៉ាងធំធេងសម្រាប់រឿងក្តីផ្នែកខាងព្រហ្មទណ្ឌហេតុនេះហើយព្រះរាជអាជ្ញាប្រាកដជាត្រូវការជំនួយពិសេសផ្នែកខាងកម្លាំងប្រតិបត្តិការ ដែលមានអង្គភាពនគរបាលយុត្តិធម៌ជាសេនាធិការ។ ដើម្បីយល់ដឹងឱ្យកាន់តែច្បាស់នូវចំណុចនេះ គប្បីត្រូវដឹងថា៖

តើអ្វីជាអង្គការអយ្យការ?

តើអ្វីជាអង្គភាពនគរបាលយុត្តិធម៌?

តើព្រះរាជអាជ្ញាមានសិទ្ធិអំណាចអ្វីខ្លះក្នុងការដឹកនាំនីតិវិធីស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌?

តើព្រះរាជអាជ្ញាមានសិទ្ធិអំណាចអ្វីខ្លះមកលើនគរបាលយុត្តិធម៌?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ ក៏មានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងខ្លះៗដែលបានសិក្សាដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ដែលការស្រាវជ្រាវនេះជាវណ្ណកម្មមួយសម្រាប់ជាជំនួយដល់មិត្តៗនិស្សិត ដែលមានបំណងចង់សិក្សាស្វែងយល់អំពីទំនាក់ទំនងការងារនៃព្រះរាជអាជ្ញាជាមួយនគរបាលយុត្តិធម៌ ព្រមទាំងដើម្បីជាជំនួយដល់សិក្សាការ ស្រាវជ្រាវ ការប្រកបអាជីពវិជ្ជាជីវៈក្នុងវិស័យតុលាការ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ការស្រាវជ្រាវទៅលើសារណានេះ គឺមានដែនកំណត់ផ្តោតទៅលើការសិក្សាទាក់ទងនឹងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញានៃអយ្យអមសាលាដំបូងលើវិធាននៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងអំណាចនានាដែលព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងមានចំពោះនគរបាលយុត្តិធម៌ក្នុងនាមជានាយឋានានុក្រមផ្នែកខាងនីតិវិធីព្រហ្មទណ្ឌ និងសិទ្ធិអំណាចមួយចំនួនដែលអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការជាន់ខ្ពស់មានចំពោះនគរបាលយុត្តិធម៌ ដោយឡែកសម្រាប់សិទ្ធិអំណាចព្រះរាជអាជ្ញាលើនគរបាលយុត្តិធម៌នៃបទល្មើសតាមវិស័យពិសេសនីមួយៗ ព្រមទាំងសិទ្ធិអំណាចនៃអយ្យការអមតុលាការយោធាមានលើនគរបាលយុត្តិធម៌ដែលជាកងរាជអាវុធហត្ថពុំមានលើកយកមកសិក្សានោះឡើយ។ លើសពីនេះទៅទៀតប្រធានបទនេះបានផ្តោតសំខាន់ទៅលើការសិក្សាអំពីការអនុវត្តនីតិវិធីស៊ើបអង្កេតដោយនគរបាលយុត្តិធម៌ដែលមានការដឹកនាំ និងសម្របសម្រួលពីសំណាក់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានអត្ថប្រយោជន៍ជាជំនួយស្មារតី ជាពុទ្ធិ និងពង្រីកចំណេះដឹង ក៏ដូចជាការជំនួយជាធនធាន ចំណេះដឹង សម្រាប់បំពេញមុខងារក្នុងទំនាក់ទំនងការងារនៃអង្គភាពនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ។ ជាពិសេស មិត្តអ្នកអានគ្រប់រូបអាចស្វែងយល់ អំពីស្ថាប័នអយ្យការ ស្ថាប័ននគរបាលយុត្តិធម៌ ទំហំនៃការបំពេញភារកិច្ចដោយនគរបាលយុត្តិធម៌ ជាលក្ខណៈទ្រឹស្តីផ្សារភ្ជាប់ជាមួយទិដ្ឋភាពនៃការអនុវត្តបច្ចុប្បន្នឱ្យកាន់តែមានភាពច្បាស់លាស់។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការប្រមូលទិន្នន័យឯកសារផ្សេងៗដែលទាក់ទងប្រធានបទនេះ ខ្ញុំបាទបានខិតខំព្យាយាមស្រាវជ្រាវជាលក្ខណៈទូទៅនៃប្រធានបទនេះ នៅតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការសាកសួរសុំយោបល់ពីសំណាក់សាស្ត្រាចារ្យផ្នែកច្បាប់ សិស្សច្បង និងមិត្តរួមការងារ ជាពិសេស ឯកសារដែលមានលក្ខណៈជាលាយលក្ខណ៍អក្សរដូចជា សៀវភៅ អត្ថបទផ្សេងៗ ដែលខ្ញុំបាទបានព្យាយាមរកនៅតាមបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញតាមតូបលក់សៀវភៅ បណ្ណាគារ គេហទំព័រជាតិមួយចំនួនទៀតដែលជាគ្រឹះនាំឱ្យអាចដំណើរការសរសេរសារណានេះបានដោយជោគជ័យ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះបែងចែកចេញជា ៣ (បី) ជំពូក៖

**ជំពូកទី១ អំពីអង្គការអយ្យការ និងអង្គភាពនគរបាលយុត្តិធម៌** រៀបរាប់អំពីតួនាទី លក្ខន្តិកៈព្រមទាំងសមត្ថកិច្ច នៃអង្គការអយ្យការ និងសមាសភាពនគរបាលយុត្តិធម៌ដែលទទួលបាននីតិសម្បទាហើយអនុវត្តនូវបេសកកម្មការងាររបស់ខ្លួន។

**ជំពូកទី២ អំណាចព្រះរាជអាជ្ញាដឹកនាំនីតិវិធីស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌** រៀបរាប់អំពីនីតិវិធីនៃការស៊ើបអង្កេតជាក់ស្តែង និងនីតិវិធីនៃការស៊ើបអង្កេតបឋម ដែលព្រះរាជអាជ្ញាមានសិទ្ធិអំណាចដឹកនាំនគរបាលយុត្តិធម៌ ហើយមានចំណាត់ការលើបណ្តឹងអាជ្ញា។

**ជំពូកទី៣ អំពីអំណាចព្រះរាជអាជ្ញាចំពោះនគរបាលយុត្តិធម៌** រៀបរាប់អំពីអំណាចដែលព្រះរាជអាជ្ញាមានមកលើនគរបាលយុត្តិធម៌ក្នុងនាមជានាយឋានានុក្រមផ្នែកខាងនីតិវិធីព្រហ្មទណ្ឌ ដូចជាអំណាចអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌ ការដាក់វិន័យលើនគរបាលយុត្តិធម៌ និងការដឹកនាំនគរបាលយុត្តិធម៌ក្នុងការអនុវត្តសេចក្តីសម្រេចរបស់តុលាការ។

# ជំពូកទី១
# អំពីអង្គការអយ្យការ
# និងអង្គភាពនគរបាលយុត្តិធម៌

# ជំពូកទី១
# អំពីអង្គការអយ្យការ និងអង្គភាពនគរបាលយុត្តិធម៌

## ១.១.ស្ថាប័នអយ្យការ

មានតែស្ថាប័នអយ្យការមួយនោះទេ ដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការធ្វើបណ្ដឹងអាជ្ញា (បើកបណ្ដឹងព្រហ្មទណ្ឌ) ដោយអនុលោមតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់មានឋានានុក្រមខ្ពស់បំផុតនៃកម្ពុជា។[1] បើឱ្យនិយមន័យដោយយោងតាម វចនានុក្រម អយ្យការ សំដៅដល់ស្ថាប័នមួយដាច់ដោយឡែកពីចៅក្រម ដែលដឹកនាំដោយព្រះរាជអាជ្ញា។[2] ដើម្បីស្វែងយល់បន្ថែមអំពីស្ថាប័នអយ្យការចំណុចខាងក្រោមនឹងមានសិក្សារួមមាន (១.១.១.តួនាទីរបស់អយ្យការ) ព្រមទាំងសិក្សាពី(១.១.២.លក្ខន្តិកៈរបស់អយ្យការ) និង(១.១.៣. សមត្ថកិច្ចរបស់អយ្យការ)។

### ១.១.១.តួនាទីរបស់អយ្យការ

ស្ថាប័នអយ្យការ គឺជាម្ចាស់នៃបណ្ដឹងអាជ្ញា។ ស្ថាប័នមួយនេះមានមុខងារចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធ្វើការសន្និដ្ឋានជូនតុលាការក្នុងការសម្រេចសេចក្ដី។ ក្នុងន័យនេះដែរ តំណាងអយ្យការត្រូវតែមានវត្តមាននៅក្នុងសវនាការរឿងក្ដីព្រហ្មទណ្ឌដើម្បីធ្វើជាបុគ្គលតំណាងឱ្យរដ្ឋ ការពារផលប្រយោជន៍សាធារណៈ សន្តិសុខ និងសណ្ដាប់ធ្នាប់ល្អនៃប្រទេស។ អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ ជាមួយគ្នានេះអង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយពីដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយក្នុងការអនុវត្តមុខនាទីរបស់ខ្លួន។ កាលណាអង្គហេតុដែលជាបទល្មើសត្រូវបានពិនិត្យដោយព្រះរាជអាជ្ញានូវអត្ថិភាពនៃបទល្មើសរួចមក ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចត្រូវធ្វើចំណាត់ការលើរឿងក្ដីនោះភ្លាម។ ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅពេលដែលសវនាការរឿងព្រហ្មទណ្ឌ។[3]

ចៅក្រមអយ្យការមានសមាសភាព៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូង។[4]

[1] មាត្រា១៣១(ថ្មី), រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

[2] វចនានុក្រមរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២២

[3] មាត្រា២៧ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[4] មាត្រា២៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

តួនាទីចម្បងរបស់អង្គការអយ្យការ គឺការចោទប្រកាន់លើសំណុំរឿងព្រហ្មទណ្ឌតាមរយៈគោលការណ៍កាលានុវត្តភាពដែលជាគោលការណ៍មួយនៅក្នុងនីតិវិធីព្រហ្មទណ្ឌដែលផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលបញ្ជូនមក ដើម្បីសម្រេចថាតើគួរតែតម្កល់រឿងទុកឥតចាត់ការ ឬគួរធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដែលគេអាចហៅបានថាជា ជម្រើសនៃការចោទប្រកាន់។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចមិនធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយទោះបីជាអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ផ្សេងៗទៀតក៏ដោយ។ ជាគោលការណ៍ព្រះរាជអាជ្ញាអាចពិចារណាអំពីតុល្យភាពនៃការផ្តន្ទាទោស និងទំហំនៃព្យសនកម្ម(ការខូចខាត) របស់ជនរងគ្រោះ និងសង្គមជាតិទាំងមូលត្រូវទទួលរង។

ប្រសិនបើការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវបានសម្រេចដោយព្រះរាជអាជ្ញា ដោយមិនបានពិចារណាថ្លឹងថ្លែងច្បាស់លាស់ទេ ក៏អាចជះនូវភាពអវិជ្ជមានផងដែរ។ ដើម្បីចៀសវាងការប្រើប្រាស់អំណាចជ្រុលពីសំណាក់ព្រះរាជអាជ្ញាតាមរយៈការតម្កល់រឿងទុកឥតចាត់ការ ក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា៤១ កថាខណ្ឌទី៤ និងកថាខណ្ឌទី៦ បានបញ្ញត្តិថា ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេនោះ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាន។[5] ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ចេញអធិបញ្ជាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់តាមការណែនាំជាលាយលក្ខណ៍អក្សរ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ។ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា។

ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់នគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែករណីមានការអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួសនោះនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរវិញ។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានទទួលស្គាល់ ហើយអនុវត្តការដឹកនាំលើនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងស៊ើបអង្កេតដោយផ្ទាល់ និងធ្វើគ្រប់ការណែនាំដល់នគរបាលយុត្តិធម៌ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីនគរបាលយុត្តិធម៌ និងផ្តល់សិទ្ធិស៊ើបអង្កេតដល់

[5] មាត្រា៤១ កថាខណ្ឌទី៤ និងទី៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

នគរបាលយុត្តិធម៌ផ្សេងៗ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយគ្រប់ពេលនៃនីតិវិធីស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ដោយព្រមទាំងត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។[6] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីខេត្ត ដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីខេត្ត អាចប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសដែលទទួលបានការអនុញ្ញាត ឬចាត់តាំង។[7]

**១.១.២.លក្ខន្តិកៈរបស់អយ្យការ**

ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា គឺជាបទដ្ឋានគតិយុត្តដែលគ្រប់គ្រងផ្ទាល់លើអង្គចៅក្រមដែលរួមទាំងព្រះរាជអាជ្ញាផងដែរ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។ ដែលបុគ្គលក្លាយជាព្រះរាជអាជ្ញាត្រូវជ្រើសរើសតែជាអ្នកមានសមត្ថភាព និងមានសុចរិតមានសីលធម៌ស្អាតស្អំដើម្បីធានាដល់សេចក្តីថ្លៃថ្នូរនៃស្ថាប័នអយ្យការ។[8]

ព្រះរាជអាជ្ញាជាអង្គអវិភាគដែលតម្រូវឱ្យបំពេញមុខងារនៅអង្គការអយ្យការមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា ព្រមទាំងអាចជំនួសគ្នាទៅវិញទៅមកបាន ឬបន្តការងារពីគ្នាក្នុងសំណុំរឿងតែមួយបានតាមការចាត់តាំងដោយនាយឋានានុក្រមរបស់ខ្លួន។ ជាមួយគ្នានេះផងដែរត្បិតអង្គការអយ្យការអមសាលាជម្រះក្តីតែងនៅអមជាមួយគ្នានឹងសាលាជម្រះក្តី ក៏ប៉ុន្តែសាលាជម្រះក្តីមិនមាននូវអំណាចមកលើអង្គការអយ្យការនោះឡើយ។[9] ព្រះរាជអាជ្ញាទាំងឡាយអនុវត្តមុខងារ និងតួនាទីរបស់ខ្លួន ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោល ពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ លើកលែងនាយឋានានុក្រមរបស់ខ្លួន។[10] ក្របខណ្ឌព្រះរាជអាជ្ញាអមសាលាជម្រះក្តីអនុវត្តតាមប្រព័ន្ធអាជីពបិទដែលមានវិសមិតភាពនឹងការបំពេញមុខងារដទៃដូចជា ផ្នែកនៃមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល តំណែងនយោបាយ ទីប្រឹក្សាមេធាវី និងមុខរបរពាណិជ្ជកម្មផ្សេងៗ ដែលអាចជះឥទ្ធិពលដល់ទំនាស់ផលប្រយោជន៍ហើយធ្វើឱ្យប៉ះពាល់ដល់កិត្តិយសស្ថាប័នអយ្យការ ប៉ុន្តែអាចបំពេញមុខងារជាគ្រូឧទ្ទេសនាមសម្រាប់ការបង្រៀននៅតាមគ្រឹះស្ថានសិក្សាបាន។[11]

---

[6] មាត្រា៣៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[7] មាត្រា៣៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[8] មាត្រា៤, ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

[9] មាត្រា៧៥ ចំណុចទី២ និងទី៣, ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

[10] មាត្រា៧៧, ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

[11] មាត្រា១០៦, ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០៧១៤/០១៦, ប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

### ១.១.៣.សមត្ថកិច្ចរបស់អយ្យការ

សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញាមានសមត្ថកិច្ច តាមដែនដីដែលខ្លួនបានកាន់កាប់គឺ៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តិបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស។[12]

ត្បិតចៅក្រមអយ្យការ ជាអង្គឯករាជ្យក៏ប៉ុន្តែអនុវត្តបែបឋានានុក្រមដែលមានទិសដៅគោលអនុវត្តឱ្យប្រសើរនូវគោលនយោបាយព្រហ្មទណ្ឌ។ នាយឋានានុក្រមនៃអង្គការអយ្យការគឺ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានសិទ្ធិពេញលេញអាចធ្វើអធិបញ្ញាជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយដែលបានដឹងទៅដល់ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងតាមការយល់ឃើញរបស់រដ្ឋមន្ត្រី។ បើទោះបីក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវអំណាចអធិបញ្ញាឱ្យចោទប្រកាន់ក្តីក៏ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនមានសិទ្ធិក្នុងការធ្វើអធិបញ្ញាឱ្យតម្កល់រឿងទុកឥតចាត់ការបាននោះឡើយ។ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ មានអំណាចលើរាល់ចៅក្រមអយ្យការទាំងអស់ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង រួមទាំងអំណាចក្នុងការធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យចៅក្រមអយ្យការណាមួយធ្វើការចោទប្រកាន់តែម្តងក៏បាន រួមទាំងការធ្វើនូវសេចក្តីសន្និដ្ឋានតាមការគួរ។ លើសពីនេះព្រះរាជអាជ្ញាអមសាលាដំបូងក៏មានអំណាចលើចៅក្រមអយ្យការទាំងអស់ក្នុងដែនសមត្ថកិច្ចខ្លួន ដែលអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬចាត់ឱ្យចៅក្រមអយ្យការណាមួយដើម្បីចោទប្រកាន់រួមទាំងការធ្វើនូវសេចក្តីសន្និដ្ឋានតាមការគួរផងដែរ។[13] បើទោះបីចៅក្រមអយ្យការអនុវត្តមុខងារតាមគោលការណ៍ឋានានុក្រមក្តី ប៉ុន្តែអំឡុងពេលសវនាការចៅក្រមអយ្យការមានសិទ្ធិក្នុងការកត់សម្គាល់ផ្ទាល់មាត់ដោយសេរីតាមសតិសម្បជញ្ញៈរបស់ខ្លួន ដោយពុំមានការអនុវត្តវិន័យណាមួយដោយសារការថ្លែងដោយសេរីនៅក្នុងសវនាការនេះឡើយ។[14]

## ១.២.អង្គភាពនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ជាពាក្យសម្រាប់ប្រើប្រាស់ជារួម សំដៅដល់កងកម្លាំងសាធារណៈខាងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ (នគរបាលជាតិ និងកងរាជអាវុធហត្ថ) ព្រមទាំងមន្ត្រីរាជការដទៃទៀតដែលទទួលបាននីតិសម្បទាតាមច្បាប់ ហើយមានលទ្ធភាពបំពេញភារកិច្ចក្នុងរឿងក្តីផ្នែកព្រហ្មទណ្ឌ។ ក្នុងនោះនគរបាលយុត្តិធម៌មានសមាសភាពចំនួន ៣ ចម្បងមាន ៖

[12] មាត្រា៣៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[13] មាត្រា២៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[14] មាត្រា៣០, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

១. មន្ត្រីនគរបាលយុត្តិធម៌

២. ភ្នាក់ងារនគរបាលយុត្តិធម៌

៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។[15]

### ១.២.១.សមាសភាពនគរបាលយុត្តិធម៌ និងការទទួលបាននូវនីតិសម្បទាជានគរបាលយុត្តិធម៌

#### ១.២.១.១.មន្ត្រីនគរបាលយុត្តិធម៌

##### ក.ការទទួលបាននីតិសម្បទាតាមរយៈតួនាទី

កាលណាមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ឬកងរាជអាវុធហត្ថ នៃក្រសួងការពារជាតិ ដែលមានឋានន្តរស័ក្តិ និងមុខងារ (តួនាទី) ប្រកបដោយគុណសម្បត្តិអាចក្លាយជាមន្ត្រីនគរបាលយុត្តិធម៌បានតាមរយៈតួនាទីរបស់ខ្លួនរួមមាន៖

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង (បច្ចុប្បន្នរាជធានី/ខេត្ត), អភិបាល និងអភិបាលរង ស្រុក ខណ្ឌ (បច្ចុប្បន្នមានក្រុង/ស្រុក/ខណ្ឌ) និងមេឃុំ ចៅសង្កាត់

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌, ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃក្រសួងមហាផ្ទៃ

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក (ក្រោមឱវាទក្រសួងមហាផ្ទៃ) នៃ:

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភ័ណ្ឌ

ង. ស្នងការ ស្នងការរង នគរបាលខេត្ត ក្រុង (បច្ចុប្បន្នស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត)

[15] មាត្រា៥៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ច. ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌ ចំណុះស្នងការនគរបាលខេត្ត ក្រុង (បច្ចុប្បន្នស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត) ដូចជា:

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ (ផ្នែកកោសលវិច័យ)
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាល័យជនបរទេស

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ (បច្ចុប្បន្នមានក្រុង/ស្រុក/ខណ្ឌ)

ជ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរណ៍, ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរណ៍ "ចំពោះបទល្មើសចរាចរណ៍" ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែក នៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ"។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ

ឈ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"

ញ. មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ (បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស) ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ នៃក្រសួងការពារជាតិ

ដ. មេបញ្ជាការ និងមេបញ្ជាការរង កងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ (បច្ចុប្បន្នបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី/ខេត្ត) នៃក្រសួងការពារជាតិ

ឋ. មេបញ្ជាការ និងមេបញ្ជាការរង កងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ (បច្ចុប្បន្នមានមូលដ្ឋានកងរាជអាវុធហត្ថក្រុង/ស្រុក/ខណ្ឌ) នៃក្រសួងការពារជាតិ

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក នៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ នៃក្រសួងការពារជាតិ

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

ដោយរដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាលជាតិ(រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ) ឬរដ្ឋមន្ត្រីជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ(រដ្ឋមន្ត្រីក្រសួងការពារជាតិ) ដែលមានចែងនៅក្នុងចំណុចខាងលើ មានភារកិច្ចតែងតាំងមន្ត្រីនគរបាលជាតិ និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដោយចេញប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (ប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌)។[16] សម្រាប់ទិដ្ឋភាពនៃការអនុវត្តជាក់ស្តែងបច្ចុប្បន្នរដ្ឋមន្ត្រីដែលជាអាណាព្យាបាលជាអ្នករៀបចំបញ្ជីឈ្មោះរបស់មន្ត្រីនគរបាលជាតិ ឬនាយទាហាននៃកងរាជអាវុធហត្ថដែលមានគុណសម្បត្តិគ្រប់គ្រាន់មានគោលបំណងស្នើសុំផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានាដែលមានលទ្ធភាពក្នុងការស្នើសុំនីតិសម្បទា ហើយបញ្ជូនមកក្រសួងយុត្តិធម៌ក្នុងការពិនិត្យ និងសម្រេច (ដែលមាននាយកដ្ឋានកិច្ចការយុត្តិធម៌ព្រហ្មទណ្ឌ និងនគរបាលយុត្តិធម៌ នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ជាសេនាធិការលើកិច្ចការងារនេះ)។

## ខ.ការទទួលបាននីតិសម្បទាតាមរយៈការប្រលងជាមុន

កាលណាបើមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ឬកងរាជអាវុធហត្ថ នៃក្រសួងការពារជាតិ មិនមាននូវគុណសម្បត្តិក្នុងការទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌តាមរយៈតួនាទីរបស់ខ្លួនដូចមានបកស្រាយខាងលើទេ ពួកគេអាចទទួលបាននីតិសម្បទាតាមរយៈការមាននូវសញ្ញាបត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌បាន។ ជាលក្ខខណ្ឌយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអាចទទួលបានសញ្ញាបត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌បានត្រូវឆ្លងកាត់នីតិវិធីនៃការប្រលងជាមុន។

**វិញ្ញាសាប្រលង** ដើម្បីបានសញ្ញាបត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវផ្តល់ជូនបន្ទាប់ពីឆ្លងកាត់ការប្រលងបែបវិជ្ជាជីវៈដែលរួមមានវិញ្ញាសាជាមូលដ្ឋានដែលមានចំនួន ៣ (បី) គឺ៖

១-វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ

២-វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ

៣-វិញ្ញាសាស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលបានតាក់តែងដោយអង្គការសហប្រជាជាតិ។[17]

[16] មាត្រា៦០ ចំណុចទី៣ និងកថាខណ្ឌចុងក្រោយ, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[17] មាត្រា៦១ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ក្នុងនោះដែរដើម្បីធានាដល់ការប្រលងខាងលើ សមាសភាពគណៈមេប្រយោគនៃការប្រលង គឺស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬតំណាងមហាអយ្យការអមតុលាការកំពូលជាតំណាង។ ហើយសមាសភាពនៃគណៈមេប្រយោគដែលទាក់ទងនឹងមន្ត្រីនគរបាលជាតិ ឬយោធិននៃកងរាជអាវុធហត្ថមានដូចជា៖

១.ទាក់ទងនឹងមន្ត្រីនៃនគរបាលជាតិ (ចំណុះឱ្យក្រសួងមហាផ្ទៃ) គណៈមេប្រយោគមានសមាសភាពដូចតទៅ៖

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប របស់ក្រសួងមហាផ្ទៃ។

២.ទាក់ទងនឹងយោធិន នៃកងរាជអាវុធហត្ថ (ចំណុះឱ្យក្រសួងការពារជាតិ) គណៈមេប្រយោគមានសមាសភាពដូចតទៅ៖

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប មកពីក្រសួងការពារជាតិ។[18]

ក្រោយមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ឬកងរាជអាវុធហត្ថ នៃក្រសួងការពារជាតិ បានប្រលងជាប់ជាស្ថាពរដើម្បីទទួលសញ្ញាបត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌នេះហើយ ការចេញសញ្ញាបត្រជូនសាមីខ្លួនត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ) និងមានបោះត្រាក្រសួងសាមីជាមួយផង។[19]

កាលបើមាននូវសញ្ញាបត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ហើយ នោះសាមីខ្លួនមិនទាន់ក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌ភ្លាមនោះទេ។ ពួកគេអាចមានលទ្ធភាពក្នុងការទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌បានតាមរយៈការចេញប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ ក្រោយពីត្រូវបានបំពេញលក្ខខណ្ឌជាមុនដូចជា៖

- មន្ត្រីនគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រី (សក្តិ១) ឡើងទៅហើយគាត់បានបម្រើការងារយ៉ាងតិចបំផុតរយៈពេល ២ (ពីរ) ឆ្នាំ ឱ្យនគរបាលជាតិរួចហើយ បន្ទាប់ពីពេលដែលបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

[18] មាត្រា៦២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[19] មាត្រា៦១ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- នាយទាហាននៃកងរាជអាវុធហត្ថ ចំណុះក្រសួងការពារជាតិ (មិនកំណត់ឋានន្តរសក្តិ) ហើយគាត់បានបម្រើការងារយ៉ាងតិចបំផុតរយៈពេល ២ (ពីរ) ឆ្នាំ នៅក្នុងកងរាជអាវុធហត្ថរួចហើយ បន្ទាប់ពីពេលបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។[20]

## គ.ការទទួលបាននីតិសម្បទាដោយស្វ័យប្រវត្តិ

ក្រៅពីវិធីទាំងពីរខាងលើនៃការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ក៏អាចទទួលបានដោយស្វ័យប្រវត្តិផងដែរ។ ចំពោះចំណុចនេះមានន័យថាកងកម្លាំងនៃនគរបាលជាតិ ឬកងរាជអាវុធហត្ថទាំងឡាយណាដែលបានបំពេញនូវលក្ខខណ្ឌមុនក្រមនីតិវិធីព្រហ្មទណ្ឌចូលជាធរមាន នោះនឹងមានការផ្តល់ជូននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ កាលបើ ៖

- នាយនគរបាលជាតិ សំដៅទៅលើនាយនគរបាលជាតិដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្តីពីមន្ត្រីនគរបាលយុត្តិធម៌មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌចូលជាធរមាន ដែលត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ហើយនឹងត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។
- នាយទាហាន នៃកងរាជអាវុធហត្ថ សំដៅទៅលើនាយទាហាននៃកងរាជអាវុធហត្ថ ដែលមានវិញ្ញាបនបត្រនៃមន្ត្រីប៉ូលីសតុលាការ មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមរបស់ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌។[21]

**ការធ្វើសម្បថនៃមន្ត្រីនគរបាលយុត្តិធម៌** ៖ ក្រោយទទួលបាននីតិសម្បទាដែលត្រូវបានផ្តល់ឱ្យពីសំណាក់ក្រសួងយុត្តិធម៌ជាមួយក្រសួងពាក់ព័ន្ធរួច តាមរយៈតួនាទី តាមរយៈការប្រលងជាមុន ឬការទទួលបាននីតិសម្បទាដោយស្វ័យប្រវត្តិក្តី សាមីខ្លួនពុំទាន់មាននីតិសម្បទាភ្លាមៗឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗត្រូវធ្វើនីតិវិធីសម្បថ ដោយត្រូវស្បថថាខ្លួននឹងបំពេញតួនាទីដោយភក្តីភាពនូវមុខងាររបស់ខ្លួន។ សម្បថនេះត្រូវធ្វើនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ ឬសាលាឧទ្ធរណ៍តំបន់ដែលមានសមត្ថកិច្ចខាងដែនដី។ នីតិវិធីសម្បថខាងលើក៏មានចំណុចអញ្ញាត្តកម្មដោយមិនចាំបាច់ធ្វើសម្បថសាជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[22]

[20] មាត្រា៦០ ចំណុចទី១ និងទី២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[21] មាត្រា៦០៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[22] មាត្រា៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ១.២.១.២.ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌សំដៅដល់ មន្ត្រីជាជំនួយដល់នគរបាលយុត្តិធម៌ក្នុងការពិនិត្យនូវបទល្មើសខាងព្រហ្មទណ្ឌ(ពិសេសបទលហុ) ហើយការពិនិត្យនេះត្រូវធ្វើរបាយការណ៍ផងដែរបើទោះបីជាមានតម្លៃត្រឹមជាព័ត៌មានក៏ដោយ។[23] ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ដល់៖

- នាយនគរបាល ឬនាយនគរបាលរង(គ្រប់ឋានន្តរសក្តិទាំងអស់) ដែលមិនមាននូវគុណសម្បត្តិគ្រប់គ្រាន់ជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលជាតិដទៃទៀត នៃក្រសួងមហាផ្ទៃ
- នាយទាហាននៃកងរាជអាវុធហត្ថដែលមិនមាននូវគុណសម្បត្តិគ្រប់គ្រាន់ជាមន្ត្រីនគរបាលយុត្តិធម៌ និងយោធិនផ្សេងទៀត(គ្រប់ឋានន្តរសក្តិទាំងអស់) នៃកងរាជអាវុធហត្ថ របស់ក្រសួងការពារជាតិ។[24]

**ការធ្វើសម្បថនៃភ្នាក់ងារនគរបាលយុត្តិធម៌** ៖ មិនខុសគ្នាឆ្ងាយពីមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើនីតិវិធីសម្បថដូចគ្នា ដែលស្បថថាខ្លួននឹងបំពេញមុខងារដោយភាពស្មោះត្រង់ ប៉ុន្តែនីតិវិធីនេះត្រូវធ្វើឡើងនៅចំពោះមុខសាលាដំបូងរាជធានី/ខេត្ត ដែលមានសមត្ថកិច្ចខាងដែនដី។ សាមីភ្នាក់ងារនគរបាលយុត្តិធម៌ដែលធ្លាប់ស្បថរួចមកហើយ ពុំចាំបាច់ក្នុងការស្បថម្តងទៀតនោះឡើយ។ រូបមន្តនៃសម្បថទាំងនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[25] ជាវិធានកំណត់យ៉ាងជាក់លាក់ដោយក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ៧៨ កថាខណ្ឌទី៣ ដែលបញ្ញត្តិ លើភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងករណីណាក៏ដោយពុំអាចមានលទ្ធភាពបំពេញកិច្ចទាំងឡាយដែលកំណត់សម្រាប់តែមន្ត្រីនគរបាលយុត្តិធម៌សម្រាប់អនុវត្តប៉ុណ្ណោះ កាលបើមានការអនុវត្តន៍បំពាននឹងនាំឱ្យមោឃភាពនៃកិច្ចនីតិវិធីទាំងនោះ។

### ១.២.១.៣.មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន

នីតិសម្បទាអាចផ្តល់ជូនដល់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកក្នុងវិស័យរបស់ខ្លួនបានប្រគល់អំណាចឱ្យពិនិត្យបទល្មើសដោយច្បាប់កំណត់ដោយត្រូវតែដាក់ឱ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះដែរ។ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចតាមផ្លូវច្បាប់ដើម្បីដឹកនាំការអនុវត្តនីតិវិធីទាំងឡាយនៃមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដែលបានទទួលនីតិសម្បទាដើម្បីធានាឱ្យបានប្រតិបត្តិការនីតិវិធីមានភាពស្របតាមច្បាប់។ ច្បាប់ដោយឡែកដែលបានបញ្ញត្តិអំពីការ

---

[23] មាត្រា៧៨ កថាខណ្ឌទី១ និងទី២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[24] មាត្រា៧៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[25] មាត្រា៧៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

មានលទ្ធភាពដើម្បីទទួលនីតិសម្បទា រួមមានជាច្រើនស្ទើរគ្រប់វិស័យនានានៃរដ្ឋបាលសាធារណៈ ក្នុងប្រទេសកម្ពុជា ជាអាទិ៍រួមមាន៖

- ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ (អង្គភាពប្រឆាំងអំពើពុករលួយ)
- ច្បាប់ស្តីពីគយ, ច្បាប់ស្តីពីសារពើពន្ធ, ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ច្បាប់ស្តីពីការធានារ៉ាប់រង... (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
- ច្បាប់ស្តីពីសំណង់ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ក្រសួងកិច្ចការនារី)
- ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត (ក្រសួងរ៉ែ និងថាមពល)
- ច្បាប់ស្តីពីទូរគមនាគមន៍ (ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)
- ច្បាប់ស្តីពីផ្លូវថ្នល់ (ក្រសួងសាធារណៈការនិងដឹកជញ្ជូន ឬក្រសួងអភិវឌ្ឍន៍ជនបទ)
- ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត (ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (ក្រសួងបរិស្ថាន)
- ច្បាប់ស្តីពីព្រៃឈើ, ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម... (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
- ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា (ក្រសួងពាណិជ្ជកម្ម)
- ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ (ក្រសួងសុខាភិបាល)
- ច្បាប់ស្តីពីទេសចរណ៍ (ក្រសួងទេសចរណ៍) ។ល។

**ការធ្វើសម្បថនៃមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន** ៖ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ក្រោយពីទទួលបាននីតិសម្បទាតាមរយៈប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទារួចហើយ សាមីខ្លួនពុំទាន់មាននីតិសម្បទាភ្លាមៗឡើយ។ សាមីខ្លួនត្រូវធ្វើសម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូងដែលមានសមត្ថកិច្ចខាងដែនដីដោយស្បថថាបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ សម្រាប់រូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ ចំពោះការពិនិត្យបទល្មើសនានា មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះត្រូវធ្វើរបាយការណ៍។ សម្រាប់របាយការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ។[26]

[26] មាត្រា៨២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ១.២.២.បេសកកម្មនគរបាលយុត្តិធម៌

បេសកកម្មរបស់នគរបាលយុត្តិធម៌ គឺជាជំនួយដល់អំណាចតុលាការដែលជាអង្គឯករាជ្យ។ ដូច្នេះអាចកំណត់បានថានគរបាលយុត្តិធម៌អាចបំពេញភារកិច្ចរបស់ខ្លួនគ្រប់ដំណាក់កាលនានានៃនីតិវិធីព្រហ្មទណ្ឌតាមរយៈការមានតម្រូវការពីអំណាចតុលាការចាប់តាំងពីដំណាក់កាលដំបូងដល់បញ្ចប់។ នគរបាលយុត្តិធម៌មានភារកិច្ចត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណផ្សេងៗ ចាប់ជនល្មើស និងប្រមូលភស្តុតាងពាក់ព័ន្ធដើម្បីដំណើរការនីតិវិធី។[27]

ជាគោលការណ៍នគរបាលយុត្តិធម៌ មានតួនាទីបង្ការ រក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានបទល្មើសណាមួយកើតឡើងក្នុងសង្គម និងបង្ក្រាបបទល្មើសដែលបណ្តាលឱ្យប៉ះពាល់បង្កភាពរឹករវដល់សង្គមដែលធ្វើឱ្យអសន្តិសុខសង្គម។ ដោយនគរបាលយុត្តិធម៌ជាអ្នកបម្រើសេវាយុត្តិធម៌ដោយផ្ទាល់ដែលស្ថិតនៅជិតប្រជាពលរដ្ឋបំផុតនៃដែនរដ្ឋបាលមូលដ្ឋានរបស់ខ្លួន។ ដូចនេះហើយរាល់ពេលដែលមានបទល្មើសកើតឡើងនគរបាលយុត្តិធម៌មានបេសកកម្មចុះទៅបង្ក្រាបបទល្មើសនោះភ្លាមៗ និងរហ័សបំផុត។ ចំពោះបទល្មើសនគរបាលយុត្តិធម៌ត្រូវធ្វើការឃាត់ខ្លួនជនសង្ស័យ ជៀសវាងការបង្ករគ្រោះថ្នាក់បន្ថែមទៀត។

ចំពោះបេសកកម្មចម្បងរបស់មន្ត្រីនគរបាលយុត្តិធម៌សំខាន់ៗមាន ៣ (បី) ចំណុចះ

- ការត្រួតពិនិត្យបទល្មើស
- ការទទួលពាក្យបណ្តឹង
- ការស៊ើបអង្កេត។[28]

**ការពិនិត្យបទល្មើស** នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ឃើញមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង គាត់មានសិទ្ធិធ្វើកិច្ចការនេះដោយខ្លួនឯង ទោះបីគ្មានអ្នកប្តឹងក៏ដោយលើកលែងតែមានបទល្មើសមួយចំនួនប៉ុណ្ណោះ ដូចជាបទបរិហារកេរ្តិ៍ជាសាធារណៈ បទជេរប្រមាថជាសាធារណៈ ព្រមទាំងបទហិង្សាក្នុងគ្រួសារដែលត្រូវការទទួលពាក្យបណ្តឹងជាមុន។

**ការទទួលពាក្យបណ្តឹង** មន្ត្រីនគរបាលយុត្តិធម៌អាចទទួលពាក្យបណ្តឹងរឿងក្តីព្រហ្មទណ្ឌបានចំណែករឿងក្តីរដ្ឋប្បវេណីមិនអាចទទួលបាននោះទេ ហើយនៅក្នុងបណ្តឹងរឿងក្តីព្រហ្មទណ្ឌរួមមានបណ្តឹងទាមទារ និងបណ្តឹងបរិហារ។ បណ្តឹងទាមទារ គឺជាបណ្តឹងដែលធ្វើឡើងដោយជនរងគ្រោះប្តឹងទៅសមត្ថកិច្ច (មន្ត្រីនគរបាលយុត្តិធម៌) ឱ្យជួយដោះស្រាយនូវសំណងនៃការខូចខាត សំណងជំងឺចិត្ត និងផ្តន្ទាទោសតាមផ្លូវច្បាប់។ បណ្តឹងបរិហារ គឺជាបណ្តឹងដែលធ្វើឡើងដោយតតិយជន មន្ត្រីសាធារណៈ ឬភ្នាក់ងារនគរបាលយុត្តិធម៌ដែលប្តឹងទៅ

---

[27] មាត្រា៥៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[28] មាត្រា៧១, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

សមត្ថកិច្ចដើម្បីស្វែងរកភស្តុតាង និងឈានទៅដល់ការស្រាវជ្រាវចាប់ជនល្មើសមកផ្តន្ទាទោស ដោយនីតិវិធីនៃការទទួលពាក្យបណ្តឹងនៅពេលទទួលពាក្យបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុទទួលពាក្យបណ្តឹងដែលមានបញ្ជាក់អត្តសញ្ញាណរបស់អ្នកប្តឹង កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹងអំពីអំពើល្មើស និងឈ្មោះឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងអង្គភាពហើយត្រូវស្រង់ឱ្យបានត្រឹមត្រូវចំពោះសេចក្តីរាយការណ៍របស់អ្នកប្តឹង។ ក្នុងករណីដែលអ្នកប្តឹងពុំចេះភាសាខ្មែរ ត្រូវរកអ្នកបកប្រែម្នាក់ដែលមិនពាក់ព័ន្ធក្នុងអង្គហេតុដោយតម្រូវឱ្យធ្វើសម្បថតាមជំនឿ ឬសាសនា ជាមុនថាខ្លួននឹងបកប្រែនូវសេចក្តីត្រឹមត្រូវ។ ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្តឹង។ ការឆូតលុប ការសរសេរចំណុចថែមណាមួយត្រូវតែមានការបញ្ជាក់ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹងនៅរឹមទំព័រ។ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ អ្នកប្តឹងត្រូវអានកំណត់ហេតុឡើងវិញឱ្យបានច្បាស់លាស់។ ក្នុងករណីអ្នកប្តឹងមិនចេះអក្សរមន្ត្រីនគរបាលយុត្តិធម៌ត្រូវអាននូវខ្លឹមសារកំណត់ហេតុដោយសំលេងខ្លាំងៗ។[29]

**ចំណាត់ការលើពាក្យបណ្តឹង** ក្រោយពីបានទទួលពាក្យបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែចាត់ការភ្លាមៗ គឺធ្វើការស៊ើបអង្កេតដោយខ្លួនឯង ឬក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការ។ មុននឹងធ្វើការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា។[30] ប៉ុន្តែកាលណាទទួលពាក្យបណ្តឹងពីបទឧក្រិដ្ឋ ឬបណ្តឹងបរិហារដែលអាចសន្និដ្ឋានថាមានបទល្មើសមន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ។ ទោះក្នុងករណីណាក៏ដោយមន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស ជាមួយជនរងគ្រោះហើយក៏ដោយ ឬក៏មានការដកពាក្យបណ្តឹងក៏ដោយ[31] ព្រោះជាគោលការណ៍បណ្តឹងអាជ្ញាមិនអាចរលត់ដោយសារការសម្រុះសម្រួល ឬការដកពាក្យបណ្តឹងបានឡើយ លើកលែងតែបទល្មើសមួយចំនួនប៉ុណ្ណោះដូចជា អំពើហិង្សាក្នុងគ្រួសារ និងឯកពន្ធភាពជាដើម។

**ការស៊ើបអង្កេត** ដំណាក់កាលស៊ើបអង្កេត ជាដំណាក់កាលមួយដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ក្រោមការត្រួតពិនិត្យ និងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា។ ជាគោលការណ៍ ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់។ បុគ្គលទាំងឡាយ ដែលបានចូលរួមក្នុងការស៊ើបអង្កេត ជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យផ្នែកបច្ចេកទេសឬវិទ្យាសាស្ត្រ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវរក្សាការសម្ងាត់

[29] មាត្រា៧២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[30] មាត្រា៧៤, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[31] មាត្រា៧៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

នៃវិជ្ជាជីវៈ។ ប៉ុន្តែការគោរពការសម្ងាត់នៃវិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។ ម៉្យាងវិញទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត។ ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើស ដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[32]

**១.២.៣.បញ្ជីនៃបណ្តឹង**

នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីបណ្តឹងមួយសម្រាប់ចុះនូវនិទ្ទេសពាក្យបណ្តឹងដូចតទៅ៖

- អត្តសញ្ញាណរបស់អ្នកប្តឹង
- កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង
- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹង
- ប្រភេទនៃអំពើដែលប្តឹង (អង្គហេតុកើតមានឡើង)
- ចំណាត់ការលើពាក្យបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេតដោយខ្លួនឯង។

ដោយបញ្ជីនៃបណ្តឹងនេះត្រូវតែមានជានិច្ច ព្រមទាំងរក្សាទុកជាអចិន្ត្រៃយ៍សម្រាប់ជូនដល់អាជ្ញាធរតុលាការកាលបើមានតម្រូវការ។[33]

---

[32] មាត្រា៨៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[33] មាត្រា៧៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# ជំពូកទី២

# អំណាចរបស់ព្រះរាជអាជ្ញា ដឹកនាំនីតិវិធីស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី២

# អំណាចរបស់ព្រះរាជអាជ្ញាដឹកនាំនីតិវិធីស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌

## ២.១.ការស៊ើបអង្កេតជាក់ស្តែង

ការស៊ើបអង្កេតជាក់ស្តែងជាវិធាននៃការស៊ើបអង្កេតលើភាពបន្ទាន់ដែលតម្រូវឱ្យមានការប្រមូលនូវភស្តុតាងនៃបទល្មើសដែលនៅមាននៅឡើយដែលទើបត្រូវបានប្រព្រឹត្តថ្មីៗដើម្បីឆ្លើយតបនឹងភាពរហ័សចាំបាច់។ វិធាននៃការស៊ើបអង្កេតជាក់ស្តែងនេះបង្កើតអំណាចយ៉ាងធំធេងដល់មន្ត្រីនគរបាលយុត្តិធម៌។ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង គឺជាដំណាក់កាលដែលពុំអាចឱ្យវេលាណាមួយត្រូវបានបាត់បង់ឡើយ ការយឺតយ៉ាវតែបន្តិចអាចជាមូលហេតុនៃការបាត់នូវតម្រុយនានានៃបទល្មើស។ ជាមួយគ្នានេះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានដាក់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងក្របខណ្ឌនៃការស៊ើបអង្កេតនេះ។

### ២.១.១.លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង

ជាលក្ខខណ្ឌដែលមានប្បញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីបើកការស៊ើបអង្កេតករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែងបានគឺតម្រូវឱ្យបទល្មើសនោះត្រូវស្ថិតក្នុងចំណាត់ថ្នាក់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែលក្នុងករណី៖

- បទល្មើសដែលកំពុងតែប្រព្រឹត្ត
- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។

មិនត្រឹមតែប៉ុណ្ណោះត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដែរកាលបើក្រោយពេលមានការប្រព្រឹត្តបទល្មើសរួចបន្តិចមក ហើយ ៖

- ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស ត្រូវបានសាធារណៈជនដេញប្រដាប់ចាប់ប្រកីង
- បុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុតាង ស្លាកស្នាម តម្រុយច្បាស់លាស់ ដែលមានការស៊ីចង្វាក់គ្នាជាហេតុនាំឱ្យគេអាចសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្តដោយផ្ទាល់ ឬបានចូលរួមក្នុងការប្រព្រឹត្តនូវបទល្មើស។[34]

លើសពីនេះក្រៅអំពីការរៀបរាប់ខាងលើ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់ទីនោះ បានស្នើសុំទៅដល់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌(ករណីគ្មានវត្តមានមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវរាយការណ៍ភ្លាមដល់មន្ត្រីនគរបាលយុត្តិធម៌) ក៏ត្រូវចាត់ថាជាបទល្មើសជាក់ស្តែងដែរ។[35] បន្ថែមពីនេះទៀត មិនត្រឹមតែនគរបាលយុត្តិធម៌ ឬអាជ្ញាធរ

---

[34] មាត្រា៨៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[35] មាត្រា៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

មានសមត្ថកិច្ចនោះទេដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការចាប់ខ្លួនបុគ្គលដែលបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តក្នុងករណីនេះ ពោលគឺបុគ្គលគ្រប់រូបទាំងអស់ (មិនថាប្រជាពលរដ្ឋ ឬជនស៊ីវិលក្តី) អាចចូលរួមក្នុងការចាប់ខ្លួនជនល្មើស បន្ទាប់មកត្រូវនាំខ្លួនជននោះដើម្បីប្រគល់ជូនទៅមន្ត្រីនគរបាលយុត្តិធម៌ណាមួយដែលនៅជិតបំផុត។[36]

ត្រង់ចំណុចនេះព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដី (ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី/ខេត្ត) អាចចូលរួមដោយផ្ទាល់ ឬចាត់ឱ្យព្រះរាជអាជ្ញារង ដើម្បីដឹកនាំសម្របសម្រួលក្នុងនីតិវិធីស៊ើបអង្កេតជាក់ស្តែងបានដែលប្រតិបត្តិការជាមួយមន្ត្រីនគរបាលយុត្តិធម៌។

### ២.១.២.ដំណើរការនៃការស៊ើបអង្កេតជាក់ស្តែង

ក្រោយសន្មតបានថាអ្វីទៅជាបទល្មើសជាក់ស្តែងរួចហើយ ដំណើរការស៊ើបអង្កេតត្រូវប្រព្រឹត្តឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាគោល ចិរវេលានៃការស៊ើបអង្កេតនេះអាចប្រតិបត្តិការទៅបានមិនឱ្យលើសពី ៧ (ប្រាំពីរ) ថ្ងៃ ដោយគិតពីថ្ងៃដែលបានប្រព្រឹត្តបទល្មើស ដោយដំណើរការនៃការស៊ើបអង្កេតមួយនេះត្រូវប្រតិបត្តិការជាប់ជានិច្ចក្នុងចិរវេលាខាងលើ។[37] ករណីការស៊ើបអង្កេតលើសពីរយៈពេលនេះនឹងនាំឱ្យមានមោឃភាពចោលនៃនីតិវិធី។[38] ប៉ុន្តែប្រសិនបើការស៊ើបអង្កេតមិនត្រូវបានបញ្ចប់ត្រឹមរយៈពេលខាងលើទេនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំយោបល់ទៅព្រះរាជអាជ្ញាថាតើមានចំណាត់ការណាមួយបន្តទៀតដូចជា បន្តការស៊ើបអង្កេតក្នុងបរិបទនៃស៊ើបអង្កេតករណីបឋម ជាដើម។[39]

ក្រោយបញ្ចប់ការស៊ើបអង្កេតជាក់ស្តែងរួចហើយ កំណត់ហេតុនានា និងភស្តុតាងត្រូវបន្តនីតិវិធីបញ្ជូនទៅព្រះរាជអាជ្ញាជាអ្នកមុខការបន្តក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ។ បរិបថនេះពេលវេលានៃការស៊ើបអង្កេតជាក់ស្តែង ជាកត្តាសំខាន់បំផុតសម្រាប់បម្រើឱ្យនីតិវិធីនេះអនុវត្តទៅបានដោយស្របតាមច្បាប់ ព្រោះភស្តុតាងអាចត្រូវបានបាត់ដានដោយសកម្មភាពចេតនា ឬអចេតនាណាមួយ ដែលជាការចាំបាច់ដែលមន្ត្រីនគរបាលយុត្តិធម៌គប្បីធ្វើប្រតិបត្តិការស៊ើបអង្កេតឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ធានាដល់ភាពស្របតាមច្បាប់នៃការអនុវត្តរបស់ខ្លួន។

---

[36] មាត្រា៨៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[37] មាត្រា១០៦ វាក្យខណ្ឌទី១ និងទី២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[38] មាត្រា១០៩ ចំណុចទី១៣ , ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[39] ទំព័រទី២៥-២៦ នៃសៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និងលោក ខាន់ សុខា (ពុំមានបញ្ជាក់ឆ្នាំ)

ទិដ្ឋភាពក្នុងការអនុវត្តព្រះរាជអាជ្ញាអាចដឹកនាំក្នុងការប្រតិបត្តិការនីតិវិធីនៃការស៊ើបអង្កេតជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌បាន ពិសេសផ្តោតលើបទល្មើសព្រហ្មទណ្ឌដែលមានលក្ខខណៈទ្រង់ទ្រាយធំ ឬបទល្មើសមានលក្ខខណៈស្មុគស្មាញ ជាអាទិ៍។

**២.១.៣.ការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌**

ដើម្បីធានាទិសដៅនៃការស៊ើបអង្កេត ក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមតាមគ្រប់មធ្យោបាយជូនដល់ព្រះរាជអាជ្ញាឱ្យបានដឹង ហើយកាលណាព្រះរាជអាជ្ញាមានការយល់ឃើញថាមានប្រយោជន៍ ឬកាលៈទេសៈនៃបទល្មើសតម្រូវនោះព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងកើតហេតុនិងដឹកនាំការស៊ើបអង្កេតនោះ។ ឧទាហរណ៍.ករណីការចុះស៊ើបអង្កេតបទល្មើសគ្រឿងញៀនលក្ខណៈទ្រង់ទ្រាយធំដែលតម្រូវឱ្យមានការដឹកនាំ និងសម្របសម្រួលនីតិវិធីពីសំណាក់ព្រះរាជអាជ្ញា ដើម្បីធានាភាពដំណើរការទៅបាននៃប្រតិបត្តិការស្រាវជ្រាវមួយដែលស្របនឹងនីតិវិធីច្បាប់ជាធរមាន។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះផ្ទាល់ទៅទីកន្លែងប្រព្រឹត្តបទល្មើស រ៉ាប់រងរក្សាទុកតម្រុយនៃភស្តុតាងទាំងអស់ដែលអាចនឹងបាត់បង់ ហើយអាចហាមឃាត់មិនបុគ្គលឱ្យគ្រប់រូបមិនឱ្យទៅណាឆ្ងាយពីកន្លែងប្រព្រឹត្តបទល្មើសរហូតដល់ពេលបញ្ចប់ប្រតិបត្តិការនៃការស៊ើបអង្កេត។[40] ករណីបន្ទាន់នៃការស្រាវជ្រាវព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការពន្លាតសមត្ថកិច្ចដែនដីលើវិសាលភាពនៃដែនដីជាតិទាំងមូលដោយអាចអនុញ្ញាតតាមរយៈផ្ទាល់មាត់ក៏បានតែត្រូវចុះនិទ្ទេសនៃលិខិតស៊ើបអង្កេត។ កាលបើមានការប្រតិបត្តិការក្នុងទំហំពន្លាតសមត្ថកិច្ចដែនដី នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំកិច្ចសហការពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។[41] ឧទាហរណ៍.នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ មានបទល្មើសឧក្រិដ្ឋជាក់ស្តែងមួយ "បទឃាតកម្ម" ប្រព្រឹត្តឡើងដោយលោក ក នៅចំណុចបណ្តោយផ្លូវមាត់ទន្លេ នៃសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បាញ់សម្លាប់លោក ខ ហើយជនសង្ស័យបានរត់គេចខ្លួនទៅដល់ខេត្តកំពង់ឆ្នាំង។ ករណីនេះព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ពន្លាតសមត្ថកិច្ចដែនដីដើម្បីបង្ក្រាបបទល្មើសដោយសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌មូលដ្ឋានដែលមានសមត្ថកិច្ចខាងដែនដីនោះ។

**ការឆែកឆេរ** ការឆែកឆេរលំនៅដ្ឋាន សម្ភារៈវត្ថុ និងលើខ្លួនបុគ្គល ត្រូវធ្វើឡើងដោយស្របនឹងបញ្ញត្តិនៃច្បាប់។[42] ព្រះរាជអាជ្ញាជាអ្នកមានសមត្ថកិច្ចក្នុងការអនុញ្ញាត(ទោះការអនុញ្ញាតផ្ទាល់មាត់ក្តី) ដើម្បីមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរអាចធ្វើបាន។ ការឆែកឆេរនៅទីកន្លែងណាមួយត្រូវប្រតិបត្តិដោយផ្ទាល់នៅ

[40] មាត្រា៨៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[41] មាត្រា៦៨ កថាខណ្ឌទី១ និងទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[42] មាត្រា៤០, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

ចំពោះមុខអ្នកកាន់កាប់ទីកន្លែង ករណីមិនមានអ្នកកាន់កាប់ទីកន្លែងនោះទេ អាចជំនួសដោយការសង្កេតពីសាក្សី ២ រូប (ចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ បុគ្គលជាសាក្សីនេះមិនអាចជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានវត្តមានចូលរួមស្រាប់ក្នុងប្រតិបត្តិការឡើយ)។ សូមបញ្ជាក់ថាដំណើរការនៃការឆែកឆេរនេះត្រូវធ្វើឡើងចាប់ពីម៉ោង ៦ ព្រឹក រហូតដល់ម៉ោង ១៨ ល្ងាច ជាលក្ខខណ្ឌគតិយុត្តិ។ ទោះជាយ៉ាងណាក្ដីករណីដែលជាអញ្ញត្រកម្មអាចអនុញ្ញាត្តិឱ្យការឆែកឆេរអាចធ្វើបានមិនកំណត់ចិរវេលា (២៤ម៉ោងលើ២៤ម៉ោង) កាលណាបើមានករណីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្ដែង ឬក្នុងករណីដែលចាត់ទុកថាជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្ដែង, ករណីមានគេស្រែកឱ្យជួយពីក្នុងទីកន្លែង, ទីកន្លែងបើកចំហរដល់សាធារណៈជន (ឧទាហរណ៍.ភោជនីយដ្ឋាន ឬរង្គសាលពេលរាត្រី) និងទីន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ កិច្ចនីតិវិធីនេះត្រូវធ្វើកំណត់ហេតុនៅនឹងទីកន្លែងដែលបានឆែកឆេរនោះដោយមានបញ្ជាក់អំពីថ្ងៃ និងម៉ោងនៃការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ព្រមទាំងអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីដែលបានចូលរួមនោះ។

មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរបាននោះទេលើការិយាល័យមេធាវី ពោលករណីនេះមានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ដែលអាចប្រតិបត្តិការឆែកឆេរបានដោយមានការចូលរួមសង្កេតដោយប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមីនៃការិយាល័យនោះ។ ការកំណត់បែបនេះគឺ ដើម្បីចូលរួមការពារអំពីការសម្ងាត់នៃដំណើរការនីតិវិធីរបស់មេធាវីដើម្បីរកយុត្តិធម៌ជូនកូនក្ដីខ្លួន។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរនៅអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ សហគ្រាសនៃសារព័ត៌មានសោតទស្សន៍បាន ដោយត្រូវធ្វើឡើងនៅមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ដែលធានាឱ្យមានការអនុវត្តត្រឹមត្រូវស្របតាមច្បាប់ មិនប៉ះពាល់ដល់ការប្រកបដោយសេរីនូវរបបសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាន ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ៤១ ជាគោលផងដែរ។[43]

**ការចាប់យកវត្ថុតាង** មន្ត្រីនគរបាលយុត្តិធម៌ក្នុងប្រតិបត្តិការនៃការស្រាវជ្រាវ មានសិទ្ធិអំណាចទទួលបានតាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ អាចធ្វើការចាប់យកនូវរាល់វត្ថុតាងដែលពាក់ព័ន្ធនៃការប្រព្រឹត្តបទល្មើស។ ដោយការចាប់យកវត្ថុតាងត្រូវបិទស្លាក និងមានការបោះត្រានៅលើវត្ថុតាងនោះ ដែលត្រូវលើកបង្ហាញដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ហើយធ្វើកំណត់ហេតុដែលរួមមានបញ្ជីសារពើភ័ណ្ឌ (បញ្ជីរាយនាមសម្គាល់វត្ថុ)។ ដើម្បីធានាឱ្យបាននូវភាពច្បាស់លាស់ កំណត់ហេតុស្ដីពីការចាប់យកនេះត្រូវមានចុះហត្ថលេខា ឬផ្ដិតមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់។ ក្នុងទិដ្ឋភាពនៃការអនុវត្តជាក់ស្ដែងគឺនិយមលើការផ្ដិតមេដៃលើកំណត់ហេតុនេះ។[44]

[43] មាត្រា៩១, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[44] មាត្រា៩២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

**ការស្តាប់ចម្លើយជនសង្ស័យ ឬបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស** ក្នុងទិសដៅដើម្បីស្វែងរកការពិតនៃអង្គហេតុដែលបានកើតឡើង ជនសង្ស័យ ឬបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស អាចត្រូវបានហៅ និងនាំខ្លួន មកកាន់អង្គភាពនគរបាលយុត្តិធម៌ដើម្បីធ្វើការស្តាប់ចម្លើយដោយមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងកាលៈទេសៈដែលចាំបាច់រួមមាន ជនមានពិការភាព (គថ្លង់) ឬជនបរទេស មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែបាន ដែលត្រូវស្បថតាមសាសនាខ្លួនថាការផ្តល់ចម្លើយជាការពិត អ្នកបកប្រែនេះមិនអាចជ្រើសពីក្នុងមន្ត្រីនគរបាលយុត្តិធម៌ដែលទាក់ទិនក្នុងករណីនោះបានទេ។ ការស្តាប់ចម្លើយត្រូវមានការធ្វើកំណត់ហេតុជានិច្ច ក្រោយមន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុរួចបុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ (ក្នុងការចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសម្លេងខ្លាំងៗនូវខ្លឹមសារទាំងស្រុង) បន្ទាប់មករាល់ទំព័រនីមួយៗកំណត់ហេតុត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃគ្រប់បុគ្គលដែលបានឆ្លើយនោះ។ ករណីដែលបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេត្រូវចុះនិទ្ទេសសម្គាល់នៅក្នុងកំណត់ហេតុ។ ជាមួយគ្នានេះកំណត់ហេតុនេះត្រូវសរសេរដោយត្រឹមត្រូវតាមអំពីសេចក្តីដែលបានរាយការណ៍របស់បុគ្គលដែលបានផ្តល់ចម្លើយ។[45]

បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទដើម្បីបំភ្លឺ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនឹងការកោះហៅ មន្ត្រីនគរបាលអាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីឱ្យចេញដីកាបញ្ជាឱ្យចូលខ្លួន។ លក្ខខណ្ឌទម្រង់នៃដីកានេះត្រូវមាន បញ្ជាក់នូវអត្តសញ្ញាណជាក់លាក់របស់បុគ្គលដែលជាកម្មវត្ថុនៃការបញ្ជាឱ្យចូលខ្លួន ចុះកាលបរិច្ឆេទ ព្រមទាំងត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងបោះត្រារបស់ស្ថាប័នអយ្យការផងដែរ។ ដីកានេះមានអំណាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួនបាន។[46] បន្ថែមពីលើនេះករណីដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បានទេ មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញដែលមាននៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ បើអ្នកជំនាញពុំមានឈ្មោះស្ថិតនៅក្នុងបញ្ជីថ្នាក់ជាតិទេនោះ អ្នកជំនាញនោះត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួនប្តេជ្ញាថានឹងជួយដោយភក្តីភាពដល់តុលាការ។[47]

គួរបញ្ជាក់ថា រាល់កិច្ចនីតិវិធីទាំងអស់នៃវិធានស្រាវជ្រាវសម្រាប់ស៊ើបអង្កេតខាងលើ គឺតម្រូវឱ្យមានការធ្វើកំណត់ហេតុដែលសរសេរអំពីសកម្មភាពនៃការអនុវត្តវិធានស្រាវជ្រាវ ឬការពិនិត្យខ្លួន។

[45] មាត្រា៩៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[46] មាត្រា៩៤, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[47] មាត្រា៩៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.១.៤.ការឃាត់ខ្លួន

ការឃាត់ខ្លួនបុគ្គល ត្រូវបានការពារពីសំណាក់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣៩ កថាខណ្ឌទី២ ដែលចែងទាក់ទងនឹងការឃាត់ខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវស្របតាមបញ្ញត្តិច្បាប់ជាធរមាន។ ស្របគ្នាជាមួយនេះ ក្រមនីតិវិធីព្រហ្មទណ្ឌដើរតួនាទីជាលិខិតបទដ្ឋានគតិយុត្តមានសមត្ថកិច្ចក្នុងការអនុវត្តពាក់ព័ន្ធនឹងការឃាត់ខ្លួន។

ដើម្បីធានាដល់ការស្វែងរកយុត្តិធម៌នៃដំណើរការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែងដែលកើតឡើង មន្ត្រីនគរបាលយុត្តិធម៌មានអំណាចយ៉ាងពេញលេញក្នុងការឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស ឬបុគ្គលដែលអាចដើរតួក្នុងការផ្តល់ព័ត៌មានស្តីពីរឿងហេតុនោះកាលបើបុគ្គលនោះបដិសេធក្នុងការមិនព្រមផ្តល់នូវព័ត៌មានដែលខ្លួនបានដឹង។

មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចរាយការណ៍ភ្លាមៗជូនដល់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមនៃនីតិវិធីស្ថិតក្នុងដំណាក់កាលនគរបាលយុត្តិធម៌របស់ខ្លួន ដោយមានយោងភស្តុតាងទាំងអស់ដែលបញ្ជាក់ពីភាពចាំបាច់នៃការឃាត់ខ្លួន។

ចិរវេលាអនុញ្ញាតដល់ការឃាត់ខ្លួនមានរយៈពេល ៤៨ ម៉ោង គិតចាប់ពីជនដែលត្រូវបានឃាត់ខ្លួននោះមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ត្បិតមានបទប្បញ្ញត្តិនៃរយៈពេលឃាត់ខ្លួនខាងលើក្តី ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យមានការពន្យារពេលនៃការឃាត់ខ្លួនបន្ថែមមិនឱ្យលើសពីរយៈពេល ២៤ ម៉ោង បន្ថែមទៀត (ដោយមិនគិតពីរយៈពេលក្នុងការដឹកជញ្ជូន) កាលបើមានលក្ខខណ្ឌដូចជា៖

- បុគ្គលឃាត់ខ្លួនជានីតិជន សម្រាប់បទល្មើសឧក្រិដ្ឋជាក់ស្តែង
- ធ្វើឡើងជាវិធានការពិសេសដែលអាចជាប្រយោជន៍ល្អដល់ការស៊ើបអង្កេត
- កាលបើមន្ត្រីនគរបាលយុត្តិធម៌ស្នើសុំទៅព្រះរាជអាជ្ញា ដើម្បីផ្ទៀងផ្ទាត់ពីភាពសមហេតុផល ហើយចេញលិខិតជាលាយលក្ខណ៍អក្សរអមជាមួយសម្អាងហេតុ។

សរុបជារួម ការឃាត់ខ្លួនបុគ្គលជានីតិជនករណីពាក់ព័ន្ធនឹងបទល្មើសឧក្រិដ្ឋជាក់ស្តែង បូកទាំងចិរវេលានៃការពន្យារពេលនៃការឃាត់ខ្លួន មិនអាចមានរយៈពេលលើសពី ៧២ ម៉ោង ( ៣ ថ្ងៃ) នោះឡើយ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនត្រូវបានធ្វើការឃាត់ខ្លួននោះឡើយ។ សម្រាប់បុគ្គលជាអនីតិជន (អាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ) អនុញ្ញាតឱ្យមានការឃាត់ខ្លួនអាចធ្វើឡើងបាន តែមិនអាចពន្យាពេលនៃការឃាត់ខ្លួនបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងស្តីពីការឃាត់ខ្លួនអនីតិជនដល់ឪពុកម្តាយ ឬអ្នកអាណាព្យាបាល។[48] ការឃាត់ខ្លួនអាចធ្វើឡើងបានកាលបើមានករណីដូចជា៖

[48] មាត្រា១០០, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

*សម្រាប់បទឧក្រិដ្ឋជាក់ស្តែង*

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ
- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ

*សម្រាប់បទមជ្ឈិមជាក់ស្តែង*

- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។[49]

ក្រោយរយៈពេលនៃការឃាត់ខ្លួនខាងលើកន្លងហួស ២៤ ម៉ោង គ្រប់បុគ្គលដែលត្រូវបានឃាត់ខ្លួន មានសិទ្ធិក្នុងការទទួលបានជំនួយពីមេធាវី ឬបុគ្គលណាម្នាក់ ដែលត្រូវបានជ្រើសរើសដោយបុគ្គលដែលគេឃាត់ខ្លួន (បុគ្គលដែលពុំជាប់ពាក់ព័ន្ធនឹងរឿងក្តី) អាចធ្វើការសន្ទនាជាមួយនឹងបុគ្គលដែលត្រូវបានគេឃាត់ខ្លួនក្នុងរយៈពេល ៣០ នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់។[50]

អំពីស្ថានភាពសុខភាពរបស់បុគ្គលដែលត្រូវបានឃាត់ខ្លួន ក៏ជាកត្តាចាំបាច់ដែរ ដោយព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅគ្រូពេទ្យឱ្យពិនិត្យបញ្ហាសុខភាពបានគ្រប់ពេលវេលា។ ទោះជាយ៉ាងណាក្តី បញ្ហាសុខភាពជាចំណុចសំខាន់ បើគ្រូពេទ្យពិនិត្យឃើញថាស្ថានភាពសុខភាពរបស់ជននោះពុំសមស្របនឹងការឃាត់ខ្លួនទេដោយមានវិញ្ញាបនបត្របញ្ជាក់សុខភាពផង មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ភ្លាមដល់ព្រះរាជអាជ្ញាដើម្បីមានលទ្ធភាពក្នុងការចុះទៅទីកន្លែងផ្ទាត់ដើម្បីពិនិត្យឱ្យបានច្បាស់លាស់។[51]

ថ្វីបើជនដែលឃាត់ខ្លួនមានឋានៈជាជនសង្ស័យក្តី ប៉ុន្តែទទួលការការពារដោយច្បាប់ជាធរមាន ដោយជននោះមានសិទ្ធិនានាជាច្រើន ពិសេសគឺសិទ្ធិទទួលបានជំនួយដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អំពីចំណុចនេះ។[52] ការឃាត់ខ្លួនត្រូវមានកំណត់ហេតុសរុបមួយ ដែលដាក់បញ្ចូលទៅក្នុងសំណុំរឿងក្តីនោះ។[53]

---

[49] មាត្រា៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[50] មាត្រា៩៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[51] មាត្រា៩៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[52] មាត្រា៩៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[53] មាត្រា១០២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.១.៥.ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

ក្រោយចប់ថេរវេលានៃការឃាត់ខ្លួនជនសង្ស័យ ជននេះនឹងបន្តដល់នីតិវិធីនៃការបញ្ជូនខ្លួន ដែលក្នុងនោះមានជម្រើសចំនួន ២ ដែលមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើបានដោយមានសេចក្ដីសម្រេចចេញពីព្រះរាជអាជ្ញារួមមាន៖

- ការបញ្ជូនខ្លួនជននោះទៅព្រះរាជអាជ្ញា
- ដោះលែងឱ្យមានសេរីភាពឡើងវិញ។[54]

ករណីបើត្រូវបញ្ជូនខ្លួនជននោះទៅព្រះរាជអាជ្ញា ជននោះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា។ ថិរវេលានៃការបញ្ជូនខ្លួនត្រូវធ្វើឡើងនៅក្នុងរយៈពេលមួយដ៏ឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ កាលបើកាលៈទេសៈបណ្ដាលឱ្យមានការយឺតយ៉ាវដូចជា ស្ថានភាពលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូន ព្រះរាជអាជ្ញាបានផ្ដល់រយៈពេលបន្ថែមដល់មន្ត្រីនគរបាលយុត្តិធម៌(មូលហេតុនៃការយឺតយ៉ាវខាងលើត្រូវចុះសម្គាល់ក្នុងកំណត់ហេតុ)។[55]

ក្នុងន័យនេះក្រោយអស់ថិរវេលាដែលក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យមានការឃាត់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌មានករណីកិច្ចក្នុងការស្នើសុំយោបល់ដល់ព្រះរាជអាជ្ញា ថាគប្បីពិនិត្យលទ្ធភាពដើម្បីដោះលែងជននោះឱ្យមានសេរីឡើងវិញ ឬក៏បន្តការស៊ើបអង្កេតក្នុងបរិបថជាការស៊ើបអង្កេតបឋមវិញ។

### ២.១.៦.វិធានពិសេសនៃការស៊ើបអង្កេតករណីជាក់ស្ដែង

មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចតាមផ្លូវច្បាប់ក្នុងការបង្គាប់ឱ្យស្ដាប់ ថតសំឡេងការសន្ទនាតាមទូរសព្ទ ព្រមទាំងមិនអាចចាប់ និងថតសារសន្ទនាតាមមធ្យោបាយទូរគមនាគមន៍ដូចជា សារតាមទូរសព្ទ ឬអិនធើណែត។[56] ឧទាហរណ៍.សារ SMS, សារតាមប្រព័ន្ធតេលេក្រាម ជាដើម។

ក្រោយពីរយៈពេលនៃការស៊ើបអង្កេតជាក់ស្ដែងត្រូវបានបញ្ចប់ ឬករណីមានការបញ្ជូនខ្លួនជនសង្ស័យទៅព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។[57]

កំណត់ហេតុមានតម្លៃត្រឹមជាព័ត៌មានប៉ុណ្ណោះ ប៉ុន្តែរាល់កំណត់ហេតុដែលធ្វើឡើងនៅដំណាក់កាលនៃការស៊ើបអង្កេតណាមួយត្រូវទុកជាឯកសារដើមរហូតមានភស្តុតាងផ្ទុយ ដែលវិធាននេះស្របគ្នាជាមួយមាត្រា ៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ កាលបើមានភស្តុតាងផ្ទុយអាចដាក់ជូនដល់ចៅក្រមបានដោយសេរី

[54] មាត្រា១០៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
[55] មាត្រា១០៤, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
[56] មាត្រា១០៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
[57] មាត្រា១០៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

តាមមធ្យោបាយដែលស្របច្បាប់។ ចៅក្រមធ្វើការពិចារណារកហេតុផលដោយសេរីលើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងនីតិវិធីនៃការស៊ើបអង្កេតជាក់ស្តែងនេះ។[58] មួយវិញទៀតកំណត់ហេតុត្រូវស្របតាមវិធានទម្រង់ ដោយត្រូវចុះរួមមាន ឈ្មោះ អមជាមួយឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ អង្គភាពសាមី និងកាលបរិច្ឆេទ។ បន្ថែមពីនេះកំណត់ហេតុត្រូវមានចុះហត្ថលេខាសម្គាល់របស់មន្ត្រីនគរបាលយុត្តិធម៌នៅគ្រប់ទំព័រនីមួយៗទាំងអស់។ កាលបើមានពាក្យឆូតលុប និងការយោងផ្សេងៗត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រនោះ។ បុគ្គលដែលពាក់ព័ន្ធក្នុងការស្តាប់ចម្លើយ ឬការឃាត់ខ្លួន ត្រូវមានចុះហត្ថលេខានៅក្នុងកំណត់ហេតុដូច្នោះដែរ។[59]

### ២.១.៧.មោឃភាពនៃនីតិវិធីស៊ើបអង្កេតជាក់ស្តែង

នីតិវិធីនៃការប្រតិបត្តិការការងារពិតជាមានសារសំខាន់ណាស់គ្រប់ចំណុចទាំងអស់ ស្ថិតក្នុងនីតិវិធីនៃការស៊ើបអង្កេតជាក់ស្តែងកាលណាមន្ត្រីនគរបាលដែលពុំគោរពតាមវិធាន និងទម្រង់នៃការការស៊ើបអង្កេតជាក់ស្តែងនោះទេនឹង នាំឱ្យមោឃភាពនៃនីតិវិធី កាលបើមិនបានគោរពតាមលក្ខខណ្ឌដាច់ខាតដែលមានរួមមានៈ

- កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការឆែកឆេរក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការបិទស្លាកបោះត្រាលើវត្ថុតាងក្នុងការស៊ើបអង្កេតជាក់ស្តែង
- កំណត់ហេតុស្តាប់ចម្លើយក្នុងការស៊ើបអង្កេតជាក់ស្តែង
- បទបញ្ជាឱ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង
- ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ
- កំណត់ហេតុស្តីពីការឃាត់ខ្លួន
- ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន
- ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង
- ថេរវេលានៃការស៊ើបអង្កេតជាក់ស្តែង
- និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ។[60]

[58] មាត្រា១១០, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[59] មាត្រា១០៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[60] មាត្រា១០៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.២.ការស៊ើបអង្កេតបឋម

ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពើដែលអាចជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងជាបឋមបាន ឬតាមការស្នើសុំពីសំណាក់ព្រះរាជអាជ្ញា ចំពោះវិធានដែលទាក់ទងនឹងការស៊ើបអង្កេតនេះ វិធាននៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ។[61]

#### ២.២.១.ការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ករណីបទល្មើសមិនជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបានផងដែលក្នុងករណីវិធានស៊ើបអង្កេតមិនជាក់ស្តែងនេះ។

**ការឆែកឆេរ** មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយមានការយល់ព្រមដែលធ្វើឡើងដោយលាយលក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងពុំចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ។ មួយវិញទៀត ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធមិនឱ្យធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាអាចធ្វើសំណើសុំដីកាអនុញ្ញាតឱ្យធ្វើការឆែកឆេរដែលចេញដោយប្រធានសាលាដំបូង ហើយការដឹកនាំនៃវិធានក្នុងការឆែកឆេរនេះត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា។ ការឆែកឆេរនេះត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីនេះពុំអាចយកនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ចំពោះការឆែកឆេរនេះ មិនអាចផ្តើមការឆែកឆេរនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចនោះឡើយ។[62] ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការចាប់យកវត្ថុតាងនៃបទល្មើសមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបិទស្លាកបោះត្រាលើវត្ថុចាប់ (វត្ថុតាង) យកនោះ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើល រួចធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យកនោះ ដោយមានការចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើកោះហៅ ឬនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងក្តីនេះបាន។ ការស្តាប់ចម្លើយ(ស្រង់យកចម្លើយត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីដែលជនត្រូវបានស្តាប់ចម្លើយជាជនបរទេស

---

[61] មាត្រា១១១, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[62] មាត្រា១១៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

គថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល ឬ កងរាជអាវុធហត្ថ ដែលរួមសហការក្នុងរឿងក្តីនេះឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីស្តាប់ចម្លើយរួចហើយត្រូវអានដោយសម្លេងខ្លាំងៗ នូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានស្តាប់ចម្លើយ (និងអ្នកបកប្រែបើមាន) ហើយឱ្យចុះហត្ថលេខា ឬផ្តិតម្រាមដៃនៅគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយ ក្នុងករណីដែល បុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិតម្រាមដៃទេនោះមន្ត្រីនគរបាលត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ អំពីហេតុការណ៍នេះ (មាត្រា ១១៤ និងមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនិងការកោះហៅនេះ មន្ត្រីនគរបាលអាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីឱ្យចេញ ដីកាបញ្ជាឱ្យចូលខ្លួន ដែលដីកានេះអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួនបាន។[63]

### ២.២.២.ការឃាត់ខ្លួន និងនីតិវិធីនៃការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

កាលៈទេសៈនៃបទល្មើសដែលកើតមានឡើងក្នុងចំណាត់ថ្នាក់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ស្ថិតក្រោមការស៊ើបអង្កេតករណីបឋម វិធានគតិយុត្តិពាក់ព័ន្ធនឹងការឃាត់ខ្លួនដូចមានបកស្រាយនៅចំណុច (២.១.៤.ការឃាត់ខ្លួន) និងការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន (២.១.៥.ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន) នៃការស៊ើបអង្កេតជាក់ស្តែង ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរក្នុងការស៊ើបអង្កេតបឋមនេះ។[64]

### ២.២.៣.វិធានពិសេសនៃការស៊ើបអង្កេតករណីមិនជាក់ស្តែង

មិនខុសគ្នានឹងការអនុវត្តករណីជាក់ស្តែងនោះទេ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតករណីបឋមនៅតែមានតម្លៃស្មើនឹងព័ត៌មានប៉ុណ្ណោះសម្រាប់ជូនស្ថាប័នតុលាការ ដោយត្រូវចាត់ទុកជាឯកសារដើមដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយណាមួយជាក់លាក់។ ដោយការដាក់នូវភស្តុតាងនេះមានលក្ខណៈសេរីអាចដាក់បានគ្រប់មធ្យោបាយជូនដល់ចៅក្រមដើម្បីពិនិត្យ។ ភស្តុតាងនេះមិនចងជាកាតព្វកិច្ចដល់ចៅក្រមនោះទេ ចៅក្រមមានសិទ្ធិក្នុងការប្រើប្រាស់សុគតិធម៌របស់ខ្លួនក្នុងការពិនិត្យ និងសម្រេចដោយអនុលោមតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។[65]

[63] មាត្រា១១៤, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[64] មាត្រា១១៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[65] មាត្រា១១៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.២.៤.មោឃភាពនៃនីតិវិធីស៊ើបអង្កេតមិនជាក់ស្តែង

កាលណាមន្ត្រីនគរបាលយុត្តិធម៌ក្នុងអំឡុងពេលអនុវត្តនីតិវិធីនៃការស៊ើបអង្កេតបឋម ពុំបានគោរពក្នុងលក្ខណៈដាច់ខាតតាមវិធាន និងទម្រង់នៃការការស៊ើបអង្កេតខាងលើ នឹងនាំឱ្យកិច្ចស៊ើបអង្កេតនេះត្រូវចាត់ទុកជាមោឃៈ ករណីដែលបំពានលើចំណុចដូចខាងក្រោម៖

- ការឃាត់ខ្លួន
- កំណត់ហេតុនៃការឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងរបស់មន្ត្រីនគរបាលយុត្តិធម៌
- ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា
- ការឆែកឆេរ
- ការបញ្ជាឱ្យចូលខ្លួន។[66]

កាលណានីតិវិធីរបស់នគរបាលយុត្តិធម៌ត្រូវបានមោឃភាពនោះសំណុំរឿងដែលបានកសាងនោះ ត្រូវចាត់ទុកជាមិនបានការ។

### ២.៣.ភាពខុសគ្នារវាងការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម

- ការប្រព្រឹត្តបទល្មើសជាក់ស្តែងគឺមានន័យថាការប្រព្រឹត្តបទល្មើសនោះ ដោយជនល្មើសកំពុងតែប្រព្រឹត្តជាក់ស្តែងហើយជនល្មើសនោះកំពុងតែត្រូវបានសមត្ថកិច្ចកំពុងតែដេញប្រដាប់ចាប់ប្រភីង (ដូចជាករណីចោរលួចដែលត្រូវបានសមត្ថកិច្ចកំពុងតែដេញតាមចាប់ខ្លួន) ហើយសមត្ថកិច្ចអាចចាប់ខ្លួនជនល្មើសនោះដោយមិនចាំបាច់សុំដីកាចាប់ខ្លួនពីតុលាការនោះឡើយ។ ចំណែកបទល្មើសបឋម មានភាពខុសគ្នាទៅនឹងការបើកការស៊ើបអង្កេតករណីជាក់ស្តែង ដូចមានចែងក្នុងមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការស្នើដោយព្រះរាជអាជ្ញា" ។
- ការឆែកឆេរនៅក្នុងការស៊ើបអង្កេតទាំងពីរថ្វីត្បិតតែមានចំណុចមួយចំនួនដូចគ្នាក្តី ផ្ទុយទៅវិញក៏នូវតែមានចំណុចមួយចំនួនមិនដូចគ្នាឡើយ។ ការឆែកឆេរក្នុងករណីស៊ើបអង្កេតជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីសំណាក់ព្រះរាជអាជ្ញាដោយមិនចាំបាច់មានដីកាពីតុលាការទេ ហើយការអនុញ្ញាតនោះជាលាយលក្ខណ៍អក្សរ ឬមួយដោយផ្ទាល់មាត់។ រីឯក្នុងករណីស៊ើបអង្កេតបឋម ត្រូវមានដីកាអនុញ្ញាតឱ្យឆែកឆេរពីប្រធានសាលាដំបូង តាមការសុំរបស់ព្រះរាជអាជ្ញា ក្នុងករណី

[66] មាត្រា១១៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ដែលអ្នកដែលកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ឱ្យកន្លែង ឬសាក្សីពីរនាក់ ហើយមិនអាចផ្តើមមុនម៉ោង ៦ ព្រឹក ដល់ក្រោយម៉ោង ១៨ ល្ងាចឡើយ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ពុំបានអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ហើយមានការបំពានទៅលើសិទ្ធិឯកជននៃលំនៅឋាន មន្ត្រីនគរបាលយុត្តិធម៌អាចត្រូវផ្តន្ទាទោសពី បទរំលោភលើលំនៅឋានតាមមាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌដែលចែងថាៈ អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ចូលទៅក្នុងលំនៅឋានរបស់អ្នកដទៃដោយគ្មានការយល់ព្រមពីម្ចាស់ផ្ទះទេនោះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ទៅ ៤ លានរៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត។

## ២.៤.ការមានចំណាត់ការលើបណ្តឹងអាជ្ញាដោយស្ថាប័នអយ្យការ

ស្ថិតក្នុងការបំពេញតួនាទីជាតំណាងឱ្យស្ថាប័នអយ្យការ កាលណាព្រះរាជអាជ្ញាមានការពិនិត្យឃើញថាមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌកើតមានឡើងនោះ ច្បាប់បានប្រគល់សិទ្ធិអំណាចជូនព្រះរាជអាជ្ញាក្នុងការអនុវត្តកាលានុវត្តភាពលើការចោទប្រកាន់ណាមួយនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាអាចចោទប្រកាន់ក្នុងសំណុំរឿងដោយឈរលើគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និងគោលការណ៍កាលានុវត្តភាព (ជម្រើស) នៃការចោទប្រកាន់។

### ២.៤.១.ការតម្កល់រឿងទុកឥតចាត់ការ

ក្រៅតែអំពីតួនាទីក្នុងការចោទប្រកាន់ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការ ពោលគឺសម្រេចមិនចោទប្រកាន់ចំពោះអំពើដែលប្តឹងមកខ្លួន។ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការអាចត្រូវបានធ្វើឡើងដោយផ្អែកលើមូលហេតុជាច្រើន ប៉ុន្តែមូលហេតុទាំងនោះមិនបានកំណត់ជាក់លាក់ដោយច្បាប់ទេ។ ការតម្កល់រឿងទុកឥតចាត់ការ អាចបណ្តាលមកពីអវត្តមាននៃបទល្មើស ឬអត្តសញ្ញាណមិនពេញលេញរបស់ចារី ឬពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញពីពិរុទ្ធភាព ហើយការស្រាវជ្រាវបន្ថែមដែលអាចនឹងត្រូវធ្វើហាក់ដូចជាគ្មានប្រយោជន៍ និងគ្មានប្រសិទ្ធិភាព។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។[67] មានន័យថា ព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការចំពោះបទល្មើសផ្នែកព្រហ្មទណ្ឌដែលគេប្តឹងមកខ្លួន ដោយធ្វើការថ្លឹងថ្លែង និងពិចារណាលើផលប្រយោជន៍សាធារណៈ ព្យសនកម្មដែលបណ្តាលមកពីបទល្មើស ដោយមានសំអាងច្បាប់ និងសំអាងហេតុជាក់លាក់។ ការតម្កល់រឿងទុក

[67] មាត្រា៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំនោះទេ។[68] ព្រះរាជអាជ្ញាអាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ចំពោះអំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ លើសពីនេះតាមបញ្ញត្តិខាងលើបានផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការ បើទោះបីជាអំពើដែលប្តឹងមកនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ពោលព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់ចំពោះបទឧក្រិដ្ឋដែលជាបទល្មើសមានលក្ខណៈធ្ងន់ធ្ងរផងដែរ។

ជារួមការតម្កល់រឿងទុកឥតចាត់ការ គឺជាជម្រើសមួយអនុញ្ញាតឱ្យព្រះរាជអាជ្ញាអាចថ្លឹងថ្លែង និងសម្រេចធ្វើការតម្កល់នូវសំណុំរឿងព្រហ្មទណ្ឌណាមួយដែលខ្លួនបានទទួលយកមកចាត់ការជាសមត្ថកិច្ចទុកឥតចាត់ការ ទោះបីអង្គហេតុនៃរឿងនោះមិនមែនជារឿងព្រហ្មទណ្ឌ ឬរឿងក្តីព្រហ្មទណ្ឌក៏ដោយ។

**២.៤.២.គោលការណ៍ភាពសមស្របនៃការចោទប្រកាន់**

ព្រះរាជអាជ្ញាមានជម្រើសនៃការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមរយៈ៖

- ការបើកការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។[69]

**២.៤.២.១.ការបើកការស៊ើបសួរ**

ការបើកការស៊ើបសួរ គឺជាប្រភេទនៃការចោទប្រកាន់មួយ ដែលព្រះរាជអាជ្ញាបញ្ជូនអង្គហេតុទៅយុត្តាធិការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការចោទប្រកាន់តាមនីតិវិធីនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យចៅក្រមស៊ើបសួរស្រាវជ្រាវបន្ថែម ព្រោះសំណុំរឿងនេះមានលក្ខណៈស្មុគស្មាញ និងពុំទាន់មានលក្ខណៈអាចបញ្ជូនទៅជំនុំជម្រះបាន។

កត្តានាំឱ្យព្រះរាជអាជ្ញាសម្រេចបញ្ជូនរឿងឱ្យចៅក្រមស៊ើបសួរឱ្យស្រាវជ្រាវបន្ថែម គឺបណ្តាលមកពី ២ កត្តាធំៗគឺ៖

- កត្តាទាក់ទងនឹងជនល្មើស ៖ ជនល្មើសមិនស្គាល់អត្តសញ្ញាណ ការប្រព្រឹត្តបទល្មើសមានគ្នាច្រើន ដែលត្រូវស្រាវជ្រាវបន្ថែម ជនល្មើសប្រព្រឹត្តបទល្មើសត្រួតគ្នាជាអាទិ៍។
- កត្តាទាក់ទងនឹងភស្តុតាង ៖ ពុំទាន់មានសាវតាដាក់បន្ទុកគ្រប់គ្រាន់ ពុំទាន់មានភស្តុតាងគ្រប់គ្រាន់ ដើម្បីជំនុំជម្រះ ។

[68] មាត្រា៤១ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[69] មាត្រា៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ការបើកការស៊ើបសួរមានលក្ខណៈដាច់ខាតចំពោះបទឧក្រិដ្ឋ ត្រូវតែបើកការស៊ើបសួរដោយព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាដីកាដែលព្រះរាជអាជ្ញាធ្វើការប្តឹងទៅចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការបើកការស៊ើបសួរទៅលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ ដែលក្នុងនោះមានលក្ខខណ្ឌនៃការបើកការស៊ើបសួរ។

**លក្ខខណ្ឌនៃការបើកការស៊ើបសួរ** ដើម្បីបើកការស៊ើបសួរបាន ត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា៖

- ការបើកការស៊ើបសួរបទឧក្រិដ្ឋ[70] ៖ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរជានិច្ចតាមគោលការណ៍នីត្យានុកូលភាព ទោះជាបទល្មើសនោះជាបទឧក្រិដ្ឋជាក់ស្តែងក៏ដោយ។ ដូចនេះ ព្រះរាជអាជ្ញាគ្មានជម្រើសណាផ្សេងក្រៅពីនេះឡើយ ចំណុចនេះស្តែងបង្ហាញឱ្យឃើញពីភាពដាច់ខាតនៃការចោទប្រកាន់របស់តំណាងអយ្យការ។ ភាពដាច់ខាតនេះមិនបានស្តែងឡើងក្នុងករណី បទល្មើសជាបទមជ្ឈិមមិនជាក់ស្តែង ឬបទលហុ មានន័យថាតំណាងអយ្យការអាចធ្វើការចោទប្រកាន់ជម្រើសផ្សេង ក្រៅពីការស៊ើបសួរ។ ទោះជាយ៉ាងណា តំណាងអយ្យការនៅតែអាចធ្វើការចោទប្រកាន់តាមរយៈការស៊ើបសួរ ក្នុងករណីសំណុំរឿងមិនអាចធ្វើការជំនុំជម្រះបានដោយសារកត្តាដែលជាហេតុមិនអាចយកសំណុំរឿងទៅជំនុំជម្រះបាន ដោយចារីជាអញ្ញាត្តជន។ ក្នុងករណីតំណាងអយ្យការយល់ឃើញថាភស្តុតាងដែលប្រមូលបានពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីជំនុំជម្រះ ឬតំណាងអយ្យការមិនស្គាល់នូវអត្តសញ្ញាណចារី ជាដើម។
- ការបើកការស៊ើបសួរក្នុងបទមជ្ឈិម[71] ៖ ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរបានតាមរយៈការចោទដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ នៅក្នុងករណីដែលបទល្មើសនោះជាប្រភេទបទល្មើសមជ្ឈិម ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឆន្ទានុសិទ្ធិឱ្យទៅព្រះរាជអាជ្ញាក្នុងការសម្រេច និងពិចារណាក្នុងការថ្លឹងថ្លែងគួរបើកការស៊ើបសួរ ឬបញ្ជូនទៅជម្រះផ្ទាល់។ ជាទូទៅការបើកការស៊ើបសួរក្នុងបទមជ្ឈិម យើងសង្កេតឃើញថាជារឿងដែលមានលក្ខណៈស្មុគស្មាញ ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមជាតិធ្ងន់ធ្ងរ។

និទ្ទេសដែលចុះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស

[70] មាត្រា៤៤, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[71] មាត្រា៤៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

• និងឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកានេះត្រូវចង្អុលបង្ហាញប្រាប់តុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន។[72]

**២.៤.២.២.ការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ករណីដែលព្រះរាជអាជ្ញាយល់ឃើញថាបទល្មើសជាបទមជ្ឈិមនោះ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីឱ្យតុលាការធ្វើការជំនុំជម្រះបាន ព្រះរាជអាជ្ញាអាចជ្រើសរើសវិធីនៃការចោទប្រកាន់តាមនីតិវិធីនៃការបញ្ជូនទៅជម្រះផ្ទាល់បាន មានន័យថាវិធាននេះ ច្បាប់មិនបានបញ្ញត្តិចងកាតព្វកិច្ចជាដាច់ខាតដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់តាមការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ដែលជាការបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូងនោះទេ។ មុននឹងឈានទៅដល់ការសម្រេចចោទប្រកាន់ តាមនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចាំបាច់ទាមទារឱ្យព្រះរាជអាជ្ញាគោរពនូវលក្ខខណ្ឌមួយចំនួន។ លក្ខខណ្ឌទាំងនោះគឺសំដៅទៅដល់លក្ខខណ្ឌនៃបទល្មើស និងលក្ខខណ្ឌនៃសាវតាជាតិរបស់ជនល្មើសដែលចាំបាច់ត្រូវបំពេញ។

**លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់** នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ អាចធ្វើឡើងបានចំពោះបទមជ្ឈិម និងបទលហុ តែប៉ុណ្ណោះ។ តំណាងអយ្យការ អាចចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៅពេលដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ចំពោះបទលហុ[73] ៖ បទលហុ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសជាអតិបរមាមានរយៈពេលស្មើឬក្រោម ៦ ថ្ងៃ។ នៅពេលអង្គហេតុដែលមានស្ថានទម្ងន់ទោសជាបទលហុនោះ នាំឱ្យព្រះរាជអាជ្ញានឹងសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង ដោយមូលហេតុថា បទលហុជាប្រភេទបទល្មើសដែលមានលក្ខណៈក្នុងការផ្តន្ទាទោសស្រាល និងតូចតាច។ ផ្ទុយទៅវិញ បើត្រូវរងការចោទប្រកាន់ដោយប្រើនីតិវិធីផ្សេងៗដូចជាការបង្ហាញខ្លួនភ្លាម ឬការបើកការស៊ើបសួរ នាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនជាប់ចោទ ព្រោះតាមនីតិវិធីបង្ហាញខ្លួនភ្លាម និងការបើកការស៊ើបសួរអាចទាមទារឱ្យមានការឃុំខ្លួន។

- ចំពោះបទមជ្ឈិម ៖ ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ពុំបានចែងច្បាស់ថាជាប្រភេទបទមជ្ឈិមបែបណា ដែលអាចអនុញ្ញាតឱ្យព្រះរាជអាជ្ញាអនុវត្តនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏ដោយ ក៏ប៉ុន្តែគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងពីស្ថានភាពនៃបទល្មើស។ ដោយឡែកបើព្រះរាជអាជ្ញាមើលឃើញថា បទមជ្ឈិមនោះមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឱ្យតុលាការធ្វើការជំនុំជម្រះវិនិច្ឆ័យសេចក្តីលើរឿងនេះបាន ព្រះរាជអាជ្ញានឹងប្រើនីតិវិធីនៃការចោទប្រកាន់នេះ។ ផ្ទុយមកវិញ បទមជ្ឈិមអាចជាកម្មវត្ថុនៃ

[72] មាត្រា៤៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[73] មាត្រា៤៨, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ការចោទប្រកាន់តាមទម្រង់ជាការបើកការស៊ើបសួរ និងជាការបង្ហាញខ្លួនភ្លាមផងដែរ ព្រោះមានស្ថានភាពនៃបទមជ្ឈិមមួយចំនួនត្រូវបានទទួលឱ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងទៀតបានដូចជាស្ថានភាពនៃបទមជ្ឈិមដែលមានលក្ខណៈស្មុគស្មាញ ទាមទារឱ្យមានការបើកការស៊ើបអង្កេតស្វែងរកភស្តុតាងគ្រប់គ្រាន់ ឬបទល្មើសដែល មិនស្គាល់អត្តសញ្ញាណជនល្មើសជាដើម ។

- លក្ខខណ្ឌសារវតាជាតិ ៖ ព្រះរាជអាជ្ញា ចាំបាច់ត្រូវរកឱ្យឃើញអត្តសញ្ញាណរបស់ជនល្មើសនោះ ព្រោះវាជាមូលហេតុចាំបាច់ សម្រាប់ធ្វើការកំណត់បង្ហាញពីលក្ខខណ្ឌមួយក្នុងការធ្វើបណ្តឹងអាជ្ញា មានគោលបំណងក្នុងការស្វែងរកអត្ថិភាពនៃបទល្មើស បូករួមទាំងការផ្តន្ទាទោសទៅលើជនល្មើសផងដែរ។ នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នេះ ចាំបាច់ត្រូវធ្វើការទាមទារកំណត់ពីអត្តសញ្ញាណរបស់ជនល្មើសដោយខានមិនបាន ដោយហេតុថា ប្រសិនបើជនល្មើសមិនបានស្ថិតក្នុងភាពស្គាល់អត្តសញ្ញាណទេនោះ នាំឱ្យដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់មិនអាចប្រព្រឹត្តបានទេ។ ម្យ៉ាងវិញទៀត ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការទទួលស្គាល់វិសាលភាពនៃបណ្តឹងចំពោះជនជាប់ចោទ មានន័យថាតុលាការនឹងធ្វើការជំនុំជម្រះទៅលើជនទាំងឡាយណា ដែលមានក្នុងពាក្យបណ្តឹងតែប៉ុណ្ណោះ។ ដូច្នេះ ការស្គាល់នូវអត្តសញ្ញាណរបស់ជនល្មើសគឺជាកត្តាចាំបាច់ និងជាលក្ខខណ្ឌដែលមិនអាចខ្វះបានឡើយ។

- មានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះផ្ទាល់បាន ៖ ដោយពុំត្រូវការនូវការស្រាវជ្រាវបន្ថែមឡើយ។

**២.៤.២.៣.នីតិវិធីបង្ហាញខ្លួនភ្លាម**

ការបង្ហាញខ្លួនភ្លាម គឺជាប្រភេទមួយនៃការចោទប្រកាន់របស់តំណាងអយ្យការ ដោយការចោទប្រកាន់តាមវិធីនេះ ពុំឆ្លងកាត់ដំណាក់កាលស៊ើបសួរនោះទេ គឺបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅចៅក្រមជំនុំជម្រះធ្វើការជំនុំជម្រះនៅថ្ងៃដែលជនជាប់ចោទមកបង្ហាញខ្លួននៅមុខតំណាងអយ្យការតែម្តង។ ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូង។ ប្រសិនបើមានលក្ខខណ្ឌត្រូវបានបំពេញ។

លក្ខខណ្ឌនៃនីតិវិធីបង្ហាញខ្លួនភ្លាម វិធីនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម គឺជាជម្រើសមួយនៃការចោទរបស់តំណាងអយ្យការ ដែលការចោទប្រកាន់នេះធ្វើឡើងដោយពុំឆ្លងកាត់ការស៊ើបសួរនោះទេ គឺបញ្ជូលសំណុំរឿង និងជនជាប់ចោទទៅចៅក្រមជំនុំជម្រះដើម្បីជំនុំជម្រះ នៅថ្ងៃដែលជនជាប់ចោទចូលមកបង្ហាញខ្លួនចំពោះមុខតំណាងអយ្យការតែម្តង។ មិនតែប៉ុណ្ណោះ នីតិវិធីបង្ហាញខ្លួនភ្លាមនេះ ជានីតិវិធីមួយដែលមានលក្ខណៈលឿនជាងនីតិវិធីនៃការចោទប្រកាន់ផ្សេងទៀត វាសម្រួលដល់ដំណើរការរឿងក្តីព្រហ្មទណ្ឌឱ្យបានឆាប់រហ័សជៀសវាងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការក៏ដូចជា ដើម្បីសម្រួលដល់វិស័យយុត្តិធម៌ក្នុងតុលាការ

កម្ពុជាផងដែរ។ យ៉ាងណាមិញ នីតិវិធីបង្ហាញខ្លួនភ្លាមនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការបំពេញនូវលក្ខខណ្ឌមួយចំនួន ហើយដំណើរការប្រព្រឹត្តទៅស្របតាមនីតិវិធីនេះ។

ព្រះរាជអាជ្ញាអាចជ្រើសយកនីតិវិធីនៃការចោទប្រកាន់តាមរយៈការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខសាលាដំបូង ក្នុងករណីមានលក្ខខណ្ឌដូចខាងក្រោម៖

- បទល្មើសជាច់ខាតត្រូវតែជាបទល្មើសជាក់ស្តែង ៖ ក្រៅពីបទមជ្ឈិមជាក់ស្តែង ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានឡើយ ឬអាចនិយាយម៉្យាងទៀតបានថា នីតិវិធីមួយនេះមិនអាចអនុវត្តបានឡើយ ចំពោះករណីបទឧក្រិដ្ឋ មជ្ឈិមមិនជាក់ស្តែង ឬបទលហុ។

- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ និងយ៉ាងច្រើន ៥ ឆ្នាំ

- ជនជាប់ចោទជានីតិជន ៖ នីតិជនសំដៅដល់ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ។ វិធានការបានកម្រិតពីចំណុច វិធីជាតាមការដែលចង់មានការជំនុំជម្រះជាច្រើនដែលនាំឱ្យមានការសន្និដ្ឋានលឿន និងចង់បានវត្តមានជនល្មើសនៅពេលអនុវត្តទោស ដោយអនុញ្ញាតឱ្យចៅក្រមអាចសម្រេចឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន។ ដូចនេះបើយើងយកអនីតិជនមកប្រើចំពោះនីតិវិធីបែបនេះ ហាក់បីដូចជា គម្រាមដល់គោលការណ៍នៃការយកចិត្តទុកដាក់បំផុតចំពោះផលប្រយោជន៍របស់អនីតិជន។ ការទទួលលក្ខខណ្ឌបែបនេះ គឺជាស្មារតីនៃការទទួលស្គាល់សិទ្ធិរបស់អនីតិជន ដោយធានាថាមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពារអនីតិជន និងជៀសវាងការបំពាននូវសិទ្ធិរបស់អនីតិជន។

- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន[74] ៖ សំណុំរឿងមានភាពពេញលេញទាំងជនសង្ស័យ ភស្តុតាងនានា។

[74] មាត្រា៤៧, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

# ជំពូកទី៣
# អំពីអំណាចព្រះរាជអាជ្ញា
# ចំពោះនគរបាលយុត្តិធម៌

# ជំពូកទី៣

# អំពីអំណាចព្រះរាជអាជ្ញាចំពោះនគរបាលយុត្តិធម៌

## ៣.១.ការធ្វើអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌ និងការដាក់វិន័យ

ព្រះរាជអាជ្ញាជាបុគ្គលដែលបានទទួលការសិក្សាជ្រៅជ្រះលើផ្នែកច្បាប់ ដែលមានសមត្ថភាពក្នុងការអនុវត្តកិច្ចការរបស់ខ្លួនបានដោយស្របតាមនីតិវិធីច្បាប់ជាធរមាន ជាហេតុនាំឱ្យព្រះរាជអាជ្ញាទទួលសិទ្ធិអំណាចតាមផ្លូវច្បាប់ជានាយហានុក្រមរបស់នគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌរឿងក្ដីព្រហ្មទណ្ឌ ក្នុងសមត្ថកិច្ចដែនដីដែលខ្លួនបំពេញការងារព្រមទាំងអាចអនុវត្តនូវ (៣.១.១.ការធ្វើអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌) និង(៣.១.២.កំហុសរបស់នគរបាលយុត្តិធម៌ និងការរងវិន័យ)។

### ៣.១.១.ការធ្វើអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌

អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងអាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ អាចចូលរួមក្នុងការស្ដាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន។ ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូប ត្រូវគោរពតាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍។[75] អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ អាចធ្វើការឃ្លាំមើល និងធ្វើការត្រួតពិនិត្យនគរបាលយុត្តិធម៌ ព្រមទាំងអាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ អាចប្រគល់ភារកិច្ចដល់មន្ត្រីនគរបាលយុត្តិធម៌ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តិទៅរបស់អង្គភាពនគរបាលយុត្តិធម៌ទាំងនេះ។ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ អាចប្រគល់ភារកិច្ចដល់មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឱ្យបំពេញកិច្ចទាំងឡាយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការល្អនៃនគរបាលយុត្តិធម៌។

ការចុះធ្វើអធិការកិច្ចរបស់មហាអយ្យការអមសាលាឧទ្ធរណ៍មានគោលបំណង ពិនិត្យ តាមដាន និងពង្រឹងការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព និងត្រឹមត្រូវស្របតាមនីតិវិធីច្បាប់ជាធរមាន ក៏ដូចជាឈ្វេងយល់អំពីបញ្ហាប្រឈម និងសំណូមពរ ដើម្បីពិភាក្សារកដំណោះស្រាយរួមគ្នា ធានារក្សាបាននូវកិច្ចសហការល្អរវាងស្ថាប័នមហាអយ្យការអមសាលាឧទ្ធរណ៍ ជាមួយនឹងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត អង្គភាព

[75] មាត្រា៣៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងសូមចូលមើលទិដ្ឋភាពនៃការអនុវត្តជាក់ស្ដែង https://m.freshnewsasia.com/index.php/en/localnews/332263-2024-03-13-07-49-25.html ចូលមើលនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤

នគរបាលយុត្តិធម៌ និងពន្ធនាគារ។ ការចុះធ្វើអធិការកិច្ចនេះអាចផ្តល់លទ្ធភាពក្នុងការ តម្រង់ទិសការអនុវត្ត ការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ឱ្យបានកាន់តែរលូន និងប្រសើរឡើងស្របតាមនីតិវិធី ដោយធ្វើការណែនាំផ្សេងៗ ជាអាទិ៍ឱ្យមានការកោះហៅមន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកកសាងសំណុំរឿងចូលរួមក្នុងសវនាការ ដើម្បីការពារនូវរបាយការណ៍របស់អង្គភាពខ្លួនក៏ដូចជាបំភ្លឺនូវចំណុចនានាដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត ពន្យល់បន្ថែមនូវនីតិវិធីមួយចំនួនដល់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ឱ្យបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមនីតិវិធីជាធរមាន និងប្រកបដោយសីលធម៌តាមវិជ្ជាជីវៈ ហើយប្រសិនក្នុងករណីមានឧបសគ្គក្នុងការអនុវត្ត ឬមានចម្ងល់ពាក់ព័ន្ធនឹងនីតិវិធី អាចសុំជាមតិណែនាំដើម្បីសម្របសម្រួលបន្ថែម។[76] ការចុះធ្វើអធិការកិច្ចពីអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាតែងមាននូវ(៣.១.១.១. ការពិនិត្យបញ្ជីបណ្តឹងព្រហ្មទណ្ឌ) (៣.១.១.២.ការពិនិត្យបញ្ជីនៃការឃាត់ខ្លួន) និង(៣.១.១.៣.ការពិនិត្យទីកន្លែងឃាត់ខ្លួន) ព្រមទាំងអាច(៣.១.១.៤.ការចុះអង្កេតពន្ធនាគារ) ផងដែរ។

**៣.១.១.១.ការធ្វើអធិការកិច្ចពិនិត្យបញ្ជីបណ្តឹងព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌដែលកើតមានឡើង កាលណាអង្គភាពនគរបាលយុត្តិធម៌ទទួលចាត់ការក្នុងនាមជាសមត្ថកិច្ច នោះអង្គភាពនគរបាលយុត្តិធម៌តម្រូវឱ្យមានការកត់ចូលបញ្ជីបណ្តឹងព្រហ្មទណ្ឌ។ បញ្ជីនៃបណ្តឹងព្រហ្មទណ្ឌ (មានបកស្រាយនៅចំណុច ១.២.៣.បញ្ជីនៃបណ្តឹង) ត្រូវតែមានជានិច្ចនៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការកត់ចំណាំអំពី ប្រភេទនៃបទល្មើស កាលៈទេសៈនៃបទល្មើស កាលបរិច្ឆេទ អត្តសញ្ញាណភាគីពាក់ព័ន្ធរួមមាន ជនសង្ស័យ ជនរងគ្រោះ មន្ត្រីនគរបាលយុត្តិធម៌ និងចំណាត់ការនៃបណ្តឹងដែលអង្គភាពនគរបាលយុត្តិធម៌បានអនុវត្ត ព្រមទាំងនិទ្ទេសនានា ដែលអាចផ្តល់ជាឧត្តមប្រយោជន៍ដល់ស្ថាប័នយុត្តាធិការក្នុងការពិនិត្យអំពីភាពត្រឹមត្រូវ ឬសម្រេចសេចក្តី ជាអាទិ៍។ តាមបញ្ញត្តិនៃមាត្រា ៧៣ កថាខណ្ឌចុងក្រោយ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា បញ្ជីនេះត្រូវតែកាន់កាប់អចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ។ ការធ្វើអធិការកិច្ចពិនិត្យបញ្ជីបណ្តឹងព្រហ្មទណ្ឌពីសំណាក់ព្រះរាជអាជ្ញាលើអង្គភាពនគរបាលយុត្តិធម៌ពិតជាមានសារៈសំខាន់ ពិសេសគឺការពិនិត្យមើលលើទម្រង់នៃបញ្ជីដើម្បីធានាបាននូវការកត់នូវបញ្ជីបណ្តឹងមួយដែលមានភាពយកជាការបាន ព្រមទាំងណែនាំផ្នែកដែលពាក់ព័ន្ធផ្សេងទៀតដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីឱ្យការអនុវត្តការងារមានភាពល្អប្រសើរ។

ករណីអង្គភាពនគរបាលយុត្តិធម៌ពុំទាន់មាននូវបញ្ជីបណ្តឹងព្រហ្មទណ្ឌនេះទេ ព្រះរាជអាជ្ញាអាចណែនាំឱ្យមានការរៀបចំ និងណែនាំឱ្យបង្កើតឡើងនូវបញ្ជីបណ្តឹងសម្រាប់ប្រើប្រាស់។

[76] សូមចូលមើលទិដ្ឋភាពនៃការអនុវត្តជាក់ស្តែង https://www.facebook.com/share/ZesCrE4tuikhR3mz/?mibextid=WC7FNe ចូលមើលនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤

**៣.១.១.២.ការធ្វើអធិការកិច្ចពិនិត្យបញ្ជីនៃការឃាត់ខ្លួន**

នាពេលមានបទល្មើសព្រហ្មទណ្ឌហើយអង្គភាពនគរបាលយុត្តិធម៌មានចំណាត់ការឃាត់ខ្លួនជនសង្ស័យ នោះត្រូវមានចុះនិទ្ទេសនៅក្នុងបញ្ជីនៃការឃាត់ខ្លួននៅក្នុងកន្លែងនីមួយៗសម្រាប់ការឃាត់ខ្លួនរបស់នគរបាល ឬកងរាជអាវុធហត្ថ ដែលគ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្ដីដូចតទៅនេះ ៖

- ឈ្មោះ ឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្ដើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យ បន្តការឃាត់ខ្លួន ជាយថាហេតុ
- ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ
- ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។[77]

បញ្ជីនេះត្រូវមានជានិច្ចសម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការផ្សេងៗ ពិសេសគឺការធ្វើអធិការកិច្ចដោយព្រះរាជអាជ្ញានេះឯងដែលត្រូវពិនិត្យមើលលើទម្រង់គ្រប់ផ្នែក ដើម្បីធានាដល់ការឃាត់ខ្លួននោះធ្វើឡើងទៅដោយស្របតាមច្បាប់។

**៣.១.១.៣.ការធ្វើអធិការកិច្ចពិនិត្យទីកន្លែងឃាត់ខ្លួន**

ស្ថិតក្នុងនីតិវិធីនៃការឃាត់ខ្លួនជនសង្ស័យក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ច្បាប់មិនអនុញ្ញាតយកជននោះទៅឃុំឃាំងក្នុងពន្ធនាគារនោះឡើយ ត្រង់នេះបញ្ជាក់ពីការចាត់ចែង និងគិតគូរយ៉ាងយកចិត្តទុកដាក់ដោយវិធានច្បាប់។ ទីកន្លែងឃាត់ខ្លួនដែលអាចឃាត់ខ្លួនជនសង្ស័យបានគឺ មានវត្តមាននៅអង្គភាពនគរបាលយុត្តិធម៌ មានដូចជា អង្គភាពនគរបាល(ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត អធិការដ្ឋាននគរបាលក្រុង/ស្រុក/ខណ្ឌ ប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់) និងអង្គភាពកងរាជអាវុធហត្ថ(បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី/ខេត្ត និងមូលដ្ឋានកងរាជអាវុធហត្ថក្រុង/ស្រុក/ខណ្ឌ)។

ទីកន្លែងសម្រាប់ឃាត់ខ្លួនជនសង្ស័យត្រូវប្រកបដោយលក្ខណៈជាសុខភាព និងបរិយាកាសដែលអាចទទួលយកបានសម្រាប់ការឃាត់ខ្លួន។

ព្រះរាជអាជ្ញាមានសមត្ថកិច្ចក្នុងការចុះអធិការកិច្ចត្រួតពិនិត្យទីកន្លែងសម្រាប់ឃាត់ខ្លួនជនសង្ស័យ ដើម្បីធានាឱ្យបានថាជនសង្ស័យទទួលបាននូវការការពារដោយច្បាប់ មិនមានការរំលោភបំពានលើផ្នែកណាមួយឡើយ។

[77] មាត្រា១០១, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ៣.១.១.៤.ការធ្វើអធិការកិច្ចចុះអន្តេគពន្ធនាគារ

ការធ្វើអធិការកិច្ចពន្ធនាគារអាចធ្វើឡើងដោយអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ។[78] យន្តការបង្ការថ្នាក់ជាតិត្រូវបានអនុញ្ញាតឱ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានាគ្រប់ពេលវេលា និងធ្វើសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ ដើម្បីត្រួតពិនិត្យមើលស្ថានភាពនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អ សំដៅបង្ការទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោកនៅក្នុងពន្ធនាគារ។ ការធ្វើអធិការកិច្ចនេះគឺផ្តោតសំខាន់ទៅលើសុខភាព ការរស់នៅ វត្តមាន ឬអវត្តមានរបស់ជនជាប់ឃុំ ជាពិសេសគឺចំនួនជនជាប់ឃុំ ជៀសវាងមានការលួចដោះលែងជនជាប់ឃុំនោះដោយគ្មានការអនុញ្ញាត ព្រមទាំងបង្ការការឃុំខ្លួនខុសច្បាប់។ នៅពេលពិនិត្យចំនួនជនជាប់ឃុំព្រះរាជអាជ្ញាត្រូវធ្វើការផ្ទៀងផ្ទាត់តាមបញ្ជីឈ្មោះដែលធ្លាប់មានចុះទិដ្ឋាការ[79] ពីសំណាក់ព្រះរាជអាជ្ញា ដោយប្រធានពន្ធនាគារផ្តល់ឱ្យដោយហៅឈ្មោះម្តងម្នាក់រហូតដល់អស់។ បន្ថែមពីនេះ ពន្ធនាគារត្រូវមាន ប៉ុស្តិ៍សុខភាព ទីកន្លែងហាត់ប្រាណ បន្ទប់ឃុំឃាំងមានពន្លឺគ្រប់គ្រាន់ មានខ្យល់ធម្មជាតិ បន្ទប់អនាម័យ ទឹកស្អាត និងអគ្គិសនីសម្រាប់ប្រើប្រាស់។[80] ក្នុងករណីសមស្របពន្ធនាគារក៏អាចមានកន្លែងសម្រាប់គោរពជំនឿសាសនា បណ្ណាល័យ អគារសម្រាប់អប់រំ ឬបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញផ្សេងៗ។[81]

### ៣.១.២.កំហុសរបស់នគរបាលយុត្តិធម៌ និងការទទួលខុសវិន័យ

រាល់ការអនុវត្តការងារក្នុងក្របខណ្ឌអនុវត្តការបំពេញការងារ នគរបាលយុត្តិធម៌ដែលមានការប្រព្រឹត្តឡើងនូវកំហុសទាំងឡាយ ត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនដល់អគ្គព្រះរាជ-អាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីដែលជាអាណាព្យាបាលនៃនគរបាលយុត្តិធម៌នោះ ដើម្បីផ្តើមដំណើរការនីតិវិធីផ្នែកវិន័យ។ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិវិធីវិន័យនេះ។[82]

ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីដែលជាអាណាព្យាបាលនៃនគរបាលយុត្តិធម៌ មិនអាចជា

[78] មាត្រា៥០៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[79] មាត្រា២១, ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

[80] មាត្រា១១,១២ និងមាត្រា១៤, ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

[81] មាត្រា១៣, ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

[82] មាត្រា៦៤,៧៩ និងមាត្រា៨២ កថាខណ្ឌចុងក្រោយ, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ឧបសគ្គរារាំងដល់ការធ្វើបណ្តឹងអាជ្ញាទេបើករណីមានបទល្មើសព្រហ្មទណ្ឌណាមួយត្រូវបានប្រព្រឹត្ត។ កាលណានគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួនយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ដែលទទួលបន្ទុករឿងនោះ ត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូល ទៅឱ្យយុត្តាធិការផ្សេងចាត់ការវិញដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាល តុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី។ ពាក្យសុំដកសិទ្ធិនៃការផ្ទេរសំណុំរឿងអាចត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា។[83]

**ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌** នៅពេលដែលអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បានយល់ឃើញថាកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់មានសភាពធ្ងន់ធ្ងរ ឬមានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌នោះអគ្គព្រះរាជ-អាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍មានសិទ្ធិប្រកាសចេញសេចក្តីសម្រេចលើវិធានការដូចជា៖

១-ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត

២-ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។

មុននឹងចេញសេចក្តីសម្រេចខាងលើអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកនូវសេចក្តីសង្កេតរបស់មន្ត្រីនោះ។ មន្ត្រីនគរបាលយុត្តិធម៌អាចរកជំនួយពីមេធាវី ឬទីប្រឹក្សាម្នាក់ តាមការជ្រើសរើសរបស់ខ្លួន ដោយសេចក្តីសម្រេចពីការហាមឃាត់នេះត្រូវតែបញ្ជាក់សំអាងហេតុយ៉ាងត្រឹមត្រូវ។ សេចក្តីសម្រេចនេះត្រូវផ្តល់ជាដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ អាចបញ្ជូនយោបល់ទាក់ទងនឹងការដាក់វិន័យនគរបាលយុត្តិធម៌ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បាន។ សេចក្តីសម្រេចនេះសាមីមន្ត្រីនគរបាលយុត្តិធម៌ក៏អាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលដំណឹង អំពីសេចក្តីសម្រេចហាមឃាត់នោះ ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញាបាន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើក្នុងអំឡុងរយៈពេលយ៉ាងយូរបំផុត ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យប្តឹងតវ៉ា ដោយសេចក្តីសម្រេចនេះគឺបិទផ្លូវតវ៉ា។ ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ាមន្ត្រីនគរបាលយុត្តិធម៌ដែលរងវិន័យហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ឡើយ(ត្រូវបានផ្អាកការងារផ្នែកនគរបាលយុត្តិធម៌) ប្រសិនបើរដ្ឋមន្ត្រី

[83] មាត្រា៦៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់ មន្ត្រីនគរបាលយុត្តិធម៌នេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌វិញបាន។ ក្នុងករណីដែលកំពុងទទួលរងវិន័យនេះហើយរាល់កិច្ចនីតិវិធីទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌នោះបានបំពេញ ដោយបំពានសេចក្តីសម្រេចពីការហាមឃាត់របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវចាត់ទុកជាមោឃៈ។[84]

## ៣.២.ការអនុវត្តទោសរបស់តុលាការ

ព្រះរាជអាជ្ញាអាចដឹកនាំនគរបាលយុត្តិធម៌ដើម្បីអនុវត្តទោសដែលចេញដោយស្ថាប័នតុលាការបានដើម្បីធានាឱ្យការអនុវត្តមានភាពសព្វជ្រុងជ្រោយ ជាអាទិ៍រួមមាន (៣.២.១.ការជូនដំណឹងអំពីសាលក្រម) និង (៣.២.២.ការអនុវត្តសាលក្រម)។

### ៣.២.១.ការជូនដំណឹងអំពីសាលក្រម

ការជូនដំណឹងអំពីសាលក្រមអាចធ្វើឡើងដោយដីកាឱ្យដំណឹង កម្មវត្ថុនៃដីកាឱ្យដំណឹងគឺជាលិខិតដែលឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដែលបញ្ញត្តិច្បាប់តម្រូវឱ្យជូនដំណឹងដល់ភាគីពាក់ព័ន្ធដើម្បីឱ្យភាគីពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្តីសម្រេចនោះដោយតុលាការទុកសិទ្ធិដើម្បីប្តឹងឧទ្ធរណ៍។ ដីកាឱ្យដំណឹងត្រូវធ្វើតាមគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា ឬភាគី។[85]

ចំពោះដីកាឱ្យដំណឹងត្រូវចុះនិទ្ទេសដូចជាៈ

- ប្រភេទ និងការយោងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង
- អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង។

ដីកាឱ្យដំណឹងមានបញ្ជាក់ប្រាប់អំពីការដែលអាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចដែលត្រូវបានជូនដំណឹងនោះ។ លិខិតចម្លងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹងត្រូវភ្ជាប់ទៅនឹងដីកាឱ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការ។[86]

ការជូនដំណឹងដល់ភាគីពាក់ព័ន្ធអាចត្រូវធ្វើដោយព្រះរាជអាជ្ញា។ ក្នុងករណីនេះព្រះរាជអាជ្ញាប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការឱ្យដល់ភាគីពាក់ព័ន្ធ។ ព្រះរាជអាជ្ញាចុះនិទ្ទេសលើសេចក្តីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនេះ។[87]

[84] មាត្រា៦៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[85] មាត្រា៤៨២, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[86] មាត្រា៤៨៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[87] មាត្រា៤៨៤, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ការជូនដំណឹងក៏អាចត្រូវធ្វើឡើងដោយអាជ្ញាសាលាផងដែរ។ អាជ្ញាសាលាប្រើគ្រប់មធ្យោបាយ ដើម្បីជូនដំណឹងដល់បុគ្គលពាក់ព័ន្ធអំពីសេចក្តីសម្រេចរបស់តុលាការ។[88] ការប្រគល់ការជូនដំណឹងធ្វើតាមមធ្យោបាយដូចតទៅ៖

- ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ភាគីពាក់ព័ន្ធប្រសិនបើអាជ្ញាសាលាជួបប្រទះភាគីពាក់ព័ន្ធនៅក្នុងលំនៅឋាន ឬនៅទីកន្លែងដទៃទៀតអាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ភាគីពាក់ព័ន្ធ។ អាជ្ញាសាលាត្រូវចារកំណត់ចំណាំនៅលើសេចក្តីសម្រេចដើមថាលិខិតចម្លងត្រូវបានប្រគល់ឱ្យភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ។ ជាមួយគ្នានេះអាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់។[89]
- ករណីអវត្តមានភាគីពាក់ព័ន្ធ ប្រសិនភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន ឧទាហរណ៍.បងប្អូនពូមីង ជាដើម។ អាជ្ញាសាលាត្រូវចារលើសេចក្តីសម្រេចដើមថាលិខិតចម្លងនៃសេចក្តីសម្រេចត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ កាលបរិច្ឆេទប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួលលិខិតត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមជាការសម្គាល់។ សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុតតាមដែលអាចធ្វើទៅបាន។[90]
- អាជ្ញាសាលាប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំ ឬចៅសង្កាត់ ឬទៅជំទប់ ឬចៅសង្កាត់រងណាមួយនៅក្នុងករណីដូចជា៖
    - ភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច
    - គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ
    - គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធ យល់ព្រមទទួលសេចក្តីសម្រេចនោះទេ។ ករណីនេះអាជ្ញាសាលាចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្តីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការ

[88] មាត្រា៤៨៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[89] មាត្រា៤៨៦, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[90] មាត្រា៤៨៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ប្រគល់ទទួល។ បុគ្គលដែលទទួលលិខិតចម្លងចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនទៅព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចសន្យាថានឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។ លិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចតទៅៈ ឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួនដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រ ត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ។[91]

- ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ភាគីដែលពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬទីសំណាក់ទេ ឬបើភាគីពាក់ព័ន្ធនេះរស់នៅដែនដីក្រៅប្រទេស សេចក្តីសម្រេចរបស់តុលាការអាចត្រូវដំណឹងដល់សាមីខ្លួនបានផងដែរ។ ក្នុងករណីនេះកាលបរិច្ឆេទនៃសេចក្តីសម្រេចតុលាការត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង។ ក្នុងករណីដែលការប្រគល់ការជូនដំណឹងត្រូវបានតាមវិធីដូចដែលបានរៀបរាប់ខាងលើមានន័យថា ការជូនដំណឹងត្រូវបានធ្វើត្រឹមត្រូវតាមនីតិវិធីរួចហើយ។[92]

ក្រៅពីវិធីនៃការជូនដំណឹងខាងលើ ក៏មានរបៀបផ្សេងទៀតនៃការជូនដំណឹង ការជូនដំណឹងក៏អាចប្រគល់ឱ្យដែរៈ

- ដោយក្រឡាបញ្ជី
- តាមផ្លូវរដ្ឋបាល
- ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើគ្មានជាប់ចោទត្រូវឃុំខ្លួនពីបទដទៃផ្សេងទៀត
- ដោយអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។[93]

### ៣.២.២.ការអនុវត្តសាលក្រម

ក្នុងពេលបច្ចុប្បន្នការអនុវត្តសាលក្រមព្រះរាជអាជ្ញាជាអ្នកទទួលបន្ទុកអនុវត្ត ហើយការអនុវត្តមូលទោសមានភាពជាក់លាក់ដោយព្រះរាជអាជ្ញាទទួលបានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការដឹកនាំកងកម្លាំងសាធារណៈពិសេសនគរបាលយុត្តិធម៌ក្នុងការអនុវត្តសាលក្រមនោះ។[94] ជាមួយគ្នានេះផងដែរពុំមានបទដ្ឋានគតិយុត្តដែលកំណត់ឱ្យបានជាក់លាក់ទាក់ទងនឹងរបៀបរបប ព្រមទាំងនីតិវិធីនៅក្នុងការអនុវត្តទោសបន្ថែមទេ ដូចនេះ

[91] មាត្រា៤៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[92] មាត្រា៤៩០, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[93] មាត្រា៤៨៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[94] មាត្រា២៧, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ការអនុវត្តទោសបន្ថែមត្រូវប្រតិបត្តិទាំងស្រុងលើសេចក្ដីសម្រេចរបស់យុត្តាធិការជំនុំជម្រះ ដោយសេចក្ដីសម្រេចដែលសម្រេចអំពីទោសនេះយ៉ាងណា ដូច្នេះយុត្តាធិការជំនុំជម្រះសម្រេចអំពីទោសបន្ថែម ឬទោសជំនួសបែបណានោះព្រះរាជអាជ្ញាដឹកនាំមន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តទៅតាមខ្លឹមសារនៃសេចក្ដីសម្រេចនោះបាន។[95]

### ៣.២.២.១.ការអនុវត្តមូលទោស

ការអនុវត្តមូលទោសយោងតាម មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ បានកំណត់មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ដូច្នេះការអនុវត្តមូលទោសគឺសំដៅទៅលើ ការអនុវត្តនូវទោសពន្ធនាគារជាកម្មវត្ថុនៃការដកហូតសិទ្ធិសេរីភាព និងការអនុវត្តទោសពិន័យជាប្រាក់បង្គាប់ឱ្យបង់ថវិការចូលរដ្ឋ។

#### ក.ការអនុវត្តទោសពន្ធនាគារ

ពន្ធនាគារ គឺជាកន្លែងដែលបង្កើតឡើងស្របច្បាប់ សម្រាប់ឃុំអ្នកទោសតាមអំណាច នៃសាលក្រម ឬការសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការ។ ពន្ធនាគារមិនមែនជាកន្លែងសម្រាប់ស៊ើបអង្កេតស្រាវជ្រាវសួរចម្លើយ ឬធ្វើទារុណកម្ម និងមិនមែនជាកន្លែងសម្រាប់ឃាត់ខ្លួនជនសង្ស័យរយៈពេល ៤៨ ម៉ោង (ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌) នោះឡើយ។ ការអនុវត្តមូលទោសក៏ត្រូវអនុវត្តករណីមានការព្យួរទោសផងដែរ ដោយព្រះរាជអាជ្ញាត្រូវធ្វើការត្រួតពិនិត្យទៅលើវិធានការដែលតម្រូវទៅលើទណ្ឌិតមានដូចតទៅ៖

- ចេញដីកាកោះចំពោះទណ្ឌិតដែលត្រូវបានព្យួរទោស
- ពិនិត្យឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្ដូរអាសយដ្ឋានរស់នៅរបស់ខ្លួន
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្ដូរមុខរបររបស់ខ្លួន
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។[96]

ដំណើរការនៃការអនុវត្តទោសពន្ធនាគារ ការទទួល ឬការឃុំខ្លួនជនណាម្នាក់នៅក្នុងពន្ធនាគារបានលុះត្រាតែមានលិខិតឃុំខ្លួនដែលចេញពីស្ថាប័នតុលាការ។[97] ជាគោលការណ៍ ការអនុវត្តសេចក្ដីសម្រេចរបស់តុលាការគឺជាតួនាទីរបស់ស្ថាប័នអយ្យការ ប៉ុន្តែដើម្បីឱ្យការអនុវត្តសេចក្ដីសម្រេចនេះ មានដំណើរការល្អប្រកបដោយភាពគ្រប់ជ្រុងជ្រោយ គឺត្រូវមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាច្រើនពិសេសគឺអង្គភាពនគរបាលយុត្តិធម៌។

---

[95] មាត្រា៤៩៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[96] មាត្រា១១៩, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[97] មាត្រា១៧, ច្បាប់ស្ដីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

វិធានទាក់ទងនឹងការឃុំខ្លួន គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន និរទេសខ្លួនដោយបំពានឡើយ ទទួលទារុណកម្ម ទណ្ឌកម្ម ប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ។[98] ជាគោលការណ៍ ការឃុំខ្លួនបុគ្គលណាម្នាក់ដាច់ខាតត្រូវតែមានលិខិតដែលចេញដោយអាជ្ញាធរតុលាការ មានន័យថាមុនពេលដែលទទួលយកជនជាប់ឃុំ ឬទណ្ឌិតចូលពន្ធនាគារ ប្រធានពន្ធនាគារ ឬមន្ត្រីពន្ធនាគារដែលទទួលបានការចាត់តាំង ត្រូវត្រួតពិនិត្យរាល់អត្តសញ្ញាណជននោះឱ្យបានត្រឹមត្រូវតាមលិខិតបង្គាប់ឱ្យឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ។ ក្នុងច្បាប់ក៏បានបញ្ញត្តិផងដែរ គ្មានភ្នាក់ងាររដ្ឋបាលពន្ធនាគារណាអាចទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការបានឡើយ។ ភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលបានទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធតុលាការទេនោះ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ចិរវេលានៃការដាក់ពន្ធនាគារត្រូវគោរពតាមដូចខាងក្រោម៖

- ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានចិរវេលា ២៤ (ម្ភៃបួន) ម៉ោង
- ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ខែ មានចិរវេលា ៣០ (សាមសិប) ថ្ងៃ
- ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ
- ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំត្រូវគិត ១២ (ដប់ពីរខែ)[99]
- ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ ព្រឹក ដល់ម៉ោង ១៨ ល្ងាច។[100]

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នដោយចៅក្រមស៊ើបសួរត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងចិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃចិរវេលាសរុបនៃទោសដែលត្រូវទទួលរងបន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា។[101] នេះជាការការពារនូវផលប្រយោជន៍របស់ទណ្ឌិត ដែលត្រូវបានដកហូតសេរីភាពនៅក្នុងដំណើរការនីតិវិធីមុខសាលក្រមស្ថាពរ។

### ខ.ការអនុវត្តទោសពិន័យជាប្រាក់

ការប្រមូលប្រាក់ពិន័យ និងពន្ធនីតិវិធីប្រសិនបើមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយ

[98] មាត្រា៥ និងមាត្រា៩, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
[99] មាត្រា៤៩, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
[100] មាត្រា៥០២ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
[101] មាត្រា៥០៣, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ដល់ទណ្ឌិត ដើម្បីបង់ប្រាក់ហើយឱ្យដំណឹងថាប្រសិនបើមិនបង់ទេសាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយដើម្បីដាក់សម្ពាធឱ្យជននោះបង់ប្រាក់តាមច្បាប់ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃទេ។ ការឱ្យដំណឹងត្រូវធ្វើដោយៈ

- ដោយផ្ទាល់មាត់
- តាមផ្លូវរដ្ឋបាល
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

ត្រូវតែមានធ្វើកំណត់ហេតុស្ដីពីការឱ្យដំណឹងនេះ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេ ទណ្ឌិតត្រូវផ្ដិតម្រាមដៃជំនួស។[102]

ការបង្ខំរូបកាយគឺជាការអនុវត្តដោយពេញលក្ខណៈច្បាប់ ទៅលើបុគ្គលដែលត្រូវផ្ដន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ដែលមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។ នៅពេលផុតរយៈពេលកំណត់ ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេព្រះរាជអាជ្ញាចេញបញ្ជាដល់កម្លាំងសាធារណៈ ព្រមទាំងមន្ត្រីនគរបាលយុត្តិធម៌ ឱ្យបង្ខំ និងឱ្យឃុំខ្លួនទណ្ឌិតនោះ ដោយមានចុះហត្ថលេខាដោយព្រះរាជអាជ្ញាផ្ទាល់ និងមានបោះត្រាស្ថាប័នអយ្យការផងដែរ។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្ដីសម្រេចនេះបានដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាពក្ដី។ កាលណាការបង្ខំដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើននោះ ចិរវេលានៃការបង្ខំនេះ ត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម។[103]

ការរួចផុតពីការបង្ខំរូបកាយ អនុវត្តលើទណ្ឌិតជាអនីតិជន ស្ត្រីដែរមានអាយុចាប់ពី ៦៥ ឆ្នាំ ឡើងទៅ និងបុរសអាយុចាប់ពី ៧០ ឆ្នាំ ឡើងទៅបានឡើយ។ ការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្ដី និងប្រពន្ធបានទេ ទោះបីជាការបង្ខំនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ ការកំណត់បែបនេះដើម្បីទុកលទ្ធភាពឱ្យសហព័ទ្ធម្ខាងទៀតមានឱកាសក្នុងការស្វែងរកប្រាក់ដើម្បីបង់បាន។[104]

#### ៣.២.២.២.ការអនុវត្តទោសបន្ថែម

ព្រះរាជអាជ្ញាអាចដឹកនាំមន្ត្រីនគរបាលយុត្តិធម៌ធ្វើការអនុវត្តទោសបន្ថែមតាមរយៈសាលក្រមដែលសម្រេចដោយយុត្តាធិការជំនុំជម្រះ មានន័យថានៅពេលដែលតុលាការចេញសាលក្រមដែលសម្រេចអំពីទោសបន្ថែម ដូចនេះព្រះរាជអាជ្ញាធ្វើការអនុវត្តនូវទោសបន្ថែមដោយផ្អែកលើខ្លឹមសារនៃសាលក្រម។ ទោសបន្ថែម

[102] មាត្រា៥២៥, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[103] មាត្រា៥៣០, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[104] មាត្រា៥៣១, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ក្នុងសាលក្រម សំដៅលើទោសដែលត្រូវបន្ថែមលើមូលទោស។ ទោសបន្ថែមអាចនឹងប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះ បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បានទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។[105]

ប្រភេទនៃទោសបន្ថែមរួមមានដូចជា៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្តក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ
- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ
- ការព្យួរលិខិតបើកបរ
- ការហាមឃាត់ចំពោះការស្នាក់នៅ
- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់នៅក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ
- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។[106]

[105] មាត្រា៥៤, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[106] មាត្រា៥៣, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

### ៣.២.២.៣.ការអនុវត្តទោសជំនួស

ទោសជំនួសគឺជាទោសដែលតុលាការយកមកអនុវត្តជំនួសឱ្យមូលទោសក្នុងករណីនេះតុលាការមិនអាចប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទៀតទេ។ ទោសជំនួសមាន ២ ប្រភេទ រួមមាន៖

#### ក.ការអនុវត្តការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាចង្អុលឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។[107] ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ដោយមានអង្គភាពនគរបាលយុត្តិធម៌ជាសេនាធិការ។ ការងារសហគមន៍ជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីរយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀតដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល។ កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍។[108] វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍អាចនឹងប្រកាសបានលុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការហើយយល់ព្រមទទួលធ្វើការងារនេះ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះផងដែរ(ត្រូវចុះសម្គាល់នៅក្នុងសាលក្រម ឬសាលដីកា)។[109] តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីចិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញមិនអាចលើសពី ១ (មួយ) ឆ្នាំឡើយ។[110]

#### ខ.ការអនុវត្តការស្តីបន្ទោស

ការស្តីបន្ទោសអនុវត្តជំនួសឱ្យមូលទោស។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចដាក់ទោសពន្ធនាគារ ឬពិន័យជាប្រាក់បន្ថែមបានទេ។[111] កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោសប្រសិនបើមានគ្រប់លក្ខខណ្ឌទាំង ៣ ដូចខាងក្រោម៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់រួចរាល់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង

[107] មាត្រា១០៣, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
[108] មាត្រា៧២, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
[109] មាត្រា១០១, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
[110] មាត្រា១០២, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
[111] មាត្រា៩៨, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

- ជនជាប់ចោទបានបង្ហាញពីការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។[112]

បន្ទាប់ពីទណ្ឌិតអនុវត្តទោសចប់សព្វគ្រប់រួចហើយ ព្រះរាជអាជ្ញាត្រូវចេញដីកាបង្គាប់ឱ្យដោះលែងជននោះជាបន្ទាន់ប្រសិនបើជននេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ។ ក្នុងស្ថានភាពនៃការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ននេះមិនទាន់មានការអនុវត្តនូវទោសជំនួសនៅឡើយនោះទេ។

[112] មាត្រា៩៨, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងធ្វើការស្វែងយល់យ៉ាងលម្អិតរួចហើយទៅលើប្រធានបទទាំងមូលស្តីពី "អំណាចព្រះរាជអាជ្ញាដឹកនាំនីតិវិធីរបស់នគរបាលយុត្តិធម៌" យើងឃើញថានគរបាលយុត្តិធម៌មាន ៣ (បី) សមាសភាពដែលមានដូចជា មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌។ ទំនាក់ទំនងការងាររវាងនគរបាលយុត្តិធម៌ ពិសេសមន្ត្រីនគរបាលជាតិ និងកងរាជអាវុធហត្ថ ដែលជាមន្ត្រីនគរបាលយុត្តិធម៌ ជាមួយនឹងព្រះរាជអាជ្ញា ក្នុងរឿងក្តីព្រហ្មទណ្ឌជាសង្វាក់ការងារដែលមិនអាចកាត់ផ្តាច់ពីគ្នាបាន។

នៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ គឺពិតជាដំណាក់កាលមួយដ៏សំខាន់ដែលកាលៈទេសៈមួយចំនួនត្រូវបានដឹកនាំសម្របសម្រួលប្រតិបត្តិការនីតិវិធីដោយព្រះរាជអាជ្ញា ព្រោះនគរបាលយុត្តិធម៌គឺជាជំនួយការមិនអាចខ្វះបានរបស់អំណាចតុលាការ។ លើសពីនេះទៅទៀតនគរបាលយុត្តិធម៌ដែលមានការដឹកនាំដោយព្រះរាជអាជ្ញា បានដើរតួនាទីយ៉ាងត្រឹមត្រូវតាមច្បាប់ក្នុងការទប់ស្កាត់បទល្មើស បង្ក្រាបបទល្មើស និងបង្ការបទល្មើសមិនឱ្យកើតឡើងសារជាថ្មី ធ្វើការត្រួតពិនិត្យ បទឧក្រិដ្ឋ បទមជ្ឈិម បទលហុកំណត់អត្តសញ្ញាណ ចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង ធ្វើការសាកសួរជនល្មើស សាក្សី និងធ្វើកំណត់ហេតុ បញ្ជូនភស្តុតាង និងជនល្មើសទៅកាន់តំណាងអយ្យការ។ នៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌណាមួយ គឺជាសកម្មភាពដ៏សកម្ម ឬក៏ជាបេសកកម្មរបស់នគរបាលយុត្តិធម៌។ ជាមួយគ្នានេះនៅក្នុងដំណើការស៊ើបអង្កេតបទល្មើសនីមួយៗ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ដោយគ្រាន់តែមានតម្រុយមួយចំនួន ឬទទួលពាក្យបណ្តឹងពីជនរងគ្រោះផ្ទាល់ព្រមទាំងតតិយជន ឬអាចជាជនអនាមិកដែលបានរាយការណ៍ជូនមកមន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់។ នគរបាលយុត្តិធម៌ ត្រូវបែងចែកនឹងកំណត់ឱ្យបានច្បាស់លាស់ថា បទល្មើសនោះ ជាបទល្មើសជាក់ស្តែង ឬបទល្មើសបឋម បើមិនដូច្នេះនីតិវិធីនឹងត្រូវធ្វើជាមោឃៈ ពីព្រោះក្នុងបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌មានអំណាចធំធេងណាស់ដោយសារតែភាពបន្ទាន់នៃបទល្មើស ក្នុងគោលការណ៍បង្ការបង្ក្រាបទៅលើបទល្មើសនោះ។ ពាក់ព័ន្ធនឹងការឆែកឆេរ ត្រូវធ្វើទៅតាមនីតិវិធីនៃច្បាប់ដែលបានចែង ពិតជាសំខាន់ណាស់ ដើម្បីកុំឱ្យក្លាយជាកម្មវត្ថុនៃមោឃភាពនីតិវិធី។ ចំពោះការស៊ើបអង្កេតនីមួយៗមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែត្រួតពិនិត្យឱ្យបានច្បាស់លាស់នូវនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ប្រសិនបើការស៊ើបអង្កេតណាមួយមិនស្របនឹងនីតិវិធីដែលមានចែងនៅក្នុងច្បាប់ទេ ពេលនោះការស៊ើបអង្កេតនឹងត្រូវចាត់ទុកជាមោឃៈ។ មិនត្រឹមតែប៉ុណ្ណោះ នគរបាលយុត្តិធម៌ក៏បានចូលរួមយ៉ាងសកម្មដល់ការអនុវត្តសេចក្តីសម្រេចរបស់តុលាការផងដែរ ជាអាទិ៍ សាលក្រមព្រហ្មទណ្ឌ។

ព្រះរាជអាជ្ញាជាអង្គប្រតិបត្តិខាងផ្នែកព្រហ្មទណ្ឌដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ឱ្យមានសិទ្ធិអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌បានដើម្បីធានាដល់ភាពស្របតាមច្បាប់។ បន្ថែមពីនេះនគរបាលយុត្តិធម៌ស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ដែលជាអ្នកអនុវត្តអំណាចខាងវិន័យនានា ព្រមទាំងដកហូតសិទ្ធិជានគរបាលយុត្តិធម៌។

សរុបសេចក្តីមក យើងអាចធ្វើការសន្និដ្ឋានបានថាគ្រប់បេសកកម្មរបស់នគរបាលយុត្តិធម៌ទាំងឡាយដែលភាគច្រើនដឹកនាំដោយព្រះរាជអាជ្ញាបានបកស្រាយ គឺវាពិតជាមានអត្ថន័យដែលបេសកកម្មនីមួយៗរបស់ពួកគាត់ពិតជាបានចូលរួមយ៉ាងសកម្មក្នុងការបង្ការ បង្ក្រាប និងការពាររក្សាសណ្តាប់ធ្នាប់សាធារណៈធានាការប្រព្រឹត្តទៅនៃដំណើរការអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋឱ្យមានភាពស្មើគ្នា ព្រមទាំងធានាក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ និងចូលរួមយ៉ាងសំខាន់ក្នុងការពង្រឹងនូវនីតិរដ្ឋ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការស្រាវជ្រាវ និងសិក្សាឈ្វេងយល់ចំពោះប្រធានបទដែលទាក់ទងនឹង "អំណាចព្រះរាជអាជ្ញាដឹកនាំនីតិវិធីរបស់នគរបាលយុត្តិធម៌" ជាចុងក្រោយបំផុតក្នុងគោលបំណង និងឆន្ទៈដើម្បីធ្វើឱ្យស្នាដៃមួយនេះអាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវ សមស្របទៅនឹងស្ថានភាពប្រទេសនាពេលបច្ចុប្បន្ន រួមទាំងកាលៈទេសៈជាក់ស្តែង ដើម្បីចែករំលែកនូវគំនិតខ្លះៗ ខ្ញុំបាទសូមការអនុញ្ញាតលើកឡើងនូវសំណូមពរនានាដូចខាងក្រោមៈ

- សូមសំណូមពរដល់ក្រសួងស្ថាប័នជាអាណាព្យាបាលនៃនគរបាលយុត្តិធម៌ឱ្យត្រួតពិនិត្យជាប្រចាំនគរបាលយុត្តិធម៌ ព្រមទាំងសម្របសម្រួលនៃការស្នើសុំនីតិសម្បទាដល់មន្ត្រីដែលមានគុណសម្បត្តិ
- សូមសំណូមពរដល់ស្ថាប័នអយ្យការគ្រប់លំដាប់ថ្នាក់ដែលមានសមត្ថកិច្ចលើអង្គភាពនគរបាលយុត្តិធម៌ដឹកនាំសម្របសម្រួលដល់នគរបាលយុត្តិធម៌តាមដែលអាចធ្វើទៅបាន រួមទាំងផ្តល់ការបណ្តុះបណ្តាលឬចែករំលែកចំណេះដឹងនៃការអនុវត្តនីតិវិធីច្បាប់នានា ពិសេសផ្នែកនីតិវិធីព្រហ្មទណ្ឌ
- សូមសំណូមពរដល់ក្រសួងស្ថាប័នជាអាណាព្យាបាលនៃនគរបាលយុត្តិធម៌បំពាក់នូវសម្ភារៈគ្រប់គ្រាន់ដោយយកចិត្តទុកដាក់ពីសុវត្ថិភាពរបស់នគរបាលយុត្តិធម៌ នៅពេលដែលពួកគាត់ចុះបំពេញបេសកកម្មក្នុងការបង្ក្រាបបទល្មើសដោយធ្វើយ៉ាងណាឱ្យពួកគាត់ទទួលបាននូវសម្ភារៈសម្រាប់ការពារខ្លួនបានគ្រប់គ្រាន់នានាដើម្បីបង្ការគ្រោះថ្នាក់
- សូមសំណូមពរដល់នគរបាលយុត្តិធម៌ទាំងអស់បំពេញការងារដោយយកចិត្តទុកដាក់ពិសេសលើផ្នែកនីតិវិធី ព្រមទាំងធ្វើការកំណត់បទល្មើសឱ្យបានច្បាស់លាស់ មុននឹងបើកការស៊ើបអង្កេតណាមួយថាអំពើល្មើសនោះ ជាបទល្មើសជាក់ស្តែង ឬបទល្មើសបឋម ឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីនៃច្បាប់ជៀសវាងការមោឃភាពនៃនីតិវិធី បើមានការកំណត់ខុសនោះកិច្ចការនិងការខិតខំប្រឹងប្រែងរបស់គាត់ទាំងឡាយដែលបានធ្វើនិងអាចក្លាយជាកម្មវត្ថុនៃការស្នើសុំមោឃភាព មានន័យថា ត្រូវចាត់ទុកជាឥតបានការ។ ដោយផលវិបាកនីតិវិធីមានច្រើន ប្រសិនបើមានការមោឃភាពមែនជននោះនឹងទទួលផលប្រយោជន៍ដូចជា ជននោះនឹងស្ថិតនៅក្នុងស្ថានភាពមួយដែលកង្វះខាតនៃភស្តុតាងដាក់បន្ទុកគាត់ និងការចោទប្រកាន់លែងមានមូលដ្ឋានរឹងមាំធ្វើឱ្យជននោះត្រូវបានដោះលែង
- សូមសំណូមពរដល់នគរបាលយុត្តិធម៌ទាំងអស់ឱ្យលុបបំបាត់ចោលនូវ អំពើពុករលួយ ជាពិសេសពាក់ព័ន្ធនឹងអ្នកធ្វើកំណត់ហេតុ អ្នកធ្វើកោសលវិច្ឆ័យ ដើម្បីឱ្យការស៊ើបអង្កេតប្រកបទៅដោយយុត្តិធម៌ល្អបំផុត បន្ថែមពីនេះបានធ្វើឱ្យប្រទេសជាតិមានតម្លាភាព និងនីតិរដ្ឋ

- សូមឱ្យនគរបាលយុត្តិធម៌ទាំងអស់ មេត្តាព្យាយាមរក្សាទុកនៅលេខទូរស័ព្ទ ឬបណ្តាញទំនាក់ទំនងរបស់ព្រះរាជអាជ្ញាដែលជាអ្នកដឹកនាំ សម្របសម្រួលការងាររបស់ខ្លួន ដើម្បីងាយស្រួលទំនាក់ទំនងគ្នានៅពេលមានបទល្មើសជាក់ស្តែងកើតឡើង។ មួយវិញទៀតនគរបាលយុត្តិធម៌គួរតែផ្សព្វផ្សាយលេខទូរស័ព្ទរបស់ខ្លួនទៅប្រជាពលរដ្ឋដែលស្ថិតនៅមូលដ្ឋានរបស់ខ្លួន ដើម្បីបង្កលក្ខណៈងាយស្រួលដល់ពួកគាត់ក្នុងការទាក់ទង នៅពេលដែលពួកគាត់ជួបប្រទះបទល្មើសណាកើតឡើងជាយថាហេតុ
- សូមឱ្យប្រជាពលរដ្ឋធ្វើការសហការគ្នាជាមួយនគរបាលយុត្តិធម៌ នៅពេលឃើញបទល្មើព្រហ្មទណ្ឌណាមួយកើតឡើងសូមប្រញាប់រាយការណ៍ភ្លាមទៅកាន់នគរបាលយុត្តិធម៌ ឬមន្ត្រីទាំងឡាយដែលមានសមត្ថកិច្ច ដែលនៅជិតទីបំផុត ដើម្បីឱ្យពួកគាត់ចុះធ្វើការស៊ើបអង្កេត និងបំបែកសំណុំរឿងបានឆាប់រហ័ស និងមានប្រសិទ្ធភាព
- សូមឱ្យប្រជាពលរដ្ឋទាំងអស់រួមគ្នាអនុវត្តច្បាប់ទាំងឡាយរបស់រដ្ឋដែលមានចែង ព្រមទាំងជៀសឆ្ងាយពីការប្រព្រឹត្តបទល្មើសពីព្រោះការប្រព្រឹត្តបទល្មើសវាអាចជះឥទ្ធិពលអាក្រក់ដល់ខ្លួនឯងគ្រួសារ និងសង្គមជាតិជាខ្លាំង។ ការចូលរួមក្នុងការអនុវត្តច្បាប់ គឺវាបានចូលរួមចំណែកក្នុងការធ្វើឱ្យសង្គមជាតិមានភាពសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងមនុស្សរស់នៅក្នុងសង្គមប្រកបដោយភាពសុខដុមរមនា។ លើសពីនេះទៀត សូមប្រជាពលរដ្ឋគ្រប់រូប ព្យាយាមសិក្សាស្វែងយល់ឱ្យបានជាអតិប្បរមាពាក់ព័ន្ធនឹងវិស័យច្បាប់អាទិ៍មាន ច្បាប់ព្រហ្មទណ្ឌ ពីព្រោះថាវាមានការទាក់ទងទៅនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នា ចំណេះដឹងផ្នែកនេះអាចបង្ការ និងការពារខ្លួនឯងផ្ទាល់ពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយកម្រិតផងដែរ ពីព្រោះតែការដឹងអំពីផលវិបាកទាំងឡាយក្រោយពីបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនេះ។

# ឯកសារយោង

# ឯកសារយោង

## ១.លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៨០៧/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០១១៦/០០១ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

## ២.ឯកសារមេរៀនជំនួយ

- មេរៀននីតិវិធីព្រហ្មទណ្ឌ លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត
- សៀវភៅនីតិព្រហ្មទណ្ឌទូទៅរបស់ លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត ឆ្នាំ២០២២
- សៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់លោក មីន សំអុល ឆ្នាំ២០២៣
- ប្រសាសន៍របស់អ្នកនាំពាក្យក្រសួងយុត្តិធម៌លោក ជិន ម៉ាលីន កាលពីខែកក្កដា ថ្ងៃទី៧ ឆ្នាំ២០១៩ តាមរយៈអាស៊ីសេរី (RFA)
- អត្ថបទ មូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌ លោកមេធាវី ទៀង វុទ្ធា
- អត្ថបទព័ត៌មានយល់ដឹងផ្នែកច្បាប់សាលាជម្រះក្តី លោក កុយ នាម
- អត្ថបទដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ឧត្តមសេនីយ៍ត្រី អាន សូរីដា
- អត្ថបទនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោក អៀង សំណាង អនុបណ្ឌិតនីសាស្ត្រ
- នីតិវិធីសង្ខេបរដ្ឋប្បវេណី និងព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅតាមសាលាជម្រះក្តីនានា, រៀបរៀងដោយ លោកចៅក្រម ជួន សុភាសី, បោះពុម្ពលើកទី២ ខែកញ្ញា ឆ្នាំ២០១១
- សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និងលោក ខាន់ សុខា។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ

១. គំរូប្រកាសអន្តរក្រសួងស្តីពី ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ

២. គំរូប្រកាសអន្តរក្រសួងស្តីពី ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីនគរបាលជាតិ នៃក្រសួងការពារជាតិ

៣. គំរូប្រកាសអន្តរក្រសួងស្តីពី ការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ ដល់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន

៤. គំរូសញ្ញាបត្រជាន់ខ្ពស់នគរបាលយុត្តិធម៌ របស់មន្ត្រីនគរបាលជាតិ

៥. គំរូសញ្ញាបត្រជាន់ខ្ពស់នគរបាលយុត្តិធម៌ របស់កងរាជអាវុធហត្ថ

៦. គំរូកំណត់ហេតុស្តីពីការធ្វើសម្បថរបស់នគរបាលយុត្តិធម៌

៧. គំរូកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌

៨. គំរូកំណត់ហេតុទទួលវត្ថុចាប់យក

៩. គំរូកំណត់ដីកាសម្រេចឆែកឆេរលំនៅដ្ឋាន

១០. គំរូលិខិតកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌

១១. គំរូដីកាបញ្ជាឱ្យចូលខ្លួនចេញដោយព្រះរាជអាជ្ញា

១២. គំរូដីកាបង្គាប់ឱ្យស៊ើបអង្កេតបឋម

១៣. គំរូលិខិតបញ្ជាបេសកកម្មរបស់អង្គភាពនគរបាលយុត្តិធម៌

១៤. គំរូដីកាអមបញ្ជូនកំណត់ហេតុនានា

១៥. គំរូបញ្ជូនខ្លួនជនសង្ស័យ

១៦. គំរូកំណត់ហេតុសាកសួរចម្លើយរបស់ព្រះរាជអាជ្ញា

១៧. គំរូដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ

១៨. គំរូដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

១៩. គំរូដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

២០. គំរូកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម

២១. គំរូចុះទិដ្ឋាការអធិការកិច្ចលើអង្គភាពនគរបាលយុត្តិធម៌

២២. គំរូដីកាឱ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការ

២៣. គំរូដីកាដោះលែងទណ្ឌិត។

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ

លេខ : គ.យ.ស:មជ.ប្រក/៦៣

## ប្រកាសអន្តរក្រសួង
## ស្ដីពី
## ការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១ ..**

ត្រូវបានផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់ អត្តលេខ អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។



មហាវិថីសម្ដេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

**ប្រការ២ ..**

មុននឹងបំពេញមុខងារ មន្ត្រីដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដូចមានកំណត់ក្នុងប្រការ១ខាងលើ ដែលមិនទាន់បានបំពេញនីតិវិធីសម្បថ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ស្របតាមបញ្ញត្តិមាត្រា ៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ប្រការ៣ ..**

មន្ត្រីដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដូចមានកំណត់ក្នុងប្រការ១ខាងលើ មានសមត្ថកិច្ចដែនដីនៅលើវិសាលភាព នៃមណ្ឌលរដ្ឋបាល ដែលមន្ត្រីនោះត្រូវចាត់តាំងឱ្យទៅបម្រើការងារ ហើយត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

គ្រប់អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ គ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ KA

ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

ក្រសួងការពារជាតិ

លេខ : ‌ /គយស.គពជ.ប្រក/៧៣

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់នីតិសម្បទាជា មន្ត្រីនគរបាលយុត្តិធម៌

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីការកិច្ច និងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ។

## សម្រេច

**ប្រការ១ ..**

ត្រូវបានផ្តល់នីតិសម្បទាជា មន្ត្រីនគរបាលយុត្តិធម៌ ដល់នាយទាហាននៃកងរាជអាវុធហត្ថចំនួន ១០៤ រូប ស្របតាមមាត្រា៦០ និង មាត្រា៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូចមានរាយនាមខាងក្រោម៖



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | ឋានន្តរសក្តិ | មុខតំណែង |
|---|---|---|---|---|---|
| ១ | | ប្រុស | ០៥.០៥.៧២ | វរសេនីយ៍ឯក | មេបញ្ជាការរង កងរាជអាវុធហត្ថ ខេត្តតាកែវ |
| ២ | | ប្រុស | ១១.០៩.៨០ | វរសេនីយ៍ទោ | នាយរងសេនាធិការ ទទួលការងារព័ត៌មានសន្តិសុខ ខេត្តមណ្ឌលគីរី |
| ៣ | | ប្រុស | ០២.០២.៧៤ | វរសេនីយ៍ត្រី | មេបញ្ជាការ មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង |
| ៤ | | ប្រុស | ០៤.០៥.៨៩ | វរសេនីយ៍ត្រី | ជំនួយការ មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកបាទី ខេត្តតាកែវ |
| ៥ | | ប្រុស | ១២.០១.៨១ | វរសេនីយ៍ត្រី | ជំនួយការ ការិយាល័យបទល្មើសគ្រឿងញៀន មន្ទីរយុត្តិធម៌ |
| ៦ | | ប្រុស | ០៣.០១.៨៤ | វរសេនីយ៍ត្រី | ជំនួយការ មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកកំពង់សិលា ខេត្តព្រះសីហនុ |
| ៧ | | ប្រុស | ០៤.០៤.៨៦ | វរសេនីយ៍ត្រី | ជំនួយការ ការិយាល័យបទល្មើសព្រហ្មទណ្ឌ មន្ទីរយុត្តិធម៌ រាជធានីភ្នំពេញ |
| ៨ | | ប្រុស | ០៣.០៣.៨០ | វរសេនីយ៍ត្រី | នាយការិយាល័យ ព័ត៌មាន និងសន្តិសុខ ខេត្តសៀមរាប |
| ៩ | | ប្រុស | ០៥.០៣.៧៩ | វរសេនីយ៍ត្រី | អនុប្រធានមន្ទីរយុត្តិធម៌ ខេត្តសៀមរាប |
| ១០ | | ប្រុស | ១៤.០៦.៩៤ | អនុសេនីយ៍ឯក | អនុប្រធានមន្ទីរ បច្ចេកទេសសន្តិសុខ ខេត្តកណ្ដាល |
| ១១ | | ប្រុស | ០៨.០៨.៨១ | អនុសេនីយ៍ឯក | មេបញ្ជាការរង មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកពញាឮ កងរាជអាវុធហត្ថ ខេត្តកណ្ដាល |
| ១២ | | ប្រុស | ១១.០៧.៨០ | អនុសេនីយ៍ឯក | មេបញ្ជាការរង មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ |
| ១៣ | | ប្រុស | ០១.០២.៧៩ | អនុសេនីយ៍ឯក | មេបញ្ជាការរង មូលដ្ឋានកងរាជអាវុធហត្ថ ក្រុងក្រចេះ ខេត្តក្រចេះ |

| | | | | | |
|---|---|---|---|---|---|
| | | | | | មន្ទីរយុត្តិធម៌ ខេត្តស្វាយរៀង |
| ៩៧ | | ស្រី | ០៥.១២.៩០ | អនុសេនីយ៍ត្រី | ជំនួយការ ការិយាល័យបទល្មើសព្រហ្មទណ្ឌ មន្ទីរយុត្តិធម៌ ខេត្តស្វាយរៀង |
| ៩៨ | | ប្រុស | ១១.០៨.៨២ | នាយចំណង់ | ជំនួយការ កងពលតូចការពារ ខេត្តតាកែវ |
| ៩៩ | | ស្រី | ០៩.០៦.៩០ | នាយចំណង់ | ជំនួយការ ការិយាល័យបទល្មើសព្រហ្មទណ្ឌ មន្ទីរយុត្តិធម៌ ខេត្តកំពង់ឆ្នាំង |
| ១០០ | | ប្រុស | ០២.១០.៨៨ | នាយចំណង់ | ជំនួយការ មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង |
| ១០១ | | ប្រុស | ១៥.០៨.៨៨ | នាយចំណង់ | ជំនួយការ ការិយាល័យបទល្មើសគ្រឿងញៀន មន្ទីរយុត្តិធម៌ ខេត្តកំពង់ធំ |
| ១០២ | | ប្រុស | ០៥.០៥.៩៤ | នាយចំណង់ | នាយទាហាន មូលដ្ឋានកងរាជអាវុធហត្ថ ក្រុងសួង ខេត្តត្បូងឃ្មុំ |
| ១០៣ | | ប្រុស | ១០.០៧.៨៦ | នាយចំណង់ | ជំនួយការ មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ១០៤ | | ប្រុស | ១០.១១.៨៧ | នាយចំណង់ | នាយរងក្រុម២ កងពលតូច១ កងពលធំប្រតិបត្តិការ៤ កងអន្តរាគមន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស |

**ប្រការ២ .-**

មុននឹងបំពេញមុខងារ មន្ត្រីនគរបាលយុត្តិធម៌ ដូចមានកំណត់ក្នុងប្រការ១ ខាងលើ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ស្របតាមបញ្ញត្តិមាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ប្រការ៣ .-**

មន្ត្រីនគរបាលយុត្តិធម៌ ដូចមានកំណត់ក្នុងប្រការ១ ខាងលើមានសមត្ថកិច្ចដែនដី នៅលើវិសាលភាពនៃមណ្ឌលរដ្ឋបាលដែលមន្ត្រីនោះ ត្រូវចាត់តាំងឱ្យទៅបម្រើការងារ លើកលែងតែការពន្លាតសមត្ថកិច្ចដែនដីដូចមានចែងក្នុងមាត្រា៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ប្រការ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

គ្រប់អង្គភាពក្រោមឱវាទក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌ សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៥រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

កើត រិទ្ធ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា ទៀ បាញ់

**កន្លែងទទួល៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ : .កយធ.អ.ស.ហ.ប្រក/២៣

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- បានឃើញប្រកាសលេខ ០៤៨ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចធានារ៉ាប់រង
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

**ប្រការ១.**

ត្រូវបានផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់មន្ត្រីអធិការកិច្ចធានារ៉ាប់រងរបស់និយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារចំនួន **១២ (ដប់ពីរ) រូប** ដែលមានរាយនាមដូចខាងក្រោម៖

| ល.រ | គោត្តនាម នាម | ភេទ | មុខតំណែងបច្ចុប្បន្ន |
|---|---|---|---|
| **១.ថ្នាក់អគ្គនាយក** (៣រូប) | | | |
| ១ | | ប្រុស | អគ្គនាយក |
| ២ | | ស្រី | អគ្គនាយករង |
| ៣ | | ស្រី | អគ្គនាយករង |
| **២.នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការគតិយុត្ត** (៣រូប) | | | |
| ៤ | | ប្រុស | ប្រធាននាយកដ្ឋាន |
| ៥ | | ប្រុស | ប្រធានការិយាល័យគ្រប់គ្រងអាជ្ញាបណ្ណ |
| ៦ | | ស្រី | អនុប្រធានការិយាល័យនីតិកម្ម និងផ្សះផ្សាវិវាទ |
| **៣.នាយកដ្ឋានត្រួតពិនិត្យ** (៤រូប) | | | |
| ៧ | | ស្រី | ប្រធាននាយកដ្ឋាន |
| ៨ | | ប្រុស | ប្រធានការិយាល័យត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត |
| ៩ | | ស្រី | ប្រធានការិយាល័យត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងទូទៅ |
| ១០ | | ស្រី | ប្រធានការិយាល័យត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងអន្តរការីធានារ៉ាប់រង |
| **៤.នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ** (២រូប) | | | |
| ១១ | | ប្រុស | ប្រធាននាយកដ្ឋាន |
| ១២ | | ស្រី | ប្រធានការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារ |

**ប្រការ២ ..**

មុននឹងបំពេញមុខងារ មន្ត្រីដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដូចមានកំណត់ក្នុងប្រការ១ ខាងលើ ដែលមិនទាន់បានបំពេញនីតិវិធីសម្បថ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូង ស្របតាមបញ្ញត្តិមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ប្រការ៣ ..**

មន្ត្រីដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ដូចមានកំណត់ក្នុងប្រការ១ ខាងលើមានសមត្ថកិច្ចដែនដីនៅលើវិសាលភាព នៃមណ្ឌលរដ្ឋបាល ដែលមន្ត្រីនោះត្រូវចាត់តាំងឱ្យទៅបម្រើការងារ ហើយត្រូវអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ស្តីពីការជានាប៉ាប់រង ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

គ្រប់អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករជានាប៉ាប់រងកម្ពុជា គ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ**នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ក្រសួងយុត្តិធម៌ | ក្រសួងមហាផ្ទៃ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ៩២១ អគ្គស្នងការដ្ឋាននគរបាលជាតិ. ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្ដីពីមន្ត្រីនគរបាលដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦០ និងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : .................................................. កើតថ្ងៃទី .......... ខែ .................... ឆ្នាំ ....................

ឋានន្តរសក្ដិ .................................................. អត្តលេខ .................... ឋានៈ ....................

អង្គភាព : នាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្ដល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : ..................................................

នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

លេខ: ៩.ប.យ.ន

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ_វង្សវឌ្ឍនា

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

# ឧបសម្ព័ន្ធទី៥



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

ក្រសួងយុត្តិធម៌

## សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ............ របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ស្ដីពីមន្ត្រីកងរាជអាវុធហត្ថ ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចមានចែងក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : ............ កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៨០

ឋានន្តរសក្តិ វរសេនីយ៍ត្រី អត្តលេខ ១០៨ ៣៦៥ មុខតំណែង ជំនួយការ ការិយាល័យសន្តិសុខ

អង្គភាព : មន្ទីរព័ត៌មាន និងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្ដល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : ............ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទាហានឧត្តមសេនីយ៍. ទៀ-បាញ់

លេខ ............ ន.ប.យ.ន.អ.ល

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១១

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ_វង្សវឌ្ឍនា

## ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តប៉ៃលិន

# កំណត់ហេតុស្តីពីការធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តធម៌ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន

ឆ្នាំពីរពាន់ដប់ប្រាំបី ខែបី ថ្ងៃទីពីរ វេលាម៉ោងប្រាំបួនព្រឹក នៅសាលាដំបូងខេត្តប៉ៃលិន តំណាងតុលាការ និង តំណាងអយ្យការ បានប្រារព្ធពិធីនៃការធ្វើសម្បថរបស់មន្ត្រីរាជការដែលបម្រើការងារនៅមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន នៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់បំពេញមុខងារជា មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ក្រោមសមាសភាពក្រុមប្រឹក្សានៃពិធីសម្បថដូចខាងក្រោម៖

**តំណាងតុលាការ**

-លោក ប្រធានសាលាដំបូងខេត្តប៉ៃលិន

**តំណាងអយ្យការ**

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តប៉ៃលិន

**ក្រឡាបញ្ជីនៃពិធី**

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងខេត្តប៉ៃលិន

**ដើម្បីប្រកាសបើកធ្វើពិធីសម្បថលើមន្ត្រីរាជការ៖**

១-លោកស្រី ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន

២-លោក ប្រធានការិយាល័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន

**ដំណើរការនៃពិធីសម្បថមានជាបន្តបន្ទាប់ដូចតទៅ៖**

-លោកស្រីក្រឡាបញ្ជីសាលាដំបូង ជាក្រឡាបញ្ជីនៃពិធី ធ្វើការប្រកាសហៅលោក-លោកស្រី ទាំង ០២ រូប ដែលមានឈ្មោះដូចខាងលើ ចូលក្នុងសាលពិធីម្នាក់ម្តងៗ។

-លោកប្រធានសាលាដំបូង ជាតំណាងតុលាការ បានប្រកាសបើកពិធីធ្វើសម្បថមន្ត្រីនគរបាលយុត្តិធម៌របស់មន្ត្រីរាជការដែលបម្រើការងារនៅ មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់បំពេញមុខងារជា មន្ត្រីអធិការកិច្ចទូរគមនាគមន៍។

-លោកប្រធានសាលាដំបូង ជាតំណាងតុលាការ បង្គាប់ឲ្យ លោកស្រីក្រឡាបញ្ជីសាលាដំបូង ជាក្រឡាបញ្ជីនៃពិធី អានបញ្ជីឈ្មោះនៃមន្ត្រីរាជការដែលត្រូវធ្វើសម្បថ។

-លោកស្រីក្រឡាបញ្ជីសាលាដំបូង ជាក្រឡាបញ្ជីនៃពិធីអានបញ្ជីឈ្មោះមន្ត្រីរាជការដែលមានខ្លឹមសារដូចតទៅ៖ សូមគោរពលោកប្រធាន ! មន្ត្រីរាជការដែលត្រូវធ្វើសម្បថនៅក្នុងពេលនេះ មានចំនួន ០២ រូប គឺ លោកស្រី , និងលោក ហើយនៅពេលនេះ មន្ត្រីទាំង ០២ រូបនេះ កំពុងមានវត្តមាននៅក្នុងសាលពិធីរួចហើយ។

-លោកព្រះរាជអាជ្ញារង ជាតំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖ ដោយយោងទៅតាមប្រកាសអន្តរក្រសួងលេខ ១៦៤ កយ.បទ.ប្រក/១៧ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ របស់ក្រសួងយុត្តិធម៌ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្តីពីការទទួលស្គាល់នីតិសម្បទាជា នគរបាលយុត្តិធម៌ ដល់មន្ត្រីរាជការដែលបម្រើការងារនៅ មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន នៃក្រសួង

ប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់បំពេញមុខងារជា មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ចំនួន ០២ រូប ដែលកំពុងមានវត្តមាននៅទីនេះ ហេតុនេះដោយអនុលោមទៅតាមមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងប្រការ ១ , ប្រការ ២ និងប្រការ ៣ នៃប្រកាសអន្តរក្រសួងខាងលើ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត នានាដែលកំពុងស្ថិតជាធរមាន ឃើញថាបានកំណត់អំពីលក្ខខណ្ឌគតិយុត្តតម្រូវជាដាច់ខាត ឲ្យមន្ត្រីរាជការដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូង។ ក្រោយពីបានពិនិត្យឃើញថា មន្ត្រីរាជការទាំង ០២ រូប ទទួលបានការផ្តល់នូវនីតិសម្បទាជា នគរបាលយុត្តិធម៌ ដូចដែលបានលើកឡើងខាងលើរួចមកហើយ ក្នុងនាមខ្ញុំជាតំណាងអយ្យការ សូមធ្វើការស្នើសុំដល់ក្រុមប្រឹក្សានៃពិធី ចាប់ផ្តើមធ្វើពិធីសម្បថជូនដល់លោក-លោកស្រីទាំង ០២ រូបនេះ ដើម្បីបានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ពេញលេញតាមផ្លូវច្បាប់ ចាប់ពីពេលនេះតទៅ។

-លោកស្រីក្រឡាបញ្ជីសាលាដំបូង ជាក្រឡាបញ្ជីនៃពិធី បានអញ្ជើញលោកស្រី . ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន ឲ្យធ្វើជាតំណាងមន្ត្រី នគរបាលយុត្តិធម៌ នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ប៉ៃលិន ឡើងអានប្រារព្ធវាទ (សេចក្តីអំពាវនាវ) និងបង្គាប់ឲ្យអ្នកដែលត្រូវធ្វើសម្បថផ្សេងៗទៀតថាតាមខ្លាំងៗ តាមពីដើមរហូតដល់ចប់ ដែលមានខ្លឹមសារដូចតទៅ៖ បពិត្រអស់ទេពារក្ស៍ អារុក្ខអារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ មាន ព្រះអង្គដង្កើរ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតឆ័ត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវ័រត្តបាភយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថ ត្បិតយើងខ្ញុំបានចូលខ្លួនមកសុំធ្វើសម្បថសច្ចាប្រណិធាន ដើម្បីបំពេញតួនាទីជានគរបាលយុត្តិធម៌នាពេលនេះ។ បើយើងខ្ញុំប្រព្រឹត្តល្មៀងឃ្លៀងឃ្លាតចាកច្បាប់ មិនអនុវត្តត្រឹមត្រូវតាមច្បាប់ ដោយមានចេតនាទុច្ចរិត សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់ បំផ្លាញយើងខ្ញុំឲ្យវិនាសលាញ ឲ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ឡានបុកម៉ូតូ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិ ឲ្យព្រាត់ប្រាស និរាសឪពុកម្តាយ បងប្អូន កូនចៅ ឲ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ។ បើយើងខ្ញុំប្រព្រឹត្តល្អទៀងត្រង់ត្រឹមត្រូវតាមគន្លងច្បាប់ យកចិត្តទុកដាក់ប្រឹងប្រែងអនុវត្តការងារ ដោយស្មោះត្រង់ អស់ពីចិត្តពីថ្លើម សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមី ដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឲ្យយើងខ្ញុំ មានអាយុវែងយឺនយូរ មានសេចក្តីសុខជុមរមនា មានសុខភាពល្អ មានទ្រព្យសម្បត្តិ មាស ប្រាក់ កែវកង ពិទូរ្យស្វប្រកាន្តសម្បូរហូរហៀរ លុះអនាគតជាតិ បានជួបតែសេចក្តី ល្អ មានទ្រព្យស្តុកស្តម្ភ កិត្តិយសថ្លៃថ្នូរ ចម្រុងចម្រើនថ្កុំថ្កើងរុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ។

-លោកប្រធានសាលាដំបូង ជាតំណាងតុលាការ បានធ្វើការអានពាក្យសច្ចាប្រណិធាន ដោយបង្គាប់ឲ្យអ្នកដែលត្រូវធ្វើសម្បថទាំងអស់ លើកដៃស្តាំដាក់ត្រឹមត្រចៀក និងថាតាមខ្លាំងៗ តាំងពីដើមរហូតដល់ចប់ ដែលមានខ្លឹមសារដូចតទៅ៖ ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈ ជាមន្ត្រីនគរបាលយុត្តិធម៌របស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ជាដរាបតរៀងទៅ។

-លោកព្រះរាជអាជ្ញារង ជាតំណាងអយ្យការ បានថ្លែងមតិផ្តាំផ្ញើថា៖ ក្រោយពីលោកប្រធានសាលាដំបូងជាតំណាងតុលាការ បានអានពាក្យសច្ចាប្រណិធានឲ្យអ្នកធ្វើសម្បថទាំងអស់ ចប់សព្វគ្រប់រួចរាល់អស់ហើយនោះ ក្នុងនាមខ្ញុំជាតំណាងអយ្យការ សូមសម្តែងនូវគារវកិច្ចចំពោះលោក-លោកស្រីដែលបានក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ជាផ្លូវការ និងស្របតាមច្បាប់នាពេលនេះ ហើយឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ ខ្ញុំសូមពន្យល់ណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទើបតែធ្វើសម្បថ ឲ្យគោរពនូវក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងការបំពេញតួនាទីរបស់ខ្លួន ព្រមទាំងសូមប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការអនុវត្តច្បាប់ ជាពិសេសក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

-លោកប្រធានសាលាដំបូង ជាតំណាងតុលាការ បានថ្លែងមតិផ្ដាំផ្ញើថា៖ ក្រោយពីបានស្ដាប់មតិផ្ដាំផ្ញើរបស់លោកព្រះរាជអាជ្ញារង ជាតំណាងអយ្យការ រួចមក ខ្ញុំសូមថ្លែងអំណរគុណដល់លោក-លោកស្រី ដែលបានចូលរួមក្នុងអង្គពិធី និងទើបតែទទួលបាននីតិសម្បទាជា មន្ត្រីនគរបាលយុត្តិធម៌ថ្មីៗនេះ និងសូមឲ្យលោក-លោកស្រី គោរពយ៉ាងខ្ជាប់ខ្ជួននូវរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតូបករណ៍អន្តរជាតិនានាដែលមានការពាក់ព័ន្ធ ព្រមទាំងអនុវត្តឲ្យបានតឹងរ៉ឹងនូវក្រមសីលធម៌វិជ្ជាជីវៈ ដោយត្រូវចូលរួមចំណែករក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ ទប់ស្កាត់ បង្ការ និងបង្ក្រាបបទល្មើសដែលកើតមានឡើងជាយថាហេតុគ្រប់ពេលវេលា នៅលើវិសាលភាពដែលជាសមត្ថកិច្ចដែនដីនៃមណ្ឌលរបស់ខ្លួន។

បញ្ឈប់កំណត់ហេតុនេះ នៅវេលាម៉ោងដប់ព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល។

| **ក្រឡាបញ្ជីនៃពិធី** | **តំណាងអយ្យការ** | **តំណាងតុលាការ** |
| --- | --- | --- |
| **ក្រឡាបញ្ជីសាលាដំបូង** | **ព្រះរាជអាជ្ញារង** | **ប្រធានសាលាដំបូង** |

**មន្ត្រីនគរបាលយុត្តិធម៌**

| **ហត្ថលេខា** | **ហត្ថលេខា** |
| --- | --- |

# ឧបសម្ព័ន្ធទី៧

**ក្រសួងមហាផ្ទៃ**

-------------

**អគ្គស្នងការដ្ឋាននគរបាលជាតិ**

-------------

**នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌**

-------------

**កំណត់ហេតុ**

លេខ

**ករណី :**

ប្រឆាំង/ គោត្តនាម នាម អាយុ

ចំណាត់ថ្នាក់បទល្មើស

(ឧទាហរណ៍:អំពើហិង្សាដោយចេតនា)

**កម្មវត្ថុ :**

ទទួលបណ្តឹង-បណ្តឹង ពី :

(គោត្តនាម នាម អាយុ មុខរបរ លំនៅដ្ឋាន)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ-សាសនា-ព្រះមហាក្សត្រ**

## កំណត់ហេតុ

ឆ្នាំ ២០០..............ថ្ងៃទី.......................................................................

នៅម៉ោង :.................................................................................................

យើង : គោត្តនាម នាម

អនុសេនីយ៍ឯកនគរបាល

ធ្វើការនៅ (ទីក្រុង ឬអង្គភាព)

មន្ត្រីនគរបាលយុត្តិធម៌នៅ : (ទីក្រុង)---

---នៅអង្គភាព---

---យើងបានដឹងពី.......(ទំនាក់ទំនងរឿងហេតុខ្លះ១)---

---ធ្វើសកម្មភាពក្នុងក្របខណ្ឌស៊ើបអង្កេត....(បទល្មើសជាក់ស្តែង ឬស៊ើបអង្កេតបឋម)

---បានឃើញមាត្រា ៨៦ និងបន្តបន្ទាប់ ឬមាត្រា ១១១ និងបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ---

---យើងបានធ្វើដំណើរទៅ....---

---ឬនៅម៉ោង(...)---

---យើងបានប្រាស្រ័យទាក់ទងជាមួយ......(អត្តសញ្ញាណខ្លះ)---

---ដែលប្រកាសប្រាប់ថា :---

---«(ចម្លើយប្រកាសរបស់ជនរងគ្រោះ)...

---ខ្ញុំដាក់ពាក្យបណ្តឹងប្រឆាំងលោក X ពីបទ(...) ។---

---ខ្ញុំប្រគល់(...)អោយអ្នក ។---

---ក្រោយពីអានដោយខ្លួនឯងរួចលោក(គោត្តនាម នាម) មិនផ្លាស់ប្តូរចម្លើយ ហើយយល់ព្រមចុះ ហត្ថលេខាលើកំណត់ហេតុនេះជាមួយយើង ។-----------

| **សាមីខ្លួន** | **ជំនួយការ** | **អនុសេនីយ៍ឯកនគរបាល** |
|---|---|---|

# ឧបសម្ព័ន្ធទី៨

(២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
++++++

ក-1292/02-12-2015

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ 1324 អ.យ.ទ

## កំណត់ហេតុទទួលវត្ថុចាប់យក

ពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោង ប្រាំបី និងសាមសិប នាទី។

យើង ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាអ្នកទទួល។

លោក ជាមន្ត្រីនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ រួមជាមួយឈ្មោះ កេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ ហៅ កេទប្រុស អាយុ១៥ឆ្នាំ ជាជនសង្ស័យ។

បានពិនិត្យកិនកាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មលេខ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ឃើញដូចខាងក្រោម៖

√១- ម៉ូតូមួយគ្រឿងម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ (ម៉ូតូចាស់ ហើយមានតែតួ)

២- ញញួរចំនួន០២, ដែកដាប់ចំនួន០៣, ដែកគាស់ចំនួន០១, កន្ត្រៃចំនួន០៦, កូនកាំបិតចំនួន០២, កាំបិតប៉ុងតោចំនួន០៤, ដាវចំនួន០១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន០១។

៣- អង្កចងចាំចំនួន០១។

យើងធ្វើកំណត់ហេតុនេះ ទុកជាកស្តុតាង ដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ តាមផ្លូវច្បាប់តទៅ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ប្រាំបី និងសែសិបប្រាំ នាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

ជនជាប់សង្ស័យ អ្នកប្រគល់ អ្នកទទួល

បានឃើញ
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥
ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី៩**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ : .................... អ.យ

## <u>ដីកាឆែកឆេរលំនៅដ្ឋាន</u>

**យើង** .................... **តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

-បានឃើញ ..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

**<u>យល់ឃើញថា :</u>**

ដើម្បីរុករកវត្ថុតាង និងបង្ក្រាបបទល្មើសទាក់ទិនករណីខាងលើ ..............................................................

..............................................................................................................................

.............................................................................................. ធ្វើការឆែកឆេរលំនៅដ្ឋានខាងលើ ។

**<u>ហេតុដូច្នេះសំរេច :</u>**

-ឆែកឆេរលំនៅដ្ឋានផ្ទះលេខ .................. ផ្លូវ ............... ភូមិ ........................ សង្កាត់ ......................... ខណ្ឌ ........................ រាជធានីភ្នំពេញ។

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ២០......

**តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌
នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

លេខ.... .....ល.ក.ហ
លេខសំណុំរឿង........................

លើកទី ១

## លិខិតកោះហៅ

យើងជាមន្ត្រីនគរបាលយុត្តិធម៌កោះហៅឈ្មោះ............................
ភេទប្រុស ជនជាតិខ្មែរ

ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៣៩E0 ផ្លូវលេខ៤៤០
សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ចូលមក នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ អគ្គស្នងការដ្ឋាននគរបាលជាតិ
នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២៣ វេលាម៉ោង០៨និង៣០នាទី
ដើម្បី មកបំភ្លឺបណ្តឹងរបស់ក្រុមហ៊ុន ឈីវ ទីម៉ិច គ្រុប។
ទីកន្លែង ៖ អគ្គស្នងការដ្ឋាននគរបាលជាតិ (បន្ទប់លេខ២៨)

- សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផង

ថ្ងៃសុក្រ ៣ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០២៣
**ប្រធាននាយកដ្ឋាន**

ឧត្តមសេនីយ៍ឯក.

ចូរមើលទំនាក់ទំនង

Scanned with CamScanner

# ឧបសម្ព័ន្ធទី១១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

លេខ ....[redacted]... អ.យ.ក

## ដីកាបញ្ជាឲ្យចូលខ្លួន[1]

យើង [redacted] ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- **បានឃើញ** មាត្រា **៣៧**[2] មាត្រា **៩៤**[3] និងមាត្រា **១១៤**[4] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។
- **បានឃើញ** របាយការណ៍លេខ **៣៨/២០២២ ស.ណ** ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០២២ របស់ **ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ** ។

**បញ្ជា**

-នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ53ABE[1] ផ្លូវលេខ២៧១ ភូមិទី៩ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ឲ្យចូលបង្ហាញខ្លួននៅ **កងរាជអាវុធហត្ថរាជធានីភ្នំពេញ** ឲ្យបានមុនថ្ងៃទី ...០៦..... ខែ ....ឧសភា..... ឆ្នាំ **២០២២** នៅរៀងរាល់ម៉ោងធ្វើការដើម្បីសាកសួរលើបណ្ដឹងព្រហ្មទណ្ឌពីបទ: **ឆបោក និងរំលោភលើទំនុកចិត្ត** តាមពាក្យបណ្ដឹងរបស់ឈ្មោ[redacted] ។

ថ្ងៃ សុក្រ...៦រោច.... ខែ ចេត្រ...ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ,ថ្ងៃទី...២៦..... ខែ មេសា...... ឆ្នាំ ២០២២

**ព្រះរាជអាជ្ញា**

[redacted]

---

[1] ដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន

[2] អំណាចរបស់ព្រះរាជអាជ្ញា

[3] ករណីស៊ើបអង្កេតជាក់ស្ដែង

[4] ករណីស៊ើបអង្កេតបឋម

អាសយដ្ឋាន: អាគារលេខ ២៥ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
Adress: #25, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855) - 23 88 20 59

# ឧបសម្ព័ន្ធទី១២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៛៛៛

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខៈ*

## ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

+++++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខៈ .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឱ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឱ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឱ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

## ឧបសម្ព័ន្ធទី១៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កងរាជអាវុធហត្ថលើផ្ទៃប្រទេស**

**កងរាជអាវុធហត្ថខេត្តកំពង់ធំ**

លេខ [redacted] អហ.កធ

**លិខិតបញ្ជាបេសកកម្ម**

គោរពផ្ញើជូន **គ្រប់ស្ថាប័នមានសមត្ថកិច្ច**

**មេបញ្ជាការកងរាជអាវុធហត្ថខេត្តកំពង់ធំ បញ្ជាឱ្យ**

ព្រឹក (?) ........ អនុសេនីយ៍ឯក [redacted]

មុខតំណែង ........ [redacted]

អង្គភាព ........ កងរាជអាវុធហត្ថខេត្តកំពង់ធំ

ធ្វើដំណើរទៅដល់ ........ ភូមិសាស្ត្រ ខេត្តកំពង់ធំ

បេសកកម្ម ........ សហការការងារជាមួយព្រះរាជអាជ្ញា

ភ្ជាប់ជាមួយ ........ អាវុធខ្លីម៉ាកK៥៤ លេខ២៧៨២ បង់០១ គ្រាប់០៨គ្រាប់

មធ្យោបាយ ........ រថយន្តផ្ទាល់ខ្លួន

ថ្ងៃចេញដំណើរ ........ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤

ថ្ងៃចប់បេសកកម្ម ........ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

មេបញ្ជាការកងរាជអាវុធហត្ថខេត្តកំពង់ធំ សង្ឃឹមថាអស់លោកមានសមត្ថកិច្ច ជួយសម្រួល ដោយអស់ពីចិត្ត ឲ្យលោកខាងលើបំពេញបេសកកម្ម សម្រេចតាមសំណូមពរ ។

ថ្ងៃ ចន្ទ ១២ រោច ខែ ពិសាខ ឆ្នាំ រោង ឆស័ក ព.ស២៥៦៨

កំពង់ធំ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២៤

**មេបញ្ជាការ**

(អ្នកទៅជាមួយ)

[redacted]

ពេលចប់ភារកិច្ច ត្រូវប្រគល់លិខិតនេះ

ដ្ឋាន អ.ហ ខេត្តវិញ

# ឧបសម្ព័ន្ធទី១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គស្នងការដ្ឋាននគរបាលជាតិ
ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
ផែនការងារប្រឆាំងគ្រឿងញៀន
លេខ: [redacted] ជអ.ផ.ប្រ.គ.ញ

ដីការមបញ្ជូន
សំណុំរឿងលេខ: ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣
សូមគោរពជូន
ឯកឧត្តម ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

កម្មវត្ថុ: ស្តីពីការបញ្ជូនសំណុំរឿង និង ជនសង្ស័យចំនួន ០១នាក់ ករណី រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិគោកពន្លៃ សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០២:៣០នាទី ។

| ល.រ | រាយមុខលិខិត និង វត្ថុតាង | ចំនួន | | ផ្សេងៗ |
|---|---|---|---|---|
| | | ច្បាប់ | សន្លឹក | |
| ១ | របាយការណ៍បញ្ជូនរបស់ស្នងការដ្ឋាននគរបាលខេត្ត លេខ.៤០៧១.. របក.នប ចុះថ្ងៃទី២៧.. ខែមេសា ឆ្នាំ២០២៣ | ០១ | ០១ | |
| ២ | របាយការណ៍សំយោគរបស់អធិការដ្ឋាននគរបាលក្រុងបាត់ដំបង លេខ ១០២ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ | ០១ | ០២ | |
| ៣ | របាយការណ៍ប្រតិបត្តិការរបស់លោក អនុសេនីយ៍ឯក | ០១ | ០១ | |
| ៤ | កំណត់ហេតុស្តីពីការឃាត់ខ្លួនជនសង្ស័យរបស់ឈ្មោះ | ០១ | ០២ | |
| ៥ | កំណត់ហេតុចាប់យកវត្ថុតាងរបស់ឈ្មោះ | ០១ | ០១ | |
| ៦ | កំណត់ហេតុទទួលស្គាល់សម្ភារៈ វត្ថុតាងរបស់ឈ្មោះ | ០១ | ០១ | |
| ៧ | កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ | ០១ | ០២ | |
| ៨ | កំណត់ហេតុសាវតាជាតិជនសង្ស័យរបស់ឈ្មោះ | ០២ | ០២ | |
| ៩ | កំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាងរបស់ឈ្មោះ | ០១ | ០១ | |
| ១០ | កំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនក្នុងទឹកនោមរបស់ឈ្មោះ | ០១ | ០១ | |
| ១១ | កំណត់ហេតុប្រគល់ និងទទួលជនសង្ស័យ របស់ការិយាល័យប្រឆាំងគ្រឿងញៀន | ០១ | ០១ | |
| ១២ | វត្ថុតាង:<br>-ថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក ICE) ចំនួន ០២ថង់ ទម្ងន់ ៦,២៦ក្រាម (ទាំងសំបក) ដកធ្វើតេស្តបឋម ចំនួន ០,០១ក្រាម ជាក់ស្តែង នៅសល់ចំនួន ០២ថង់ ទម្ងន់ ៦,២៥ក្រាម (ទាំងសំបក)<br>-ទូរស័ព្ទដៃចំនួន ០២ គ្រឿង (ចាស់)<br>-សម្ភារៈសម្រាប់ច្រករំលែកថ្នាំញៀនលក់ និងសម្រាប់ប្រើប្រាស់ថ្នាំញៀនមួយចំនួន ។ | | | |
| ១៣ | ជនសង្ស័យចំនួន ០១នាក់ឈ្មោះ: ភេទប្រុស អាយុ២៤ឆ្នាំ | ១២ ច្បាប់ | ១៥ សន្លឹក | |

ថ្ងៃ.......... ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦
បាត់ដំបង,ថ្ងៃទី២៨.... ខែមេសា ឆ្នាំ២០២៣
**ស្នងការរងផែនការងារប្រឆាំងគ្រឿងញៀន**

វរសេនីយ៍ឯក.

បញ្ចប់ត្រឹមលេខរៀងទី ១៣
បាត់ដំបង,ថ្ងៃទី២៨... ខែមេសា ឆ្នាំ២០២៣
បានឃើញ និង ទទួលគ្រប់ចំនួន
អ្នកទទួលសំណុំរឿង

## ឧបសម្ព័ន្ធទី១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តបាត់ដំបង

**<u>តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង</u>**

**<u>គោរពជូន</u>**

**<u>ឯកឧត្តមស្នងការនគរបាលខេត្តបាត់ដំបង</u>**

<u>កម្មវត្ថុ</u>: សុំបញ្ជូនជនសង្ស័យចំនួន០១នាក់ ឈ្មោះ ភេទស្រី អាយុ៣៦ឆ្នាំ នៅស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ជាបណ្ដោះអាសន្ន ។

<u>យោង</u>: សំណុំរឿងព្រហ្មទណ្ឌលេខ: ៦១៩ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

តាមកម្មវត្ថុខាងលើ និងយោងខាងលើ សូមជម្រាបជូន ឯកឧត្តមស្នងការ មេត្តាជ្រាបថា: កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣ អយ្យការអមសាលាដំបូងខេត្តបាត់ដំបង បានទទួលសំណុំរឿងព្រហ្មទណ្ឌ ដែលកសាងដោយស្នងការនគរបាលខេត្តបាត់ដំបង ដែលមានជនសង្ស័យ ចំនួន០១ នាក់ ពាក់ព័ន្ធ ករណីគ្រឿងញៀន អយ្យការសាលាដំបូងខេត្តបាត់ដំបង សូមបញ្ជូនជនសង្ស័យខាងលើទុកនៅស្នងការនគរបាលខេត្តបាត់ដំបង ជាបណ្ដោះអាសន្នចំនួនមួយយប់សិន លុះស្អែកឡើងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៨:៣០ នាទីព្រឹក សូម ឯកឧត្តមស្នងការ មេត្តាចាត់កំលាំងនាំខ្លួនជនសង្ស័យខាងលើនេះមកកាន់អយ្យការនៃសាលាដំបូងខេត្តបាត់ដំបង ដើម្បីចាត់ការបន្ត ។

សូម ឯកឧត្តមស្នងការ ទទួលនូវការរាប់អានអំពីយើងខ្ញុំ ។

ថ្ងៃសៅរ៍ ៨កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅបាត់ដំបង,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣
**តំណាងអយ្យការ**

បានទទួលនាំយកជនសង្ស័យខាងលើទៅក្សាទុក
បាត់ដំបង,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣
ហត្ថលេខា

# ឧបសម្ព័ន្ធទី១៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តបាត់ដំបង**
សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៧៣
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២៣

**កំណត់ហេតុសួរចម្លើយ**

ឆ្នាំពីរពាន់ម្ភៃបី ខែមេសា ថ្ងៃទីម្ភៃប្រាំបី វេលាម៉ោងប្រាំបួន និងសាមសិបនាទី ព្រឹក

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង**

ដោយមានលោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ជា ជនសង្ស័យ ដោយមានលោក.....................ជាមេធាវីការពារក្ដីដូចខាងក្រោមនេះ។

សួរ-ឆ្លើយ: ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិបឹងរាំង ឃុំអូរម៉ាល់ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅភូមិបឹងរាំង សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (រ) នៅលីវ កំរិតវប្បធម៌ថ្នាក់ទី០៧ថ្មី ទោសពីមុនគ្មាន ។

តំណាងអយ្យការបានប្រាប់អំពីសិទ្ធិក្នុងការរកមេធាវីការពារតែឈ្មោះ ថាអាចឆ្លើយដោយខ្លួនឯងបានពេលនេះ ។

សួរ:តើពេលសមត្ថកិច្ចសួរចម្លើយ សមត្ថកិច្ចបានវាយ និងបង្ខិតបង្ខំអ្នកឱ្យឆ្លើយដែរឬទេ ?

ឆ្លើយ: ពេលសមត្ថកិច្ចសួរចម្លើយខ្ញុំបាទ សមត្ថកិច្ចមិនបានវាយ និងបង្ខិតបង្ខំខ្ញុំបាទឱ្យឆ្លើយទេ ។

សួរ: តើចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ចកាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនរក្សាទុកនៅដែរឬទេ ?

ឆ្លើយ: ខ្ញុំបាទសូមរក្សាចម្លើយនៅសមត្ថកិច្ចទុកនៅដដែល ។

សួរ: តើអ្នករកស៊ីលក់គ្រឿងញៀនប៉ុន្មានឆ្នាំហើយ ?

ឆ្លើយ: ខ្ញុំបាទទើបតែចាប់ផ្ដើមរកស៊ីលក់ដូរគ្រឿងញៀនរយៈពេល០១ខែ ។

សួរ: តើគ្រឿងញៀនអ្នកទិញពីអ្នកណា ?

ឆ្លើយ: ខ្ញុំបាទទិញគ្រឿងញៀនពីឈ្មោះ មិនស្គាល់ត្រកូល ភេទប្រុស អាយុប្រហែល២៧ឆ្នាំ មានមាឌធំ សក់រួញ រស់នៅភូមិព្រែករកា សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

សួរ: តើអ្នកទិញគ្រឿងញៀនពីឈ្មោះ តម្លៃប៉ុន្មាន ?

ឆ្លើយ: ខ្ញុំបាទទិញតម្លៃពី៣០០.០០០ម៉ឺនរៀល បានចំនួន០១កញ្ចប់ ។

សួរ: តើលក់ទៅវិញចំណេញបានប្រាក់ចំនួនប៉ុន្មាន ?

ឆ្លើយ: ពេលលក់អស់ចំណេញបានប្រាក់ពី១៥០.០០០ម៉ឺនរៀល ទៅ២០០.០០០ម៉ឺនរៀល ។

សួរៈ តើអ្នកគ្រឿងញៀនពីឈ្មោះ      ប៉ុន្មានដង ?

ឆ្លើយៈ ខ្ញុំបាទទិញគ្រឿងញៀនពីឈ្មោះ      ចំនួន១០ដងមកហើយ ។

សួរៈ តើអ្នកទិញគ្រឿងញៀនពីឈ្មោះ      លើកចុងក្រោយនៅថ្ងៃណា ?

ឆ្លើយៈ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ខ្ញុំបាទបានកម្មង់ទិញគ្រឿងញៀនពីឈ្មោះ      លុះដល់វេលាម៉ោងប្រហែល ០៨យប់ ឈ្មោះ      បានយកគ្រឿងញៀនមកឱ្យខ្ញុំបាទនៅម្តុំភូមិពន្លៃ រួចខ្ញុំបាទក៏បានយកគ្រឿងញៀនមកវែចែកបានចំនួន០២កញ្ចប់ ទុកសម្រាប់ទុកបន្ត ។

សួរៈ តើក្រៅពីឈ្មោះ      អ្នកធ្លាប់ទិញគ្រឿងញៀនពីអ្នកណាផ្សេងទៀត ?

ឆ្លើយៈ ក្រៅពីឈ្មោះ      ខ្ញុំបាទទិញគ្រឿងញៀនពីឈ្មោះ      ភេទប្រុស អាយុប្រហែល៣០ឆ្នាំ មានធំ សម្បុរស្រ ទ្បែម រស់នៅភូមិអណ្តូងព្រីង សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដោយទិញគ្រឿងញៀនក្នុងតម្លៃ៣០០.០០០ម៉ឺនរៀល យកមកវែចែកទុកសម្រាប់ទុកបន្ត ។

សួរៈ តើពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានអ្វីខ្លះ ?

ឆ្លើយៈ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានគ្រឿងញៀនចំនួន០២កញ្ចប់ និងទូរស័ព្ទដៃចាស់ចំនួន០២គ្រឿង ។

សួរៈតើអ្នកមានសំណូមពរអ្វីចុងក្រោយ ?

ឆ្លើយៈ ខ្ញុំបាទគ្មានសំណូមពរអ្វីទេ ។

បញ្ចប់កំណត់ហេតុនៅថ្ងៃ ខែ ឆ្នាំដដែល វេលាម៉ោងប្រាំបួន និងហាសិបនាទី បានអានឱ្យស្តាប់សាម៉ីខ្លួន ឆ្លើយថាត្រឹមត្រូវសុខចិត្តផ្តិតមេដៃជាមួយយើង ។

| អ្នកឆ្លើយ | មេធាវី | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
| --- | --- | --- | --- |

## ឧបសម្ព័ន្ធទី១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តបាត់ដំបង
លេខ .....១០៣.......ដ.គ.ត.ច

## ដីកាតម្កល់រឿងទុកឥតចាត់ការ

**យើង** **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង**

-**បានឃើញ**:មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម /០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-**បានឃើញ**:សំណុំរឿងព្រហ្មទណ្ឌលេខ: ៧៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងវត្ថុតាងនានា ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា:**

១- អវត្តមាននៃបទល្មើស

☑-អវត្តមាននៃបទល្មើស

២- ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

☐-ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣- មូលហេតុគតិយុត្ត

☐- ការដកពាក្យបណ្តឹង

☐- ការលើកលែងទោសជាទូទៅ

☐- មរណភាពនៃជនល្មើស

☐- ផុតអាជ្ញាយុកាល

☐- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐- អាជ្ញាអស់ជំនុំ

☐- ការសម្រុះសម្រួលពីរដ្ឋ

☐- ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្រុះសម្រួល

☐- អភ័យឯកសិទ្ធិ

☐- អនិយ័តភាពនៃនីតិវិធី

☐- ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស

៤- ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

☐- ការស្វែងរកមិនបានផល

☐- ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង

☐- ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

□- ការខកខានរបស់ដើមបណ្ដឹង

□- អាកប្បកិរិយារបស់ជនរងគ្រោះ

□- ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

□- និយ័តកម្មដោយឯកឯងព្យសនកម្ម ឬការរំខានតិចតួចដែលបង្កដោយបទល្មើស

៥- នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

□- ការជួសជុលការខូចខាតដោយ /ដល់អនីតិជន

□- សន្ទានកម្ម

□- អធិបញ្ញាផ្ដល់ការព្យាបាល

□- ជនរងគ្រោះ /ដើមបណ្ដឹងបោះបង់បណ្ដឹងតាមការស្នើសុំ

□- និយ័តកម្មតាមសំណើររបស់ព្រះរាជអាជ្ញា

□- ការរំលឹកពីអត្ថបទច្បាប់ /ការព្រមាន

□- ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬនៃវិជ្ជាជីវៈ

□- ការសម្រុះសម្រួលព្រហ្មទណ្ឌ

៦- នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងទៀត

□- ការទោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនជាព្រហ្មទណ្ឌ

៧- ជនល្មើសមិនត្រូវគេស្គាល់

□- ជនល្មើសមិនត្រូវគេស្គាល់

៨- ជំនួយការអប់រំ

□- ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**បានឃើញ**:របាយការណ៍សំយោគលេខ: ០០២ នប.សថគ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកថ្មគោល នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង។

**បានឃើញ**:កិច្ចមិនព្រមព្រៀង ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ រវាងឈ្មោះ និងឈ្មោះ ។

**បានឃើញ**:វិក័យបត្រ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១។

**បានឃើញ**:ឯកសារមួយចំនួនទៀត ដែលពាក់ព័ន្ធនឹងសំណុំរឿង ។

**បានឃើញ**:ចម្លើយរបស់ដើមបណ្ដឹងឈ្មោះ នៅសមត្ថកិច្ច និងអយ្យការ ឆ្លើយប្រហាក់ប្រហែលគ្នាថា៖កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ ឈ្មោះ ភេទប្រុស អាយុ៣០ឆ្នាំ បានមកទិញសំបកកង់រថយន្តពីកន្លែងខ្លួនចំនួន២០ ក្នុងតម្លៃ៣៦៥០$ (បីពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិក តែឈ្មោះ បានទូទាត់ប្រាក់មកឱ្យប្តីខ្លួនចំនួន០៥លើក បានតែចំនួន ១៣២២$ (មួយពាន់បីរយម្ភៃពីរ) ដុល្លារអាមេរិក ដោយទូទាត់ប្រាក់មកឱ្យខ្លួនតាមរយៈទូម៉ាន់នី,វីង,អេស៊ីលីដា និងតាមរយៈធនាគារអេប៊ីអេ ឈ្មោះ នៅជំពាក់ប្រាក់ខ្លួនចំនួន ២០៨០$ (ពីរពាន់ប៉ែតសិប) ដុល្លារអាមេរិក ដោយសន្យាថាសងប្រាក់មកឱ្យខ្លួន ប៉ុន្តែមកដល់បច្ចុប្បន្នគាត់តែងតែគេចវេសរហូត។

បានឃើញ:ចម្លើយរបស់សាក្សីឈ្មោះ នៅសមត្ថកិច្ច និងអយ្យការ ឆ្លើយប្រហាក់ប្រហែលគ្នាថាកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ ឈ្មោះ ភេទប្រុស អាយុប្រហែល៣០ បានទិញសំបកកង់

ឡានពីប្រពន្ធខ្លួនឈ្មោះ                    តម្លៃ ៣៦៥០$ (បីពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិក ដោយឈ្មោះ                    បានទូទាត់ប្រាក់មកឱ្យខ្លួនបានចំនួន៥លើក បានតែចំនួន១៣២៥$ (មួយពាន់បីរយម្ភៃប្រាំ) ដុល្លារអាមេរិក ប៉ុណ្ណោះ ដោយទូទាត់ប្រាក់មកឱ្យខ្លួនតាមរយៈទ្រូម៉ាន់នី, វីង,អេស៊ីលីដា និងតាមរយៈធនាគារអេប៊ីអេ គាត់នៅជំពាក់ប្រាក់ថ្លៃទិញសំបកកង់ឡានចំនួន ២០៨០$(ពីរពាន់ប៉ែតសិប) ដុល្លារអាមេរិក ដោយសន្យាថាសងតែមកដល់បច្ចុប្បន្នគាត់តែងតែគេចវេសមិនព្រមសង។

**បានឃើញ**:ចម្លើយរបស់ជនសង្ស័យឈ្មោះ                    នៅសមត្ថកិច្ច បានឆ្លើយថា៖កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ ខ្លួនបានទៅទិញសំបកកង់ឡានពីឈ្មោះ                    ភេទស្រី អាយុប្រហែល២៧ឆ្នាំ ចំនួន ២០គ្រាប់ ក្នុងតម្លៃ៣៦៥០$ (បីពាន់ប្រាំមួយហាសិប) ដុល្លារអាមេរិក នៅពេលនោះខ្លួនពុំមានប្រាក់ទូទាត់ឱ្យភ្លាមទេ ខ្លួនបានវេរប្រាក់ទៅឱ្យឈ្មោះ                    ចំនួន៤លើក សរុបទឹកប្រាក់ចំនួន១៣២៥$ (មួយពាន់បីរយម្ភៃប្រាំ) ដុល្លារអាមេរិក ហើយខ្លួននៅខ្វះប្រាក់ថ្លៃទិញសំបកកង់ឡានឈ្មោះ                    ចំនួន ២០៨០$ (ពីរពាន់ប៉ែតសិប) ដុល្លារអាមេរិក។

**តាមការសង្កេតផ្សេងៗបានឱ្យដឹងថា**:កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ ពិតជាមានការទិញលក់សំបកកង់ឡានរវាងឈ្មោះ                    និងឈ្មោះ                    ចំនួន២០សំបកកង់ឡាន ក្នុងតម្លៃ៣៦៥០$ (បីពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិក ប៉ុន្តែឈ្មោះ                    ក្រោយពីទទួលបានសំបកកង់ឡានបែរជាមិនទូទាត់ថ្លៃទិញសំបកកង់ឡានដោយនៅខ្វះចំនួន២០៨០$ (ពីរពាន់ប៉ែតសិប) ដុល្លារអាមេរិក មកឱ្យឈ្មោះ                    ។

## យល់ឃើញថា

-តាមចម្លើយរបស់ដើមបណ្តឹង, សាក្សី, ជនសង្ស័យ, ភស្តុតាងកិច្ចមិនព្រមព្រៀង និងវិក័យបត្រអាចបញ្ជាក់ថាកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ ពិតជាមានការទិញលក់សំបកកង់ឡាន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ រវាងឈ្មោះ                    និងឈ្មោះ                    ពិតប្រាកដមែន ។

-អង្គហេតុខាងលើជាវិវាទទាក់ទងរឿងក្ដីរដ្ឋប្បវេណី ។

-អង្គហេតុខាងលើពុំមានសញ្ញាណរួមផ្សំបង្កើតជាបទល្មើសរំលោភលើទំនុកចិត្តនោះឡើយ។

-ក្រោយពីធ្វើការស៊ើបអង្កេតចប់រួចមក ឃើញថាអវត្តមាននៃបទល្មើសព្រហ្មទណ្ឌ គប្បីតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ៧៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ ទុកឥតចាត់ការ ។

## ហេតុដូច្នេះសម្រេច

តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ៧៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង <u>**ទុកឥតចាត់ការ**</u> ។

ថ្ងៃ.ចន្ទ....៥កើត......... ខែ.ពិសាខ..... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

<u>ខេត្តបាត់ដំបង</u>, ថ្ងៃទី..២៤.. ខែ.មេសា. ឆ្នាំ២០២៣

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី១៨**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តស្វាយរៀង**

សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤

លេខ អ.យ.ង

# <u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ</u>

**យើង** **តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង**

-**បានឃើញ** មាត្រា ៤៤ និងមាត្រា ១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តស្វាយរៀង ។

-**បានឃើញ** របាយការណ៍លេខ រ.ប.ក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**យល់ឃើញថា មានតម្រុយសន្និតបានថា៖**

-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិវៀតណាម មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត ឃុំយ៉ុងហ្វុង ស្រុកការហ្វុង ខេត្តហ្វាបិន ប្រទេសវៀតណាម អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅបន្ទប់ជួល ស្ថិតក្នុងភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់) នៅលីវ កម្រិតវប្បធម៌ ថ្នាក់ទី១២ ជានីតិជន ទោសពីមុនគ្មាន។ (ឃាត់ខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ៖**

កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ នៅចំណុចផ្ទះសំណាក់លុចសេរី បន្ទប់លេខ២០៣ ស្ថិតនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង មានករណី **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បង្កឡើងដោយជនសង្ស័យឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិវៀតណាម បានធ្វើសកម្មភាពយកកូនកាំបិតចាក់ទៅលើជនរងគ្រោះឈ្មោះ ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិវៀតណាម ។ រួចមកសមត្ថកិច្ចក៏បានឃាត់ខ្លួនជនសង្ស័យខាងលើ និងធ្វើតេស្តិ៍ទឹកនោមស្វែងរកសារធាតុញៀនជាលទ្ធផលវិជ្ជមាន ។ បន្ទាប់មកសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់ ។ ក្រោយពីបានធ្វើការសាកសួរជនសង្ស័យឈ្មោះ បានឆ្លើយសារភាពថា៖ ខ្លួនពិតជាបានយកកូនកាំបិតចាក់ទៅលើសង្សាររបស់ខ្លួនឈ្មោះ ប្រាកដមែន ។

អំពើខាងលើ គឺជាបទល្មើស **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់លុចសេរី បន្ទប់លេខ២០៣ ស្ថិតនៅភូមិបាវិតកណ្តាល

សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា **៤៥ កថាខណ្ឌទី១** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**សម្រេច**

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ**

☑ ដាក់ឱ្យស្ថិតក្រោមការពិនិត្យលើៈ

-ឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិវៀតណាម ។ (ឃាត់ខ្លួន)

ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់លុចសេរី បន្ទប់លេខ២០៣ ស្ថិតនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា **៤៥ កថាខណ្ឌទី១** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ ដោយមូលហេតុដូចតទៅៈ

**ក.ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី**

**ខ.ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី**

**គ.ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស ។**

ថ្ងៃសៅរ៍ ១៤រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ខេត្តស្វាយរៀង ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៤

**ចៅក្រមស៊ើបសួរ**

# ឧបសម្ព័ន្ធទី១៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តបាត់ដំបង
លេខ: ...០៥........ ដប.ជជ

## <u>ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់</u>

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង**

-បានឃើញៈមាត្រា ៤៦, ៤៩, ២៩១, ២៩៥ និងមាត្រា ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ ។

-បានឃើញៈសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៨ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្ត បាត់ដំបង ។

-បានឃើញៈ ពាក្យបណ្តឹងចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តបាត់ដំបង ។

-បានឃើញៈ ពាក្យបណ្តឹងបន្ថែមចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លោក ជាមេធាវីតំណាងឱ្យដើម បណ្តឹងឈ្មោះ ជាអ្នកតំណាងរដ្ឋបាលខេត្តបាត់ដំបង ។

### <u>ក្រោយពីបានពិនិត្យឯកសារខាងលើ</u>
### <u>ឃើញថា</u>

-កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ឈ្មោះ បានអះអាងជាមួយឈ្មោះ ថា ខ្លួនជាមេធាវីអន្តរជាតិ ហើយបានចូលរួមប្រជុំដោះស្រាយករណីបណ្តឹងឈ្មោះ នៅសាលាខេត្ត បាត់ដំបង ដោយមិនមានការអញ្ជើញឱ្យចូលរួមទេ និងធ្វើការលួចថតសម្លេងនៃអង្គប្រជុំ ។ លុះនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ឈ្មោះ បានធ្វើសកម្មភាពយកសំឡេងដែលបានលួចថតក្នុងអង្គប្រជុំនៅ សាលាខេត្តបាត់ដំបង ទៅបង្ហោះជាសាធារណៈតាមបណ្តាញសង្គមហ្វេសប៊ុកដែលមានគណនីហ្វេសប៊ុក ឈ្មោះ ព្រមទាំងបានសរសេរសំណេរ និងបានយករូបថត ឯកឧត្តម អភិបាលរងខេត្តបាត់ដំបង និយាយ(live) ដែលចោទប្រកាន់លើអភិបាលរង និងមន្ត្រីរាជការ របស់រដ្ឋបាលខេត្តបាត់ដំបងថាអសមត្ថភាព ។ ចំណែកឈ្មោះ បានធ្វើសកម្មភាពនិយាយឆ្លើយឆ្លង និងបាន ផ្តល់ព័ត៌មានមិនពិតក្នុងពេលនិយាយ(live)ចោទប្រកាន់ទៅលើមន្ត្រីរដ្ឋបាលខេត្តបាត់ដំបងជាមួយឈ្មោះ ។ លើសពីនេះទៅទៀតនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ ឈ្មោះ បាន ធ្វើការនិយាយ(live) តាមបណ្តាញសង្គមហ្វេសប៊ុកថា "សួស្តីពុកម៉ែ អ៊ុំ ពូមីង ប្រិយមិត្តទាំងអស់គ្នា ខ្ញុំបាទទទួល សំណួរតែ១ តែច្រើនលើសលុប ពីពុកម៉ែ អ៊ុំពូមីងបងប្អូនប្រិយមិត្ត ខ្ញុំបាទអរគុណណាស់ មិនចប់ទេ សេចក្តីសម្រេច នេះជាតាតុផ្សំហេតុបញ្ជាក់ឱ្យយើងនឹងច្បាស់២យ៉ាង ១.គឺមានបទល្មើសពុករលួយបានកើតឡើងពាក់ព័ន្ធនឹងអ៊ុំ

,ឈ្មោះ និងឈ្មោះ ២.បង្ហាញឲ្យច្បាស់ថាលោក មិនមានចំណេះដឹងសាកសមនិងតំណែងជាអភិបាលរងខេត្តបាត់ដំបងទេ ហើយគាត់មិនមានសិទ្ធិក្នុងការចេញសេចក្តីសម្រេចមួយនេះទេ អ្នកមានសិទ្ធិសម្រេចបែបនេះ គឺសម្តេចតេជោពុក" ហើយក៏ត្រូវបានម្ចាស់គណនីបណ្តាញសង្គមហ្វេសប៊ុកចំនួន១០ ធ្វើការចែករំលែកបន្តគឺ១-គណនីឈ្មោះ ២-គណនីឈ្មោះ ៣-គណនីឈ្មោះ ៤-គណនីឈ្មោះ ៥-គណនីឈ្មោះ ៦-គណនីឈ្មោះ ៧-គណនីឈ្មោះ ៨-គណនីឈ្មោះ ៩-គណនីឈ្មោះ ១០-គណនីឈ្មោះ

ដែលធ្វើឲ្យប្រជាពលរដ្ឋមានការយល់ច្រឡំមកលើសកម្មភាពការងាររបស់មន្ត្រីរាជការនៃសាលាខេត្ត និងប៉ះពាល់ដល់កិត្តិយសសាលាខេត្តបាត់ដំបងយ៉ាងធ្ងន់ធ្ងរខ្លាំងបំផុត ។

-បានឃើញចម្លើយរបស់ជនសង្ស័យឈ្មោះ បានឆ្លើយនៅដំណាក់កាលអយ្យការថា៖ សាលាខេត្តបាត់ដំបងបានអញ្ជើញខ្លួនចូលរួមប្រជុំកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ។ ខ្លួនមិនត្រូវជាអ្វីនឹងឈ្មោះ ទេ គឺខ្លួនស្គាល់តាមរយៈបងប្អូនខ្លួនឈ្មោះ ភេទស្រី អាយុប្រហែលជាង៤០ឆ្នាំ ដោយគាត់ប្រាប់ឲ្យខ្លួនទាក់ទងឈ្មោះ ទៅ ពីព្រោះគាត់អាចរកយុត្តិធម៌ឲ្យខ្លួនបាន ។ ខ្លួនធ្លាប់ជួបឈ្មោះ នៅភ្នំពេញម្តងត្រើយម្ខាង តាំងពីឆ្នាំ២០២២ និងបានឡាយវីឌីអូតាមហ្វេសប៊ុក តែពេលនោះខ្លួនបាននិយាយតែអំពីការឈ្លូសឆាយ និងការចូលហ៊ុនជាមួយឈ្មោះ , ឈ្មោះ , ឈ្មោះ និងឈ្មោះ តែប៉ុណ្ណឹង មិនបាននិយាយប៉ះពាល់អ្នកណាឡើយ ហើយឈ្មោះ បានប្រាប់ខ្លួនថាគាត់ជាមេធាវីអន្តរជាតិ តែខ្លួនមិនបានសួរអំពីការិយាល័យមេធាវីនោះទេ ពីព្រោះយល់ថាអ្នកដែលណែនាំខ្លួនឈ្មោះ គាត់ស្គាល់ហើយ ដោយឈ្មោះ មិនបានទារសេវាមេធាវីពីខ្លួនទេ ។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ សាលាខេត្តបានអញ្ជើញខ្ញុំបាទទៅចូលរួមដោះស្រាយពីបញ្ហាដីធ្លីខ្លួន ដោយខ្លួនមានលិខិតអញ្ជើញ ។ ចំណែកឯឈ្មោះ ក៏បានចូលរួមដែរ ដោយគាត់ប្រាប់ថាគាត់ជិះរឿងពីភ្នំពេញមកមុនខ្លួនទៅទៀត នៅថ្ងៃប្រជុំនោះឈ្មោះ បានទូរស័ព្ទមកខ្លួន ហើយប្រាប់ខ្លួនឲ្យជិះឡានជាមួយ ដោយខ្លួនមិនដឹងថាឈ្មោះ មានលិខិតអញ្ជើញឬអត់ទេ ខ្លួនដឹងថាខ្លួនមានលិខិតអញ្ជើញតែម្នាក់ឯង ។ ពេលប្រជុំឈ្មោះ និយាយអ្វីខ្លះ ខ្លួនមិនចាំទេ ពីព្រោះខ្លួនមិនបានចាប់អារម្មណ៍ ប៉ុន្តែនៅពេលប្រជុំលោកអភិបាលរងឈ្មោះ បានលើកឡើងថា "នឹងស៊ើបអង្កេតមើលរឿងដីធ្លីសិន ថាពាក់ព័ន្ធនឹងរឿងអ្វីខ្លះ គាត់នឹងដោះស្រាយឲ្យតាមក្រោយ" ដែលការលើកឡើងនេះល្អខ្លួនអាចទទួលយកបាន ។ ខ្លួនមិនដឹងថាឈ្មោះ លួចថតសម្លេងពេលប្រជុំឬអត់ទេ ប៉ុន្តែពេលប្រជុំខ្លួនបានឃើញទូរស័ព្ទ៣-៤ មិនដឹងថាអ្នកណាអ្នកថតទេ ដោយខ្លួនដឹងថាឈ្មោះ លួចថតសម្លេងពេលប្រជុំ ពេលដែលឈ្មោះ បានឡាយវីឌីអូតាមហ្វេសប៊ុក ពេលល្ងាចដែលចេញពីការប្រជុំ និងបានចាក់សម្លេងដែលបានលួចថតពេលប្រជុំនោះ ។ នៅពេលប្រជុំខ្លួនមិនបាននិយាយអ្វីទេ និយាយតែអំពីអង្គហេតុដីធ្លីរបស់ខ្លួន មិនបាននិយាយប៉ះពាល់ដល់ឯកឧត្តមអភិបាលរងខេត្តលោក ឡើយ ហើយខ្លួនទទួលស្គាល់ថាឯកឧត្តមមានប្រសាសន៍លើកឡើងល្អ ។ នៅពេលដែលឈ្មោះ និយាយឡាយវីឌីអូនៅក្នុងហ្វេសប៊ុក ខ្លួនមិនបានចូលរួមទេ ពីព្រោះឈ្មោះ នៅភ្នំពេញ ចំណែកខ្លួននៅខេត្តបាត់ដំបង ហើយពេលដែលឈ្មោះ និយាយឡាយវីឌីអូ

តាមហ្វេសប៊ុក ខ្លួនបានចែករំលែកបន្ត(Share) ឬអត់ខ្លួនមិនដឹងទេ តែប្រហែលជាចៅស្រីខ្លួនឈ្មោះ អាយុប្រហែល០៧ឆ្នាំ ជាអ្នកចុចចែករំលែកបន្ត ពីព្រោះចៅស្រីខ្លួនឧស្សាហ៍យកទូរស័ព្ទខ្លួនទៅចុចលេង ។ បច្ចុប្បន្ន ខ្លួនឈប់ទំនាក់ទំនងជាមួយឈ្មោះ ហើយ ។

-បានឃើញៈឯកសារផ្សេងៗ ដែលភ្ជាប់ទិននៅក្នុងសំណុំរឿងនេះ ។

## យល់ឃើញថា

-តាមចម្លើយជនសង្ស័យ, កំណត់ហេតុ, ភស្តុតាង បានបង្ហាញឲ្យឃើញថា កាលពីថ្ងៃទី០១ ដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ មានករណី បរិហារកេរ្តិ៍ជាសាធារណៈ និងបទ ប្រមាថ ប្រព្រឹត្តតាមបណ្តាញសង្គមហ្វេសប៊ុក ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៧២ បានធ្វើការលួចថតសម្លេងនៃអង្គប្រជុំ និងបានយកសម្លេងនោះទៅបង្ហោះជាសាធារណៈតាមបណ្តាញសង្គមហ្វេសប៊ុកឈ្មោះ ព្រមទាំងបានសរសេរសំណេរ និងបានយករូបថតឯកឧត្តម អភិបាលរងនិយាយ(live) ដែលចោទប្រកាន់លើឯកឧត្តម អភិបាលរងខេត្តបាត់ដំបង និងមន្ត្រីរាជការរបស់រដ្ឋបាលខេត្តបាត់ដំបងថាអសមត្ថភាព ពិតប្រាកដមែន ។

-ជនសង្ស័យឈ្មោះ ជានីតិជន ដែលមានសមត្ថភាពអាចទទួលខុសត្រូវខាងបទព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ។

-ជនសង្ស័យជាជនដែលមានកាយសម្បទាគ្រប់គ្រាន់ដោយពុំមានអត្តសញ្ញាណណាមួយ ដែលនាំឲ្យមានមន្ទិលសង្ស័យថា ជននេះមានបញ្ហាវិបល្លាសស្មារតីក្នុងពេលកំពុងប្រព្រឹត្តបទល្មើសនោះឡើយ ។

-ជនសង្ស័យពិតជាមានស្មារតីល្អអាចយល់ដឹងពីអំពើរបស់ខ្លួន ព្រមទាំងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ហើយខ្លួននៅតែប្រព្រឹត្តដោយចេតនាទុច្ចរិតតាមឆន្ទៈរបស់ខ្លួន ដែលច្បាប់បញ្ញត្តិថាជាបទល្មើសនិងត្រូវផ្តន្ទាទោស ។

-អំពើរបស់ជនសង្ស័យ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ ភេទប្រុស ភេទប្រុស កើតឆ្នាំ១៩៧២ ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងបទ ប្រមាថ ប្រព្រឹត្តតាមបណ្តាញសង្គមហ្វេសប៊ុក កាលពីថ្ងៃទី០១ ដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ និងមាត្រា ៥០២ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១-ចោទប្រកាន់លើ:

-ឈ្មោះ ភេទប្រុស ភេទប្រុស កើតឆ្នាំ១៩៧២ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅអគារនីតាហ្សលរ៉ូយ៉ាល់ ផ្លូវលេខ ២៨៨ និង២៩៤ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ជានីតិជន ។

ពីបទ៖ បរិហារកេរ្តិ៍ជាសាធារណៈ និងបទ ប្រមាថ ប្រព្រឹត្តតាមបណ្តាញសង្គមហ្វេសប៊ុក កាលពីថ្ងៃទី០១ ដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ និងមាត្រា ៥០២ នៃក្រមព្រហ្មទណ្ឌ ៗ

២-បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ និងសំណុំរឿងព្រហ្មទណ្ឌលេខ: ១៣៨ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង ទៅសាលាដំបូងខេត្តបាត់ដំបង ដើម្បីជំនុំជម្រះ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តបាត់ដំបង ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៣

**ព្រះរាជអាជ្ញារង**

# ឧបសម្ព័ន្ធទី២០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអមសាលាដំបូង
ខេត្តបាត់ដំបង
លេខ: ០៤....... អយ

**<u>ដំណាត់ហេតុ</u>**

**<u>ស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>**

**យើង តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៦៧ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ ។

- បានឃើញ មាត្រា ៤៧, ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

- បានឃើញ របាយការណ៍លេខ ០៥៥ ឧបកបប ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលក្រុងបាត់ដំបង នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

ឃើញថា

-នាម-គោត្តនាម: ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបររើសអេតចាយ កើតនៅភូមិកម្មករ ឃុំស្វាយប៉ោ ស្រុកទឹរួម-ខេត្តបាត់ដំបង កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុង-ខេត្តបាត់ដំបង ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (ស) នៅលីវ កំរិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុនគ្មាន ។

**យើងបានប្រាប់បុគ្គលខាងលើនេះ នូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ:**

កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ នៅចំណុចក្រុមទី០៦ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ជនសង្ស័យឈ្មោះ ភេទប្រុស អាយុ២៤ឆ្នាំ បានធ្វើសកម្មភាពលួចចូលតាមកាំជណ្តើរចំហៀងហាងអាលីបាបា ពេលចូលទៅដល់ក៏បានឈ្លូលពិលរកមើលរបស់របរមានតម្លៃ ដើម្បីលួចយក ស្រាប់តែពេលនោះម្ចាស់ហាងដឹងក៏បានចេញមកមើល និងបានចាប់ឲ្យសមត្ថកិច្ចធ្វើការឃាត់ខ្លួនយកមកសាកសួរតែម្តង ។

អង្គហេតុនេះជាបទល្មើស "ប៉ុនប៉ងលួច" ប្រព្រឹត្តនៅចំណុចក្រុមទី០៦ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ បទល្មើសមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣-៣៥៦,៣៦១ នៃក្រមព្រហ្មទណ្ឌ ។

បានឃើញ:

-ចម្លើយរបស់ជនសង្ស័យឈ្មោះ ភេទប្រុស អាយុ២៤ឆ្នាំ បានឆ្លើយនៅដំណាក់មន្ត្រីនគរបាលយុត្តិធម៌ និងអយ្យការថា កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ ខ្លួនបានធ្វើសកម្មភាពចូលទៅហាងមួយកន្លែង គោលបំណង

លួចរបស់របរគេ ប្រាកដមែន ។ពេលចូលដល់ខ្លួនបានយកពិលឈ្លបមើលរករបស់របរមានតម្លៃបម្រុងយក ស្រ
ម្ចាស់ហាងគេមានគ្នាច្រើនបានមកដល់ ខ្លួនក៏រត់ តែរត់មិនរួច ក៏ត្រូវម្ចាស់ហាងចាប់បានប្រគល់ឱ្យសមត្ថកិច្ចតែម្ត

-ចម្លើយរបស់ដើមបណ្តឹងឈ្មោះ                ភេទប្រុស អាយុ៣៦ឆ្នាំ បានឆ្លើយនៅចំណាក់កាលមន្ត្រី
បាលថា កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ម៉ោងប្រហែល២៣ និង៣០នាទី ខ្លួន និងក្រុមការងារបានបិទហាង
ចូលទៅដេកក្នុងហាងតាមកន្លែងរៀងៗខ្លួន រហូតដល់ម៉ោង២និង៣០នាទី ស្រាប់តែលឺសំលេង និងឃើញមានមនុ
ដើរឈ្លបពិលក្នុងហាង ខ្លួនក៏ដាស់គ្នាឱ្យជួយមើល និងដេញចាប់ប្រគល់ឱ្យសមត្ថកិច្ច តែម្តង ។

-យើងបានប្រាប់ដល់ជននេះថា ខ្លួនមានសិទ្ធិសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឱ្យម
ការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

- ជននេះបានឆ្លើយថា:

- ☐ ខ្ញុំជ្រើសរើសលោក/លោកស្រីមេធាវី.......................................................

- ☐ ខ្ញុំសូមស្នើសុំឱ្យមានការចាត់តាំងមេធាវី ដោយអនុលោមតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

- ☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ

- យើងបានបញ្ជាក់ថា:

- ☐ លោក/លោកស្រីមេធាវី...................អាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទ ។

- ☐យោងលើសំណើស្នើសុំឱ្យមានការចាត់តាំងមេធាវី          ស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
តំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

- ☐ លោក/លោកស្រីមេធាវី...................អវត្តមាន ។

- យល់ឃើញថា

- តាមចម្លើយជនសង្ស័យ,ចម្លើយរបស់ដើមបណ្តឹង,របាយការណ៍លេខ ០៥៥ នបកបប ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលក្រុងបាត់ដំបង នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងរួមទាំងឯកសារភស្តុតាងដែលពាក់ពន្ធ័ កំណត់បានថាពិតជាមានករណីប៉ុនប៉ងលួច ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ
ភេទប្រុស អាយុ២៩ឆ្នាំ បានធ្វើសកម្មភាពចូលទៅក្នុងហាងរបស់ជនរងគ្រោះ ដើម្បីលួចយករបស់របរមានតម្លៃ តែត្រូវម្ចាស់ហាងបានដឹង និងចាប់ប្រគល់ឱ្យសមត្ថកិច្ច ប្រាកដមែន ។

- ជនសង្ស័យ ជានីតិជនដែលមានសមត្ថភាព អាចទទួលខុសត្រូវខាងបទព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។

- ជនសង្ស័យជាជនដែលមានកាយសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានបញ្ហាវិបល្លាសស្មារតីក្នុងពេលកំពុងប្រព្រឹត្តបទល្មើសនោះឡើយ ។

- អំពើរបស់ជនសង្ស័យ  បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ,របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ            ភេទប្រុស អាយុ២៩ឆ្នាំ ពីបទប៉ុនប៉ងលួច ប្រព្រឹត្តនៅចំណុចភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលត្រូវបានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៦,៣៦១ នៃក្រមព្រហ្មទណ្ឌ ។

-អំពើប្រព្រឹត្តរបស់ជនល្មើសខាងលើ បំពេញគ្រប់លក្ខខណ្ឌដូចមានកំណត់ត្រង់មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គប្បីចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ។

## <u>ហេតុដូច្នេះសម្រេច</u>

បញ្ជូនជនជាប់ចោទ:

១-ឈ្មោះ ភេទប្រុស អាយុ២៤ឆ្នាំ (មានខ្លួន)

<u>ទៅជំនុំជម្រះ</u>: ពីបទ ប៉ុនប៉ងលួច ប្រព្រឹត្តនៅចំណុចក្រុមទី០៦ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣-៣៥៦, ៣៦១ នៃក្រមព្រហ្មទណ្ឌ ។ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះអង្គហេតុ និងបទល្មើសដូចខាងលើ។

ក្រោយពីបានអាន ជនជាប់ចោទបានផ្តិតស្នាមម្រាមដៃជាមួយយើង ។

ថ្ងៃ... ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ធ្វើនៅ... ថ្ងៃទី០៥...ខែមីនា ឆ្នាំ២០២៣

**ព្រះរាជអាជ្ញារង**

**ជនជាប់ចោទ**

# ឧបសម្ព័ន្ធទី២១



| ...ង | អត្តសញ្ញាណ ជនសង្ស័យ | ចំណាត់ការ នៃបណ្តឹង | | និទ្ទេស |
|---|---|---|---|---|
| ...ត្ត.ថ្ងៃខែឆ្នាំ | ឈ្មោះ.អាយុ.ភេទ.ទីលំនៅបច្ចុប្បន្ន | OPJ កំពុងអនុវត្តន៍ | គោលការណ៍អនុវត្តន៍ | ផ្សេង ៗ |
| [illegible] 2017 [illegible] | [illegible] | [illegible] | | |
| [illegible] 12 2017 [illegible] 26.12.2017 [illegible] | | | | |

**ឧបសម្ព័ន្ធទី២២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការ**
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ
លេខ: អក

# ដីកាឲ្យដំណឹងពីសេចក្ដីសម្រេចរបស់តុលាការ

យើង ... ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១០ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ ... (គ) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញមាត្រា ៤៨២ និងមាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ជូនដំណឹងមក**

ឈ្មោះ **...** ភេទប្រុស ឆ្នាំកំណើត ... (អាយុ ... ឆ្នាំ) សញ្ជាតិ ខ្មែរ មានទីលំនៅ ភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ ជាជនជាប់ចោទឲ្យបានជ្រាប ថាៈ រឿងក្ដីរបស់លោក ត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យធ្វើការជំនុំជម្រះ និងសម្រេចសេចក្ដីរួចហើយ តាមរយៈសាលក្រម ដូចបានយោងខាងលើ និងភ្ជាប់ជាមួយស្រាប់ ។

អាស្រ័យហេតុនេះសូមលោកជ្រាបបើលោកមិនសុខចិត្តនឹងការសម្រេចសេចក្ដីតាមសាលក្រមខាងលើនេះទេលោកមានសិទ្ធិប្ដឹងទាស់និង សាលក្រមខាងលើនេះបានក្នុងរយៈពេល **១៥ថ្ងៃ** ដោយគិតចាប់ពីថ្ងៃ បានទទួលដីកាឲ្យដំណឹង នេះតទៅនិងមានសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពេល **០១ខែ** គិតចាប់ពីថ្ងៃផុតកំណត់ នៃការប្ដឹងទាស់។

ជូនភ្ជាប់មកជាមួយនូវសាលក្រមព្រហ្មទណ្ឌលេខៈ ... (គ) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់ សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បន្ទាយមានជ័យ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

**ព្រះរាជអាជ្ញារង**

យើង..................................................ជា...............................................................
បានប្រគល់ដីកាឲ្យដំណឹងនេះដល់ឈ្មោះ..........................ទីលំនៅសព្វថ្ងៃភូមិ............................
ឃុំ/សង្កាត់..............................ស្រុក/ខ័ណ្ឌ............................ខេត្ត/ក្រុង...........................
នៅថ្ងៃទី..............ខែ....................ឆ្នាំ២០........... រួចហើយ ។

**អ្នកទទួល**
**ហត្ថលេខា ឬ ផ្ដិតមេដៃ**

**អ្នកប្រគល់**
**ហត្ថលេខា**

# ឧបសម្ព័ន្ធទី២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣

អយ្យការអម
សាលាដំបូងខេត្ត
*បន្ទាយមានជ័យ*
*លេខ៖*

## ដីកាដោះលែងទណ្ឌិត

+++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញមាត្រា ៤៩៦.៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ... (ឥ) ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១២ នៃសាលាដំបូងខេត្ត បន្ទាយមានជ័យ។

**<u>យើងចេញដីកាដោះលែងឈ្មោះដូចខាងក្រោម</u>**

-នាមត្រកូល-នាមខ្លួនៈ ...ជាតិ ខ្មែរ សាសនា

-កើតថ្ងៃទី ខែ ឆ្នាំ (អាយុ ៣៦ ឆ្នាំ ) ភេទ ប្រុស

-ស្រុកកំណើតភូមិ...ខេត្តបាត់ដំបង

-ទីលំនៅមុនពេលជាប់ទោសភូមិ...ខេត្តបន្ទាយមានជ័យ

-ជាប់ពីបទ **អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ**

-ត្រូវបានវិនិច្ឆ័យទោសចំនួន ០២ឆ្នាំ ដោយអនុវត្តទោសក្នុងពន្ធនាគារកំណត់ ០១ ឆ្នាំ គិត ចាប់ពីថ្ងៃទី ... ខែ ... ឆ្នាំ ...។

បច្ចុប្បន្នទណ្ឌិតរូបនេះ បានអនុវត្តទោសគ្រប់ចំនួនអស់ហើយ ។

ឈ្មោះ ...នេះត្រូវវិលត្រឡប់ទៅរស់នៅមូលដ្ឋាន ដើម្បីប្រកបការងារចិញ្ចឹមជីវិតជាមួយគ្រួសារវិញ។

លោកប្រធានពន្ធនាគារខេត្តបន្ទាយមានជ័យ មានភារកិច្ចអនុវត្តតាមដីកានេះប្រសិនបើទណ្ឌិតរូបនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ មករា ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

យើង...........................................ប្រធានមន្ទីរឃុំឃាំងខេត្តបន្ទាយមានជ័យបាន ដោះលែងឈ្មោះ..............................ភេទ.................អាយុ..............ឆ្នាំលេខខ្លួន ...........................ចុះថ្ងៃទី ខែ.............. ឆ្នាំ ..............ប្រព្រឹត្តបទល្មើស ....................................................នៅចំណុចភូមិ .......................ឃុំ............. ស្រុក.............................ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី .........ខែ .................. ឆ្នាំ...........តាមអំណាចដីកានេះថ្ងៃទី......ខែ...........ឆ្នាំ...........រួចហើយ។

បន្ទាយមានជ័យ ថ្ងៃទី .........ខែ......... ឆ្នាំ.........

ប្រធានមន្ទីរឃុំឃាំង